ក្រសួងមហាផ្ទៃ

# វិមជ្ឈការ និងវិសហមជ្ឈការ

# Decentralization and Deconcentration

ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០១៧



- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធខេត្តត្បូងឃ្មុំ
- ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការគាំទ្រពីអាជ្ញាធរមូលដ្ឋាន
- ការអភិវឌ្ឍមូលដ្ឋានប្រកបដោយសមធម៌ (បទពិសោធន៍ដឹកនាំនៅរដ្ឋបាលខេត្តកណ្ដាល)
- មូលនិធិឃុំ សង្កាត់ និងការអភិវឌ្ឍមូលដ្ឋាន

**គណៈកម្មការត្រួតពិនិត្យ និងផ្តល់យោបល់**

| | |
|---|---|
| ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ឯកឧត្តម **លេខ ទី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ឯកឧត្តម **ខ៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ |
| ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ |

**គណៈកម្មការនិពន្ធ និងរៀបរៀង**

| | |
|---|---|
| លោក **សូ មុនីរក្សា** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល អ.រ.ប *និពន្ធនាយក* |
| លោក **ជេដ្ឋ គឹមជុង** | អនុប្រធានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន |
| លោក **តាន់ សំណាង** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| លោក **មិន សុផានិត** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| កញ្ញា **ម៉ៅ ម៉ាលីស** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| លោកស្រី**ជី ច័ន្ទរស្មី** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| លោក **មុំ វីរៈ** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| លោក **ឆាង វ៉ៃ** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត |
| លោក **ឱ បូនី** | អនុប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ |
| លោកស្រី**ហួត សុគន្ធា** | អនុប្រធាននាយកដ្ឋានមុខងារ និងធនធាន |
| លោក **កែវ ចិត្រា** | ប្រធានការិយាល័យអភិវឌ្ឍន៍គោលនយោបាយ ន.ស.យ |
| លោក **សោម កុសល** | ប្រធានការិយាល័យតម្កល់ឯកសារ នាយកដ្ឋានរដ្ឋបាល សរុប |
| លោក **ហុង មុយហេង** | ប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានបុគ្គលិក |
| លោក **លឹម ពុទ្ធារី** | ប្រធានការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |
| លោក **ភឿន ស្រ៊ន់** | អនុប្រធានការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |
| លោក **ឆយ ធុន** | អនុប្រធានការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |
| លោកស្រី**សាភឿន មកត៌** | អនុប្រធានការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |
| លោក **ឯមតាន់ សុផានិត** | មន្ត្រីការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍អភិបាលកិច្ច ន.ប.ប |
| លោក **មាស ដារា** | មន្ត្រីការិយាល័យរដ្ឋបាល ន.ប.ប |
| លោក **ហេង ច័ន្ទសុភារិទ្ធ** | មន្ត្រីការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |
| លោក **សារីម វឌ្ឍនៈ** | មន្ត្រីការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |
| លោក **ហង្ស ប៉ូលីនតុន** | មន្ត្រីការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ ន.ប.ប |

អ.រ.ប : អគ្គនាយកដ្ឋានរដ្ឋបាល
ន.ប.ប : នាយកដ្ឋានបណ្តុះបណ្តាល
ន.ស.យ : នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់


**ទំនាក់ទំនងឧបត្ថម្ភក្រុមការងារ/ផ្សព្វផ្សាយពាណិជ្ជកម្ម**

ការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ នាយកដ្ឋានបណ្តុះបណ្តាល អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
អាសយដ្ឋាន : #២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : ០៩៨ ៣៣៣ ៣៨៧/០២៣ ៧២៦ ៨៨៤, អ៊ីម៉ែល : bulletindnd@gmail.com ,
Facebook Page : នាយកដ្ឋានបណ្តុះបណ្តាល អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

# មាតិកា


| | |
|---|---|
| ***ព្រឹត្តិការណ៍សំខាន់ៗ*** | |
| ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលខេត្ត និហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ ស្ថិតនៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ | ០១ |
| កិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម | ០៥ |
| សម្តេចក្រឡាហោម អញ្ជើញជាអធិបតីផ្សព្វផ្សាយសារាចរណែនាំស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ | ០៩ |
| សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) | ១៦ |
| សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអភិវឌ្ឍស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០ |
| ***អភិបាលកិច្ច*** | |
| ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា-កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ-(២) | ២៤ |
| ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការគាំទ្រពីអាជ្ញាធរមូលដ្ឋាន | ៣២ |
| ការអភិវឌ្ឍអ្នកដឹកនាំវ័យក្មេង | ៣៨ |
| ***ការដឹកនាំ គ្រប់គ្រង*** | |
| អ្នកដឹកនាំកើតពីកំណើត ឬពីការរៀន? | ៤២ |
| ការអភិវឌ្ឍមូលដ្ឋានប្រកបដោយសមធម៌ (បទពិសោធន៍ដឹកនាំនៅរដ្ឋបាលខេត្តកណ្តាល) | ៤៥ |
| ***ទស្សនអត្ថាធិប្បាយ*** | |
| មូលនិធិឃុំ សង្កាត់ និងការអភិវឌ្ឍមូលដ្ឋាន | ៥៥ |
| ***ការស្វែងយល់ពីបទពិសោធន៍អន្តរជាតិ*** | |
| ស្វែងយល់អំពីអាស៊ាន៖ កម្ពុជា អាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន (២) | ៦១ |
| ***កម្សាន្ត*** | |
| កំណាព្យ "វិមជ្ឈការ និងវិសហមជ្ឈការ" | ៦៦ |
| តំបន់ទេសចរណ៍សំខាន់ៗ ក្នុងខេត្តមណ្ឌលគិរី | ៦៨ |
| សារប្រយោជន៍របស់ផ្លែម្រះ សម្រាប់សុខភាព | ៧៣ |
| ***លិខិតបទដ្ឋាន*** | |
| អនុក្រឹត្យស្តីពីប័ណ្ណព្រំដែនកម្ពុជា-ថៃ | ៧៦ |
| ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ | ៨១ |
| ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ | ៨៦ |

# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ ស្ថិតនៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ



*ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ*

ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលខេត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃទីរួមខេត្តត្បូងឃ្មុំ បានប្រព្រឹត្តទៅកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងដោយមានការអញ្ជើញចូលរួមពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវ ជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ថ្នាក់ដឹកនាំក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំខេត្តត្បូងឃ្មុំ និងខេត្តពាក់ព័ន្ធ មន្ត្រីរាជការ និងប្រជាពលរដ្ឋខេត្តត្បូងឃ្មុំសរុបប្រមាណ ១២,០០០នាក់។

ខេត្តត្បូងឃ្មុំជាខេត្តទើបបង្កើតថ្មីលើទឹកដីចាស់នៃខេត្តកំពង់ចាម តាមរយៈព្រះរាជក្រឹត្យ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣ និងប្រកាសដាក់ឱ្យដំណើរការស្របជាមួយការប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាខេត្តកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤។ ខេត្តត្បូងឃ្មុំជាខេត្តទី២៥ ដែលត្រូវបានបង្កើតថ្មីជាបន្តបន្ទាប់ក្នុងអំឡុងពេល៣៨ឆ្នាំ ក្នុងដំណើរការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិពីបាតដៃទទេ ពីគំនរផេះផង់នៃសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ប៉ុលពត។ ក្រោយពីប្រទេសជាតិត្រូវបានរំដោះពីរបបប៉ុលពត នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរាជធានី និងខេត្តឡើងវិញទូទាំងប្រទេស។ គិតត្រឹមចុងឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាមានខេត្តចំនួន១៩ និងក្រុងភ្នំពេញ។ នៅឆ្នាំ១៩៨៨ ខេត្តបន្ទាយមានជ័យត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ ដោយបំបែកចេញពីខេត្តបាត់ដំបង។ ខេត្តឧត្តរមានជ័យដែលធ្លាប់បានបង្កើតនាសម័យសង្គមរាស្ត្រនិយម ក៏ត្រូវបានបង្កើត

ឡើងវិញនាឆ្នាំ១៩៩៥ និងប្រកាសដាក់ឱ្យដំណើរការនាឆ្នាំ១៩៩៩ បន្ទាប់ពីការអនុវត្តដោយជោគជ័យនូវនយោបាយ "ឈ្នះ ឈ្នះ" តាមរយៈការធ្វើសមាហរណកម្មអតីតកម្លាំងខ្មែរក្រហមនៅអន្លង់វែង។ ចំពោះកែប និងប៉ៃលិន ក៏ត្រូវបានបង្កើតជាក្រុងថ្នាក់ស្មើខេត្ត និងប្តូរមកជាខេត្តនៅឆ្នាំ២០០៨។ ការបង្កើតខេត្តត្បូងឃ្មុំ ក៏ដូចការបង្កើតខេត្តថ្មីៗ ខាងលើនេះ សំដៅឆ្លើយតបជាមួយកំណើនប្រជាជនដែលតម្រូវ



*ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលខេត្ត*

ឱ្យបង្កើនការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍ តាមរយៈការបង្កើតរដ្ឋបាលខេត្តដែលមានតួនាទីគាំទ្រ សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ឱ្យកៀកជិតប្រជាពលរដ្ឋ ព្រមទាំងការបង្កើតនូវមជ្ឈមណ្ឌលសេដ្ឋកិច្ច សង្គម សម្រាប់ធ្វើការផ្លាស់ប្តូរ ទំនិញ សេវាកម្ម កសិផលនានារបស់ប្រជាពលរដ្ឋនៅតំបន់ជនបទឱ្យបានកាន់តែច្រើនឡើងថែមទៀត សំដៅកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទ។ ជាក់ស្តែង ខេត្តដែលបានបង្កើតថ្មីៗ ដូចជាខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន និងខេត្តកែប បានកំពុងមានការអភិវឌ្ឍរីកចម្រើនក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ចសង្គមសម្រាប់ផ្លាស់ប្តូរ ទំនិញ សេវាកម្ម កសិផលនានាដែលប្រជាជនផលិតបានក្នុងតំបន់ ការបង្កើតទីផ្សារការងារថ្មីៗបន្ថែមទៀតនៅតំបន់ជនបទ ដែលជាការរួមចំណែកបង្កើនប្រាក់ចំណូលគ្រួសាររបស់ប្រជាជន។

ការសម្រេចជ្រើសយកទីតាំងដីចំការម៉ៅសាក់ ស្ថិតនៅក្នុងភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ធ្វើជាទីតាំងរដ្ឋបាលខេត្តត្បូងឃ្មុំ ដោយធ្វើការសាងសង់នូវសាលាខេត្ត មន្ទីរ អង្គភាពជំនាញជុំវិញខេត្ត សាលារៀន មន្ទីរពេទ្យ។ល។ រាជរដ្ឋាភិបាលបានវាយតម្លៃយ៉ាងហ្មត់ចត់អំពីទីតាំងនៃទីរួមខេត្តត្បូងឃ្មុំ ដោយផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ភាពងាយស្រួលក្នុងការទំនាក់ទំនងការងាររវាងខេត្តជាមួយស្រុក ក្រុង ឃុំ សង្កាត់ក្នុងខេត្ត ការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គមកិច្ច កត្តាប្រវត្តិសាស្ត្រ ប្រភពទឹកប្រើប្រាស់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ។ ការសាងសង់អគាររដ្ឋបាលសាលាខេត្ត និងមន្ទីរ អង្គភាពនានាជុំវិញខេត្ត ជារដ្ឋបាលប្រមូលផ្តុំតាមគោលការណ៍នៃរដ្ឋបាលឯកភាព នឹងជួយបង្កើនប្រសិទ្ធភាពក្នុងការទំនាក់ទំនងរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលខេត្ត និងការផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋបានកាន់តែងាយស្រួល ឆាប់រហ័ស ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ព្រមជាមួយគ្នានេះ រាជរដ្ឋាភិបាលបានធ្វើការសាងសង់អគារស្នាក់នៅសម្រាប់មន្ត្រីរាជការ ដើម្បីជួយសម្រួលមួយផ្នែកដល់មន្ត្រីរាជការដែលភាគច្រើនពុំមានលំនៅឋានអចិន្ត្រៃយ៍នៅទីនេះបានស្នាក់នៅ និងបំពេញការងារនៅទីតាំងថ្មីនៃរដ្ឋបាលខេត្តត្បូងឃ្មុំ។

ទន្ទឹមនេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់ជាមូលដ្ឋាននានាសម្រាប់បង្កើតនូវទីរួមខេត្តថ្មីនេះ ក៏

ត្រូវបានកសាងឡើងសម្រាប់ទស្សនវិស័យរយៈពេលវែងដោយផ្អែកលើការកើនឡើងយ៉ាងឆាប់រហ័សនូវទីក្រុង ទីប្រជុំជននានាដែលជាផ្លែផ្កានៃការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ៧% ក្នុងមួយឆ្នាំក្នុងរយៈពេលជិតពីរទសវត្សរ៍កន្លងទៅនេះ។ អាស្រ័យហេតុនេះ ការអភិវឌ្ឍប្រព័ន្ធផ្លូវគមនាគមន៍ អគ្គិសនី ទឹកស្អាត ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង រាវជាដើម គឺអាចមានសមត្ថភាពទ្រទ្រង់ការអភិវឌ្ឍរីកចម្រើន រយៈពេលវែងពី១៥ ទៅ២០ឆ្នាំខាងមុខ។

ដើម្បីអភិវឌ្ឍទីរួមខេត្តត្បូងឃ្មុំ ដែលជាខេត្តទើបបង្កើតថ្មីសម្រាប់ទស្សនវិស័យរយៈពេលវែង សំដៅធានាដល់ការអភិវឌ្ឍដោយមានការគ្រោងទុក មានរបៀបរៀបរយ សណ្តាប់ធ្នាប់ល្អ និងមាននិរន្តរភាព ប្លង់គោលទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំត្រូវបានអនុម័តដោយគណៈកម្មការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដែលចែកចេញជា ០៤មណ្ឌល គឺមជ្ឈមណ្ឌលរដ្ឋបាលប្រមូលផ្តុំរបស់ខេត្ត មជ្ឈមណ្ឌលសេដ្ឋកិច្ច និងពាណិជ្ជកម្ម មជ្ឈមណ្ឌលទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ ព្រមទាំងមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល។

អគារសាលាខេត្ត មន្ទីរ អង្គភាពនានាជុំវិញខេត្ត និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ នានា ដែលបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនេះ ត្រូវបានវិនិយោគទាំងស្រុងដោយថវិកាជាតិ និងការចូលរួមពីសប្បុរសជននានា។ សំណង់អគារសាលាខេត្ត និងមន្ទីរ អង្គភាពនានាជុំវិញខេត្ត ត្រូវបានសាងសង់ឡើងក្នុងលក្ខណៈជារដ្ឋបាលប្រមូលផ្តុំ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការផ្តល់សេវានានា ជូនប្រជាពលរដ្ឋ ក៏ដូចទំនាក់ទំនងរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលខេត្ត។



*អគាររដ្ឋបាលខេត្តត្បូងឃ្មុំ*

ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ការផ្តល់សេវានានាជូនប្រជាពលរដ្ឋមិនពឹងផ្អែកទាំងស្រុងតែទៅលើអគារ និងកន្លែងធ្វើការតែប៉ុណ្ណោះទេ បញ្ហាសំខាន់បំផុតគឺការលើកកម្ពស់ការផ្តល់សេវាជូនប្រជាពលរដ្ឋ តាមរយៈការកែទម្រង់នូវប្រព័ន្ធ បែបបទ នីតិវិធីនៃការផ្តល់សេវា និងការពង្រឹងសមត្ថភាពមន្ត្រី ការកែប្រែទម្លាប់ និងឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ក្នុងការផ្តល់សេវា ការដោះស្រាយសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋឱ្យបានកាន់តែងាយស្រួល ឆាប់រហ័ស មានគុណភាព មានតម្លាភាព និងមានគណនេយ្យភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធទាំងនេះគ្រាន់តែជាជំហានចាប់ផ្តើមដើម្បីប្រែក្លាយតំបន់នេះពីព្រៃចំការកៅស៊ូ ពីជនបទដែលមានប្រជាជនរស់នៅតិចតួចឱ្យទៅជាទីតាំងរដ្ឋបាលខេត្ត ជាទីប្រជុំជន និងជាទីក្រុងនាពេលអនាគត។ ដើម្បីបន្តប្រែក្លាយ

តំបន់នេះជាទីប្រជុំជន និងជាទីក្រុងប្រកបដោយ សក្តានុពល យើងនៅមានសេសសល់កិច្ចការនានា ជាច្រើនទៀតដែលត្រូវកសាង និងអភិវឌ្ឍ។ ហេតុនេះ គម្រោងអាទិភាពដែលនៅសេសសល់ត្រូវរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ពហុឆ្នាំ ដោយដាក់បញ្ចូលគម្រោង ទាំងនោះទៅក្នុងផែនការអភិវឌ្ឍន៍ និងគម្រោងថវិកា ប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត មន្ទីរ អង្គភាពនានាជុំវិញ ខេត្ត និងក្រសួង ស្ថាប័នតាមវិស័យដែលពាក់ព័ន្ធ គម្រោងទាំងនោះ។ រដ្ឋបាលខេត្តត្រូវសហការសម្របសម្រួលជាមួយមន្ទីរ អង្គភាពនានាជុំវិញខេត្ត និង ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការអនុវត្តគម្រោង អភិវឌ្ឍន៍ជាអាទិភាពនានាស្របតាមប្លង់គោល និង ប្លង់ប្រើប្រាស់ដីធ្លីដែលបានកំណត់។ អាស្រ័យដោយ ប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ទើបយើង មានលទ្ធភាពរៀបចំអភិវឌ្ឍអគាររដ្ឋបាលប្រមូលផ្តុំ ហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដើម្បីប្រែក្លាយតំបន់ នេះពីចំការម៉ៃសាក់ ពីតំបន់ជនបទឱ្យទៅជាទីរួមខេត្ត ជាទីប្រជុំជន និងជាទីក្រុង រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ធារាសាស្ត្រ អគ្គិសនី សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធសង្គម នានាជាច្រើនទៀត ដែលធ្វើឱ្យសង្គមជាតិរបស់យើង មានការប្រែប្រួលផ្លាស់ប្តូររីកចម្រើនជារៀងរាល់ថ្ងៃ។

*ដោយ ឆាង វ៉ៃ*

# កិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម

តបតាមការអញ្ជើញរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម ផាម ប៊ិញ មិញ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម** បានដឹកនាំគណៈប្រតិភូវៀតណាមចូលរួមកិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម នាថ្ងៃទី១៣-១៥ ខែមីនា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពសហប្រធានកិច្ចប្រជុំ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តម ផាម ប៊ិញ មិញ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម** ដោយមានសមាសភាពចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួននៃប្រទេសទាំងពីរ និងថ្នាក់ដឹកនាំនៃបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។


*កិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម*

កិច្ចប្រជុំលើកទី៩នេះ បានប្រព្រឹត្តដោយរលូនស្របទៅតាមរបៀបវារៈ និងកម្មវិធីដែលបានគ្រោងទុកក្នុងបរិយាកាសមិត្តភាព សាមគ្គីភាព ភាតរភាព និងយោគយល់គ្នាទៅវិញទៅមក។ ភាគីទាំងពីរបានបង្ហាញនូវការយល់ឃើញរួមគ្នាអំពីសារៈសំខាន់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ដែលបានរួមចំណែកយ៉ាងសំខាន់ នៅក្នុងការពង្រឹងពង្រីកចំណងទំនាក់ទំនងជាមិត្តភាព សាមគ្គីភាពជាប្រពៃណីរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើន និងកាន់តែស៊ីជម្រៅថែមទៀត។ ភាគីទាំងពីរមានសេចក្តីសោមនស្សរីករាយ និងបានសំដែងនូវបំណងដូចគ្នាក្នុងការបន្តរក្សានូវចំណងទាក់ទង "ភូមិផងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ឋិតថេរ រឹងមាំយូរអង្វែង" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមដែលជាប្រទេសជិតខាងល្អនឹងគ្នា ព្រមទាំងខិតខំកសាង និងថែរក្សាការពារឱ្យបាននូវព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ ការអភិវឌ្ឍ និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកសម្រាប់ប្រជាជាតិ និងប្រជាជននៃប្រទេសទាំងពីរ។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការផ្លាស់ប្តូរដំណើរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរ ដែលបានសបញ្ជាក់ឱ្យឃើញពីការរីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែរឹងមាំ និងស៊ីជម្រៅថែមទៀត។ ភាគីទាំងពីរបានពិនិត្យឃើញថា ទំនាក់-ទំនង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាង

ប្រទេសទាំងពីរត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី តំបន់ និងអន្តរជាតិ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរ ជាពិសេសនៅតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ។

ភាគីទាំងពីរសំណូមពរដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរបន្តជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការតាមវិស័យនីមួយៗឱ្យបានកាន់តែសកម្ម និងខ្លាំងក្លាថែមទៀត ជាពិសេសប្រែក្លាយផែនការសហប្រតិបត្តិការតាមវិស័យដែលបានឯកភាពគ្នាឱ្យទៅជាសកម្មភាពជាក់ស្តែង ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។ ទន្ទឹមនេះ កិច្ចប្រជុំក៏បានស្នើដល់ក្រសួង ស្ថាប័នពាក់ព័ន្ធខិតខំសម្របសម្រួល និងដោះស្រាយសំណើ សំណូមពរ និងការលំបាករបស់បណ្តាខេត្តជាប់ព្រំដែនឱ្យបានទាន់ពេលវេលា និងតាមលទ្ធភាពជាក់ស្តែង។

ភាគីទាំងពីវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ ដែលត្រូវបានបន្តពង្រឹង និងលើកកម្ពស់ជាប្រចាំ ហើយបានរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ ដោយក្នុងឆ្នាំ២០១៦កន្លងមកនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានក្នុងរង្វង់ ៧% និងសេដ្ឋកិច្ចវៀតណាមសម្រេចបាន ៦,២១%ដែលជាអត្រាមួយខ្ពស់។

ភាគីទាំងពីរនឹងធ្វើការសិក្សា និងពិនិត្យលទ្ធភាពក្នុងការដំឡើងកម្រិត និងបង្កើតថ្មីនូវច្រកទ្វារព្រំដែន ដោយផ្អែកលើគោលការណ៍ជាក់ស្តែង ប្រសិទ្ធភាព សមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់បណ្តាខេត្តជាប់ព្រំដែន និងគោរពទៅតាមបទដ្ឋានកំណត់នៃច្បាប់របស់ប្រទេសនីមួយៗ។ ភាគីទាំងពីរឯកភាពជំរុញការដំឡើងកម្រិតច្រកទ្វារតំបន់ព្រំដែនម៉ឺនជ័យ (ខេត្តព្រៃវែង) និងច្រកទ្វារតំបន់ព្រំដែនតឹនណាន (ខេត្តតៃនិញ) ទៅជាច្រកទ្វារព្រំដែនអន្តរជាតិឱ្យបានឆាប់។



*កិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម*

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើននៃកិច្ចសហប្រតិបត្តិការលើវិស័យសាធារណការ និងដឹកជញ្ជូនរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ដែលបានខិតខំជំរុញការតភ្ជាប់បណ្តាញផ្លូវគមនាគមន៍សំខាន់ៗនៅតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរពាណិជ្ជកម្ម ការដឹកជញ្ជូនទំនិញ និងអ្នកដំណើរឆ្លងកាត់ព្រំដែន។

ភាគីទាំងពីរឯកភាពគ្នាផ្លាស់ប្តូរទស្សនកិច្ច បទពិសោធន៍ល្អ និងព័ត៌មានទៅវិញទៅមកដើម្បីពង្រឹង និងអភិវឌ្ឍន៍វិស័យកសិកម្ម ព្រៃឈើ និងផលផល រវាងបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ ព្រមទាំង

ជួយឧបត្ថម្ភបច្ចេកទេស ពូជដំណាំ ពូជសត្វដែលមានគុណភាព និងទិន្នផលខ្ពស់ឱ្យគ្នាទៅវិញទៅមក។ ភាគីទាំងពីរនឹងរួមសហការគ្នាខិតខំស្វែងរកទីផ្សារទិញកសិផលបន្ថែមទៀត ដើម្បីជំរុញការលក់កសិផលនៅតាម បណ្តាខេត្តជាប់ព្រំដែន ក៏ដូចការពារតម្លៃកសិផលក្នុងកម្រិតមួយសមស្រប និងមានស្ថិរភាព ជាពិសេសលើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួលដល់ការបង្កើតរោងចក្រ សហគ្រាសកែច្នៃកសិផលនៅនឹងកន្លែង។ ភាគីទាំងពីរប្តេជ្ញារួមសហការគ្នាទប់ស្កាត់ និងបង្ក្រាបនូវសកម្មភាពកាប់បំផ្លាញព្រៃឈើ ការជួញដូរ និងការដឹកជញ្ជូនឈើ ផលនេសាទ និងសត្វព្រៃខុសច្បាប់ឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរ។

ភាគីវៀតណាមនឹងខិតខំបន្តរក្សានូវទំនុកចិត្ត និងធានាការផ្គត់ផ្គង់អគ្គិសនីឱ្យកម្ពុជា។ ភាគីទាំងពីរគប្បីសហការឱ្យបានជិតស្និទ្ធ ដើម្បីដំណើរការបណ្តាវិធានការបច្ចេកទេស និងវិនិយោគដែលធានាឱ្យបណ្តាញតភ្ជាប់អគ្គិសនីរវាងប្រទេសទាំងពីរ (ពិសេសបណ្តាញតភ្ជាប់ ២២០KV ចូវដុក-តាកែវ) ដំណើរការប្រកបដោយទំនុកចិត្តស្ថិរភាព និងសុវត្ថិភាព។ ភាគីទាំងពីរខិតខំអនុវត្តឱ្យបានម៉ឺងម៉ាត់បណ្តាការព្រមព្រៀងទិញលក់អគ្គិសនីដែលបានចុះហត្ថលេខា និងអនុវត្តតាមកាតព្វកិច្ចដែលបានចែងក្នុងកិច្ចព្រមព្រៀង។

ភាគីទាំងពីរឯកភាព និងជំរុញឱ្យមានការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ឬរៀបចំសិក្ខាសាលា ឬសន្និសីទផ្សេងៗ ដើម្បីចែករំលែកបទពិសោធន៍ ចំណេះដឹង និងការរីកចម្រើនលើវិស័យសុខាភិបាល ព្រមទាំងផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកឱ្យបានឆាប់រហ័ស អំពីជំងឺឆ្លង និងសហការទប់ស្កាត់ និងត្រួតពិនិត្យកុំឱ្យមានរីករាលដាលជំងឺឆ្លងដែលអាចប៉ះពាល់ដល់អាយុជីវិត និងសុខភាពប្រជាពលរដ្ឋ ជាពិសេសនៅតាមមាត់ច្រកទ្វារព្រំដែន។ ភាគីទាំងពីរនឹងបន្តខិតខំសហការទប់ស្កាត់ និងបង្ក្រាបការជួញដូរឱសថក្លែងក្លាយ ឬខូចគុណភាព ក៏ដូចជាមូលដ្ឋានផលិត ព្រមទាំងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកឱ្យបានឆាប់រហ័ស និងទាន់ពេលវេលាលើការងារនេះ។ ខេត្តជាប់ព្រំដែនរបស់វៀតណាមនៅតែបន្តផ្តល់ភាពអនុគ្រោះ និងបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋកម្ពុជាដែលឆ្លងដែនទៅពិនិត្យ និងព្យាបាលជំងឺនៅមន្ទីរពេទ្យ និងមូលដ្ឋានសុខាភិបាលវៀតណាម ដោយគិតតម្លៃដូចប្រជាពលរដ្ឋវៀតណាមដែរ។

ភាគីកម្ពុជាវាយតម្លៃខ្ពស់ចំពោះភាគីវៀតណាមដែលបានផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិត មន្ត្រីរាជការ ដើម្បីបន្តសិក្សាកម្មវិធីមហាវិទ្យាល័យ ក្រោយមហាវិទ្យាល័យ និងបំពាក់បំប៉នមុខជំនាញបច្ចេកទេសបន្ថែមនៅតាមសាកលវិទ្យាល័យ ឬគ្រឹះស្ថានបណ្តុះបណ្តាល ឬស្ថាប័នរដ្ឋនានានៅសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានរួមចំណែកលើកកម្ពស់សមត្ថភាព និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

ភាគីទាំងពីរសហការជិតស្និទ្ធក្នុងការបង្កើនការអភិវឌ្ឍទេសចរណ៍នៅបណ្តាខេត្តជាប់ព្រំដែន ដោយប្រមូលផ្តុំលើបណ្តាវិស័យផ្លាស់ប្តូរព័ត៌មាន ការតភ្ជាប់ខ្សែទស្សនកិច្ច ការអភិវឌ្ឍផលិតផល ជំរុញការផ្សព្វផ្សាយ អភិវឌ្ឍន៍ប្រភពធនធានមនុស្សក្នុងវិស័យទេសចរណ៍។ ភាគីទាំងពីររួមគ្នាសហការកសាងគោលដៅរួមនៃប្រទេសទាំងពីរ ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដូចជាសហប្រតិបត្តិការ CLV, CLMV, GMS, ACMECS, ASEAN។ ភាគីទាំងពីរឯកភាពជំរុញការកសាង និងផ្សព្វផ្សាយផលិតផលទេសចរណ៍របស់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមលើប្រធានបទ "ប្រទេសពីរ គោលដៅមួយ" និងចាត់តាំងការតាំងពិព័រណ៍ទេសចរណ៍សំដៅទាក់ទាញភ្ញៀវទេសចរ និងវិនិយោគមកលើវិស័យទេសចរណ៍។

ភាគីទាំងពីរវាយតម្លៃខ្ពស់ចំពោះក្រុមការងារបច្ចេកទេស និងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរដែលបានខិតខំប្រឹងប្រែងក្នុងការ

កំណត់ខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរដែលរហូតមកដល់ពេលបច្ចុប្បន្ននេះសម្រេចបានប្រមាណ ៨៤%។ លើមូលដ្ឋាននេះ ភាគីទាំងពីរជំរុញឱ្យបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរត្រូវសហការគ្នាថែរក្សា និងការពារបង្គោលព្រំដែន និងបង្គោលតម្រុយព្រំដែនដែលបានបោះរួច មិនឱ្យមានការបំផ្លិចបំផ្លាញ និងត្រូវខិតខំបន្តរក្សាការគ្រប់គ្រងព្រំដែនត្រឹមត្រូវតាមសន្ធិសញ្ញា និងការព្រមព្រៀងស្តីពីព្រំដែនដែលប្រទេសទាំងពីរបានចុះហត្ថលេខា។ ក្នុងករណីមានហេតុការណ៍ ឬបាតុភាពអ្វីមួយកើតឡើងនៅតំបន់ព្រំដែន បណ្តាខេត្តជាប់ព្រំដែនត្រូវពិភាក្សាគ្នា និងសហការគ្នាដោះស្រាយភ្លាម មិនទុកឱ្យបញ្ហាកើតមានឡើងរីករាលដាលបង្កផលប៉ះពាល់ដល់ទំនាក់ទំនងជាប្រពៃណីល្អរវាងប្រទេសទាំងពីរ និងបង្កការរាំងស្ទះដល់ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនឡើយ ដោយឈរលើស្មារតីយោគយល់គ្នាទៅវិញទៅមក និងសន្តិវិធី។ បណ្តាខេត្តជាប់ព្រំដែនត្រូវបន្តសហការ និងសម្របសម្រួលដោះស្រាយបញ្ហាបាក់ដីច្រាំងទន្លេ ឬព្រែកនៅតាមបណ្តោយព្រំដែន ដោយឈរលើក្របខ័ណ្ឌច្បាប់ដែលបានព្រមព្រៀងគ្នា ការយោគយល់គ្នា និងឆន្ទៈមិនបំពានគ្នា ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋរស់នៅតំបន់ព្រំដែន។ ដើម្បីបម្រើដល់ការងារបោះបង្គោលព្រំដែនបំពេញបន្ថែម និងបង្គោលតម្រុយព្រំដែន ភាគីទាំងពីរឯកភាពសហការគ្នាឱ្យបានស្អិតរមួត ដើម្បីចៀសវាងនូវបាតុភាពផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដែលរំខានដល់ការកសាងព្រំដែនរវាងប្រទេសទាំងពីរ។

ភាគីទាំងពីរវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនៅតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរដែលបានខិតខំប្រឹងប្រែងថែរក្សា និងការពារបានយ៉ាងល្អប្រសើរនូវសន្តិសុខសណ្តាប់ធ្នាប់នៅតាមតំបន់ព្រំដែននៃប្រទេសទាំងពីរ ជាមួយនឹងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងឆាប់រហ័សនៅក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទនៅតាមតំបន់ព្រំដែន ដែលធានាបានយ៉ាងរឹងមាំនូវខឿនសន្តិភាព និងស្ថិរភាពសង្គម។

ភាគីទាំងពីរឯកភាពរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឆ្នាំ២០១៨។ កាលបរិច្ឆេទ និងទីកន្លែងប្រជុំជាក់ស្តែងនឹងជូនដំណឹងតាមរយៈការទូត។

ជំនួសមុខគណៈប្រតិភូនៃសាធារណរដ្ឋសង្គមនិយមវៀតណាម **ឯកឧត្តម ផាម ប៊ិញ មិញ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស** បានវាយតម្លៃខ្ពស់ចំពោះការចាត់ចែងរៀបចំយ៉ាងហ្មត់ចត់របស់ភាគីកម្ពុជា និងវាយតម្លៃកិច្ចប្រជុំបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងទទួលបានលទ្ធផលល្អប្រសើរ និងសូមថ្លែងអំណរគុណចំពោះ**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងភាគីកម្ពុជា ដែលបានទទួលបដិសណ្ឋារកិច្ចយ៉ាងមហោឡារិក និងកក់ក្តៅ ក្នុងមនោសញ្ចេតនាវិតចំណងសាមគ្គីភាព មិត្តភាពជាភាតរភាព ជូនចំពោះគណៈប្រតិភូវៀតណាម ក្នុងអំឡុងពេលទស្សនកិច្ច និងចូលរួមកិច្ចប្រជុំដ៏វិសេសវិសាលនេះ៕

*ដោយ ឆាង វៃ*

# សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយ សារាចរណែនាំស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ



នៅព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងមហាផ្ទៃ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)** បានអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយខ្លឹមសារនៃសារាចរណែនាំស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងសហគមមូលដ្ឋាន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ។ ពិធីនេះមានគោលបំណងផ្សព្វផ្សាយសារាចរណែនាំរបស់រាជ- រដ្ឋាភិបាលលេខ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១៦ ជូនដល់ថ្នាក់ដឹកនាំ ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ តំណាងសហគមន៍មូល-ដ្ឋាន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាឱ្យបានជ្រួតជ្រាប សំដៅលើកកម្ពស់កិច្ចសហការគ្នាឱ្យបានកាន់តែជិតស្និទ្ធនិងចូលរួមយ៉ាងសកម្មក្នុងការចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិឱ្យមានប្រសិទ្ធភាពខ្ពស់។

នាឱកាសនោះ **ឯកឧត្តម សាយ សំអាល់ រដ្ឋ-មន្ត្រីក្រសួងបរិស្ថាន** បានមានចំណាប់អារម្មណ៍អំពីសមិទ្ធផលដែលក្រសួងសម្រេចបានក្នុងការគ្រប់គ្រង និងការពារធនធានធម្មជាតិកន្លងមក ក្នុងនោះមានការសម្របសម្រួល និងដោះស្រាយបញ្ហាជម្លោះដីសម្បទានដែលកើតឡើងរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋជាដើម។ ពាក់ព័ន្ធការងារនេះក្រសួងបានបង្កើតគណៈកម្មការមួយដើម្បីពិនិត្យមើលឡើងវិញនូវការអនុវត្តតាមលក្ខខណ្ឌនានានៃការផ្តល់ដីសម្បទាន និងបានសម្រេចលុបចោលនូវកិច្ចសន្យាផ្តល់ដីសម្បទានបានជាបន្តបន្ទាប់ និងបានសម្រប-សម្រួលការចុះបញ្ជីដីធ្លីនៅទូទាំងប្រទេស ដោយបានកំណត់តំបន់សម្រាប់លំនៅដ្ឋាន សេដ្ឋកិច្ចសង្គមកិច្ច និងតំបន់សម្រាប់ជនជាតិដើមភាគតិចជាដើម ជាពិសេស ក្រសួងបានកាត់បន្ថយថេរវេលានៃការផ្តល់ដីសម្បទានមកត្រឹម៥០ឆ្នាំ។ ជាមួយនេះ ក្រសួងបានបិទច្រក និងលុបបំបាត់ការនាំឈើ

ចេញ ពិសេសការនាំចេញទៅប្រទេសវៀតណាម ហើយ រដ្ឋាភិបាលនៃប្រទេសវៀតណាមក៏បាន សហការអនុវត្ត ដោយមិនអនុញ្ញាតឱ្យនាំឈើចូល ឬកាប់ឈើ ឬកែច្នៃឈើនៅក្នុងទឹកដីនៃប្រទេសវៀត-



*ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន*

ណាមផងដែរ។ ចំពោះតំបន់ព្រៃឡង់ ក្រសួងបាន សម្រេចរៀបចំតំបន់ព្រៃឡង់នេះ ឱ្យក្លាយជាតំបន់ ការពារធនធានធម្មជាតិ ស្របតាមការសម្រេច របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងវេទិកាស្តីពីការអភិរក្ស និងការការពារធនធានធម្មជាតិ និងបានជ្រើសរើសឧទ្យានុរក្សចំនួនប្រមាណ៣០០នាក់ បន្ថែមទៀត។

ទន្ទឹមនេះ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានកត់សម្គាល់ នូវបញ្ហាប្រឈមមួយចំនួនមានដូចជា ការកាប់ ព្រៃឈើដើម្បីទន្ទ្រានយកដីនៅតែបន្ត ការទប់ស្កាត់ ការកាប់ព្រៃឈើរបស់ប្រជាពលរដ្ឋជាលក្ខណៈគ្រួសារ តាមតម្រូវការរបស់ប្រជាពលរដ្ឋមានការលំបាក ការ ចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងការកាប់ឈើ ការ ចរាចរឈើ ផលនេសាទ និងការប្រើប្រាស់ធនធាន ធម្មជាតិនានាដោយអ្នកពាក់ព័ន្ធនានា ដែលការ ចេញលិខិតទាំងនោះមិនត្រឹមត្រូវតាមក្របខ័ណ្ឌច្បាប់ និងពិបាកក្នុងការចាត់វិធានការទប់ស្កាត់ ដោយនៅ មានករណីនាំចេញឈើខុសច្បាប់តាមច្រករបៀង មួយចំនួន។ល។

**ឯកឧត្តមរដ្ឋមន្ត្រី** បានបន្ថែមទៀតថា សារាចរ ណែនាំលេខ០៥នេះ នឹងចូលរួមចំណែកដល់ការ ដោះស្រាយបញ្ហានានា ដែលកំពុងជួបប្រទះកាន់តែមានប្រសិទ្ធភាព ដូចជាបញ្ហាជម្លោះដីធ្លី ការគ្រប់គ្រង តំបន់ការពារធនធានធម្មជាតិ ការ លុបបំបាត់ការកាប់ឈើជាដើម ដោយរាជរដ្ឋាភិបាល បានប្រគល់ អំណាចឱ្យរដ្ឋបាលខេត្ត ដើម្បី គ្រប់គ្រង និងការពារធនធានធម្ម-ជាតិ ដូច្នេះរដ្ឋបាលខេត្តត្រូវរួមគ្នាការពារ និងគ្រប់-គ្រងធនធានធម្មជាតិដែលមានក្នុងដែនដីរបស់ខ្លួន ដោយមានមន្ទីរ អង្គភាពនានា ជាសេនាធិការ។

ក្នុងអង្គពិធីនោះដែរ **ឯកឧត្តម ហាស់ សារ៉េត រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** តំណាងឱ្យ**ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានមាន ចំណាប់អារម្មណ៍ពាក់ព័ន្ធនឹងសមិទ្ធផលនៅក្នុងការ គ្រប់គ្រង និងការពារធនធានធម្មជាតិ(ព្រៃឈើ និង ផលផល) ដោយផ្តោតលើចំណុចសំខាន់ៗមួយចំនួន ដូចជា ក្រសួងបានផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើទាំងអស់ឱ្យស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ក្រសួងបរិស្ថាន ក្រសួងបានបង្កើត គណៈកម្មការមួយដើម្បីគ្រប់គ្រង និងទប់ស្កាត់ការ ធ្វើចរាចរឈើ ដែលជាលទ្ធផលនៅ៩ខែ ដើមឆ្នាំ ២០១៦នេះ បទល្មើសព្រៃឈើបានថយចុះ បើធៀប ជាមួយឆ្នាំកន្លងទៅ។ ជាមួយនេះ ក្រសួងបានកែ សម្រួលរចនាសម្ព័ន្ធមន្ទីរកសិកម្ម មកជាមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបានដាក់

បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលមកស្ថិតនៅក្រោមរចនាសម្ព័ន្ធមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទន្ទឹមនេះដើម្បីគ្រប់គ្រងផលនេសាទប្រកបដោយនិរន្តរភាព សហគមន៍នេសាទចំនួន៥១៦ ត្រូវបានបង្កើត និងចំនួន៣៩៤ បានទទួលស្គាល់ពីក្រសួងចាប់តាំងពីឆ្នាំ២០០០មក ហើយបានរៀបចំឱ្យមានការអភិរក្សមេពូជ ដោយបង្កើតឱ្យមានអន្លង់មេពូជជាច្រើនកន្លែងទាំងនៅតំបន់ទឹកសាប និងនៅតំបន់សមុទ្រ។

ជាមួយនេះ **ឯកឧត្តម រដ្ឋលេខាធិការ** ក៏បានលើកឡើងអំពីបញ្ហាប្រឈមមួយចំនួនដូចជា បទល្មើសព្រៃឈើ និងបទល្មើសនេសាទនៅតែកើតមានជាបន្តបន្ទាប់ ហើយនៅពេលមានបទល្មើសកើតឡើង អាជ្ញាធរមានសមត្ថកិច្ចតែងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីចាត់វិធានការទប់ស្កាត់ និងអន្តរាគមន៍។ ប៉ុន្តែនៅមានករណីមួយចំនួនជនល្មើសមិនខ្លាចរអានឹងវិធានការនានាដែលបានអនុវត្តឡើយ ហើយការកាប់ព្រៃលិចទឹក ការបង្ហូរជាតិពុល និងសារធាតុគីមីទៅក្នុងទឹក ការបំពុលទឹក និងត្រីនៅតែមានជាបន្តបន្ទាប់ជាដើម។

**ឯកឧត្តម ហាស់ សារ៉េត** បានបន្ថែមដោយលើកឡើងថា ក្នុងការអនុវត្តកន្លងមក ក្របខ័ណ្ឌច្បាប់ បានប្រគល់សិទ្ធិផ្តាច់មុខឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខ្សែបណ្តោយរបស់ខ្លួន ដើម្បីគ្រប់-គ្រងធនធានព្រៃឈើ និងជលផល ដោយមិនបានកំណត់អំពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានច្បាស់លាស់ ហើយនៅពេលមានបញ្ហាបទល្មើសនានាកើតឡើង អ្នកពាក់ព័ន្ធតែងតែឆ្លើយដាក់គ្នា។ ដូច្នេះ តាមរយៈសារាចរនេះ អំណាចនៃការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានប្រគល់ឱ្យរដ្ឋបាលខេត្ត ហើយត្រូវពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធឱ្យបានសមស្រប និងត្រូវពិនិត្យ និងធ្វើវិសោធន-កម្មច្បាប់ព្រៃឈើ និងច្បាប់ជលផល ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាចពេញលេញក្នុង



*ឯកឧត្តម ហាស់ សារ៉េត រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ការអនុវត្ត។

នៅក្នុងឱកាសនោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានលើកឡើងអំពីបញ្ហាប្រឈម និងទស្សនវិស័យក្នុងកំណែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ និងបានផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់អំពីខ្លឹមសារ និងវិធានការនានា ដើម្បីអនុវត្តសារាចរនេះ ឱ្យមានប្រសិទ្ធភាព។ សម្តេចបានលើកឡើងថា បញ្ហាប្រឈមរបស់យើងគឺធនធានធម្មជាតិដែលនៅសេសសល់កំពុងរងសម្ពាធពីការបំផ្លិចបំផ្លាញតាមគ្រប់រូបភាពពីសំណាក់ឈ្មួញទុច្ចរិត ហើយការការពារហាក់ដូចជាគ្មានប្រសិទ្ធភាពពីព្រោះច្បាប់បច្ចុប្បន្ន បានរៀបចំឡើងក្នុងពេលដែលប្រទេសយើងអនុវត្តប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការដោយផ្តល់សិទ្ធិផ្តាច់មុខទៅឱ្យក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានក្នុងការ

គ្រប់គ្រង អភិវឌ្ឍ និងអភិរក្សព្រៃឈើ ផលផល និងតំបន់ការពារធម្មជាតិ តាមរយៈអង្គភាពខ្សែបណ្ដោយរបស់ខ្លួន រួមមានដូចជា រដ្ឋបាលព្រៃឈើ រដ្ឋបាលផលផល និងរដ្ឋបាលតំបន់ការពារ និងអភិរក្សធម្មជាតិជាដើម។ ជាក់ស្ដែងច្បាប់នេះពុំបានផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀតឡើយ។ ច្បាប់បានផ្ដល់នាទីត្រឹមតែការផ្ដល់កិច្ចសហការទៅតាមការស្នើសុំរបស់រដ្ឋបាលព្រៃឈើ រដ្ឋបាលផលផល និងរដ្ឋបាលតំបន់ការពារ និងអភិរក្សធម្មជាតិប៉ុណ្ណោះ។ ការមិនបានផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ច បានធ្វើឱ្យវិធានការទប់ស្កាត់បទល្មើសព្រៃឈើ ផលផល និងការបំផ្លាញតំបន់ការពារធម្មជាតិគ្មានប្រសិទ្ធភាព ហើយតែងតែឆ្លើយឆ្លងទឹកដាក់គ្នារវាងរដ្ឋបាលព្រៃឈើ រដ្ឋបាលផលផល រដ្ឋបាលតំបន់ការពារ និងអភិរក្សធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ដោយមើលឃើញដូចនេះ ទើបទាមទារឱ្យរាជរដ្ឋាភិបាល សិក្សាពិនិត្យឡើងវិញក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងវិធានការនានាដែលអនុវត្តកន្លងមក សំដៅដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងវិធានការដែលមានលក្ខណៈសមស្រប ឆ្លើយតបតាមការវិវត្តប្រែប្រួលរបស់សង្គមសេដ្ឋកិច្ច និងគោលនយោបាយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើកំណែទម្រង់លើការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសលើការគ្រប់គ្រងព្រៃឈើ ផលផល និងតំបន់ការពារធម្មជាតិ ដោយបាន និងកំពុងធ្វើវិសោធនកម្មច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីផលផល និងច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ។ ការធ្វើវិសោធនកម្មច្បាប់ និងការកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធនានា ដើម្បីបែងចែកឡើងវិញនូវសមត្ថកិច្ចរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្ដល់សិទ្ធិអំណាចឱ្យបានច្បាស់លាស់ និងធនធានសមស្រប ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ផ្អែកតាមទស្សនវិស័យនៃកំណែទម្រង់នេះ ថ្នាក់ជាតិគឺជាអ្នករៀបចំគោលនយោបាយ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអ្នកអនុវត្តគោលនយោបាយទាំងនោះ។ តែទោះជាយ៉ាងនេះក្ដី ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិនៅតែជាស្ថាប័នដែលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាក្នុងវិស័យព្រៃឈើ ផលផល និងតំបន់



*ពិធីផ្សព្វផ្សាយសារាចរណែនាំស្ដីពីការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ*

ការពារធម្មជាតិ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជាស្ថាប័ន ដែលត្រូវមានគណនេយ្យភាពចំពោះក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិក្នុងការអនុវត្តគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងបទដ្ឋានបច្ចេកទេសសម្រាប់ការគ្រប់គ្រងការថែរក្សាការពារ ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិដែលបានកំណត់ និងត្រូវមានគណនេយ្យ-ភាពចំពោះប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។ ជាមួយគ្នានោះដែរ ដើម្បីងាយស្រួលគ្រប់គ្រង និងថែរក្សាការពារ រាជរដ្ឋាភិបាលកម្ពុជា បានបែងចែកសមត្ថកិច្ចរវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិក្នុងការ



*ពិធីផ្សព្វផ្សាយសារាចរណែនាំស្តីពីការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ*

ទទួលខុសត្រូវ ដោយបានសម្រេចផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើទាំងអស់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីទាំងអស់ ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងបានដាក់បញ្ចូលតំបន់ព្រៃឈើមួយចំនួនឱ្យក្លាយជាតំបន់ការពារធម្មជាតិផងដែរ។

**សម្តេចក្រឡាហោម ស ខេង** បានសង្កត់ធ្ងន់ថា ដើម្បីជាវិធានការបន្ទាន់ចាំបាច់ចំពោះមុខក្នុងអំឡុងពេលកំពុងសិក្សាធ្វើវិសោធនកម្មច្បាប់ ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្ម-ជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរណែនាំលេខ០៥នេះ ដោយផ្តោតលើវិធានការចាំបាច់ចំពោះមុខចំនួន៩ចំណុច ដូចខាងក្រោម៖

ទីមួយ-អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈគណៈបញ្ជាការឯកភាព នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ សម្របសម្រួលកម្លាំងអធិការខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកងកម្លាំងមានសមត្ថកិច្ចនានា ឱ្យអនុវត្តបានត្រឹមត្រូវនូវតួនាទីរបស់ខ្លួន។

ទីពីរ-អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កលទ្ធ-ភាព និងលើកទឹកចិត្តឱ្យសហ-គមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាចូលរួមទប់ស្កាត់ និងលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទីបី-ប្រគល់សមត្ថកិច្ចដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ និងហ្មត់ចត់ចំពោះរាល់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងជលផល។ ត្រួតពិនិត្យនិងចាត់វិធានការលុបបំបាត់ការដឹកជញ្ជូន និងការស្តុកឈើគ្រប់ប្រភេទដែលគ្មានច្បាប់អនុញ្ញាត។ ចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំឈើ និងផលិត-

ផលកែច្នៃពីឈើគ្រប់ប្រភេទ ព្រមទាំងសត្វព្រៃដែលគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវទៅក្រៅប្រទេស។

ទីបួន-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានរដ្ឋបាលព្រៃឈើជាសេនាធិការ ត្រូវត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់នូវការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល និងអនុផលព្រៃឈើគ្រប់ប្រភេទ។

ទីប្រាំ-ក្រសួងបរិស្ថាន ដោយមានអគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការត្រូវពង្រឹងយន្តការ និងផ្តល់កម្លាំងគាំទ្រដល់គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ។

ទីប្រាំមួយ-រាល់អន្តរាគមន៍របស់អង្គភាព ឬបុគ្គលដែលគ្មានសមត្ថកិច្ចលើការដឹកជញ្ជូនផល និងអនុផលព្រៃឈើ ត្រូវហាមឃាត់ជាដាច់ខាត ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

ទីប្រាំពីរ-ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការ និងគាំទ្រគណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តវិធានការនេះ។

ទីប្រាំបី-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចស្នើសុំកម្លាំងអន្តរាគមន៍ជាបន្ទាន់មកមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីចាំបាច់។

ទីប្រាំបួន-រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារគ្រប់គ្រងធនធានធម្មជាតិរៀងរាល់ត្រីមាស ឬអាចកោះប្រជុំតាមការចាំបាច់។

ជារួម វិធានការក្នុងសារាចរណែនាំនេះ ភាគច្រើនបានប្រគល់ការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្ត។ ហេតុនេះ រាជធានី ខេត្ត ក្រុង ស្រុកណាដែលមានបទល្មើសព្រៃឈើ បទល្មើសនេសាទ និងការបំផ្លិចបំផ្លាញធនធានធម្មជាតិ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក នោះត្រូវមានការទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល។ តែមិនមានន័យថា ក្រសួង ស្ថាប័នថ្នាក់ជាតិទម្លាក់ការទទួលខុសត្រូវទាំងអស់ទៅឱ្យរដ្ឋបាលថ្នាក់-ក្រោមជាតិនោះឡើយ។ ដូចដែលបានបញ្ជាក់រួចហើយ ក្រសួង ស្ថាប័នថ្នាក់ជាតិនៅតែទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល និងរដ្ឋសភា ហើយវិធានការនេះមានគោលបំណងលើកកម្ពស់កិច្ចសហការ ការគាំទ្រ និងការទទួលខុសត្រូវរួមគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអ្នកពាក់-ព័ន្ធនានា។

ជាចុងក្រោយ ដើម្បីធានាដល់ការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព **សម្តេចក្រឡាហោម** បានផ្តល់នូវគោលការណ៍ណែនាំមួយចំនួន ដល់ក្រសួង ស្ថាប័ន អាជ្ញាធររាជធានី ខេត្ត និងអង្គភាពមានសមត្ថកិច្ចទាំងអស់ ត្រូវរៀបចំផ្សព្វផ្សាយសារាចរណែនាំនេះឱ្យបានទូលំទូលាយ ដល់មន្ត្រីក្រោមឱវាទរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធនានាសំដៅរួមគ្នាសហការអនុវត្ត ដើម្បីធានាដល់ការពង្រឹងការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ជាមួយនេះ **សម្តេច**

**គ្រួឡាះមោម** ក៏បានស្នើឱ្យលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) និងក្រសួងមហាផ្ទៃ សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក្នុងការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីផលផល និងច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិឱ្យបានឆាប់ ដើម្បីដាក់ឱ្យមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាមុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចតាមនីតិវិធីជាធរមាន៕

*ដោយៈ ឿន ស្រ៊ន់*

# សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)




*សម្តេចក្រឡាហោម ស ខេង ចូលរួមបិទសិក្ខាសាលាផ.ស.ថ២០១៧*

“កិច្ចខិតខំប្រឹងប្រែងរួមរបស់យើងទាំងអស់គ្នា ក្នុងការគាំទ្រ និងចូលរួមរៀបចំ និងអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី១ និងផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី២ តាមរយៈផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប នាពេលកន្លងមកបានជំរុញឱ្យកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់-ក្រោមជាតិ មានការវិវត្តជឿនលឿនទៅមុខ ដោយបង្កើតបាននូវសមិទ្ធផលជាប្រវត្តិសាស្ត្រធំៗជាច្រើនពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។” **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** បានគូសបញ្ជាក់យ៉ាងដូច្នេះនៅក្នុងឱកាសអញ្ជើញជាអធិបតីនៃពិធីបិទសិក្ខាសាលាស្តីពី “ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ គ.ជ.អ.ប” កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានរៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៧ (ផ.ស.ថ២០១៧)ដោយមានអ្នកចូលរួមប្រមាណជាង៥០០នាក់មកពីក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ។ សិក្ខាសាលានេះមានគោល-បំណងពិនិត្យ ពិភាក្សាអំពីលទ្ធផលរំពឹងទុកសម្រាប់ផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៧ ក៏ដូចជាដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា

ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ ព្រមទាំងពិនិត្យ ពិភាក្សាលើសេចក្តីព្រាងលទ្ធផលរំពឹងទុក និងចំណុចដៅជាអាទិភាព នៃ ផ.ស.ថ ឆ្នាំ ២០១៧ របស់គ.ជ.អ.ប ការវិភាជមូលនិធិពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍសម្រាប់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៧។ ផ.ស.ថ ឆ្នាំ ២០១៧ បានកំណត់លទ្ធផលរំពឹងទុកចំនួនប្រមាណ ៣៦ ដោយគ្រោងថវិកាប្រមាណ៤៣៨លានដុល្លារ ដែលក្នុងនោះមានថវិការដ្ឋចំនួនប្រមាណ៣៩៦លានដុល្លារ និងថវិកាចូលរួមចំណែកពីដៃគូអភិវឌ្ឍចំនួន ៤២លានដុល្លារ។ បើប្រៀបធៀបនឹងឆ្នាំ២០១៦ ថវិការដ្ឋដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១៧ មានចំនួនកើនឡើងប្រមាណជិត ៧០លានដុល្លារ។ កំណើននេះគឺដោយសារកំណើនសេដ្ឋកិច្ចជាតិ និងការបង្កើតឱ្យមាននូវប្រភពចំណូលផ្សេងៗទៀតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

បន្ទាប់ពីបទបង្ហាញសេចក្តីព្រាង ផ.ស.ថ ឆ្នាំ២០១៧ សិក្ខាសាលាបានបែងចែកជាក្រុមដើម្បីពិភាក្សាលើប្រធានបទចំនួន០៦ មាន១) យុទ្ធសាស្ត្របន្ថយជំនួយបច្ចេកទេសគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោជាតិ ដើម្បីឈានទៅកការទទួលខុសត្រូវទាំងស្រុងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអភិវឌ្ឍសមត្ថភាព ២) យុទ្ធសាស្ត្រសម្រាប់ការបង្កើនការរ៉ាប់រងចំណាយរបស់រដ្ឋក្នុងការអនុវត្តកម្មវិធីកំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៣)បញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តន៍ដោយរដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារដែលបានផ្ទេរឱ្យ ដូចជា មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការគ្រប់គ្រង ការថែរក្សាសុខុមាលភាពកុមារ ការគ្រប់គ្រងសហគមន៍តំបន់ការពារ។ល។ ៤)ការផ្ទេរធនធានពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគម្រោងមូលនិធិ ក្រុង ស្រុក ៥)យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង៦)យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

បន្ទាប់ពីបទបង្ហាញលទ្ធផលនៃកិច្ចពិភាក្សានៅក្នុងឱកាសថ្លែងសុន្ទរកថាបិទសិក្ខាសាលា **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី**




ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី អុន ព័ន្ធមុនីរ័ត្ន អញ្ជើញជាអធិបតីបើកសិក្ខាសាលាជាតិ ផ.ស.ថ២០១៧

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** បានគូសបញ្ជាក់អំពីលទ្ធផលនៃការសិក្សាវាយតម្លៃពាក់កណ្ដាលអាណត្តិនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានរៀបចំឡើងដោយទីប្រឹក្សាឯករាជ្យមួយក្រុមដោយមានការគាំទ្រពីសហភាពអឺរ៉ុប នៅក្នុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៦ កន្លងមកនេះបានបង្ហាញឱ្យឃើញថា


ទិដ្ឋភាពអ្នកចូលរួមសិក្ខាសាលាជាតិ ៨.ស.ថ២០១៧

ការអនុវត្តកម្មវិធីជាតិអស់រយៈពេលជាង៥ឆ្នាំកន្លងមកនេះបាន និងកំពុងធ្វើឱ្យមានការផ្លាស់ប្ដូរជាវិជ្ជមាននៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិស្របតាមទស្សនៈវិស័យ និងគោលដៅនានាដែលកំណត់ក្នុងច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទន្ទឹមគ្នានេះដែរ ទីប្រឹក្សាវាយតម្លៃក៏បានកត់សម្គាល់ផងដែរអំពីការរីកចម្រើននៃទំនាក់ទំនង និងកិច្ចសហការកាន់តែស៊ីសង្វាក់គ្នារវាងកម្មវិធីកំណែទម្រង់សំខាន់ៗទាំង៣របស់រាជរដ្ឋាភិបាល គឺកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈនិងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ **សម្ដេច** ក៏បានសង្កត់ធ្ងន់អំពីភាពចាំបាច់នៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធានាឱ្យបាននូវជោគជ័យនៃកំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ **សម្ដេច** បានលើកឡើងថាក្នុងអំឡុងពេលនៃការអនុវត្តផអ៣ទី១ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ ២០១៤ មានតែក្រសួងមួយចំនួនតូចប៉ុណ្ណោះដែលបានផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ប៉ុន្តែមុខងារដែលបានផ្ទេរទាំងនោះភាគច្រើន គឺជាការផ្ទេរនូវមុខងារតូចៗ ហើយក្នុងលក្ខណៈជាការអនុវត្តសាកល្បង និងក្នុងបែបផែនជាការធ្វើប្រតិភូកម្មទៅឱ្យថ្នាក់រដ្ឋបាលគោលដៅមួយចំនួននៅថ្នាក់ក្រោមជាតិ គឺពុំមែនជាការផ្ទេរមុខងារតាមបែបផែននៃការប្រគល់ការទទួលខុសត្រូវដោយភ្ជាប់ជាមួយនឹងធនធានជាក់លាក់ និងភាពជាម្ចាស់ច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ ក្នុងការអនុវត្តផអ៣ទី២រយៈពេលជិត២ឆ្នាំកន្លងមកនេះ បើទោះបីជាក្រសួង ស្ថាប័ន ក្នុងវិស័យអាទិភាពមួយចំនួនបានខិតខំជំរុញកិច្ចដំណើរការផ្ទេរមុខងារនេះក៏ដោយ ក៏លទ្ធផលជាក់ស្ដែងនៅពុំទាន់សម្រេចបានតាមការរំពឹងទុកដូចដែលបានឯកភាពគ្នាឡើយ។ ម្យ៉ាងវិញទៀតទោះបីក្រសួង ស្ថាប័នមួយចំនួនបានកំណត់មុខងារសម្រាប់ផ្ទេរទៅឱ្យរដ្ឋ-



ទិដ្ឋភាពអ្នកចូលរួមសិក្ខាសាលាជាតិ ឆ.ស.២០១៧

បាលថ្នាក់ក្រោមជាតិរួចហើយក៏ដោយ ក៏នៅពុំទាន់អនុវត្តបានពេញលេញតាមគោលការណ៍នៃការផ្ទេរមុខងារនៅឡើយ ដោយសារមិនទាន់មានការរៀបចំប្រព័ន្ធ និងនីតិវិធីសម្រាប់គាំទ្រដល់ការអនុវត្តមុខងារទាំងនោះ រួមមានដូចជា ការផ្ទេរធនធានហិរញ្ញវត្ថុ ការផ្ទេរធនធានមនុស្ស និងទ្រព្យសម្បត្តិ ការកំណត់ស្តង់ដា ឬបទដ្ឋានបច្ចេកទេស និងការផ្តល់អន្តរាគមន៍គាំទ្រនានាជាដើម។

ជាមួយគ្នានេះ **សម្តេច** ក៏បានជំរុញឱ្យមានការធ្វើវិមជ្ឈការហិរញ្ញវត្ថុឱ្យបានសមស្របផងដែរ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រភពធនធានហិរញ្ញវត្ថុរួមទាំង មានប្រព័ន្ធ មាននីតិវិធី និងមានសមត្ថភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ពាក់ព័ន្ធនឹងការងារនេះ **សម្តេចក្រឡាហោម** ឯកភាពទាំងស្រុងទៅលើផែនការសកម្មភាពសំខាន់ៗដែលអង្គសិក្ខាសាលាបានលើកឡើងពាក់ព័ន្ធនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់និងការបង្កើនមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ការអនុវត្តយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ(SNIF) និងការបង្កើនប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ដោយឡែកពាក់ព័ន្ធការអភិវឌ្ឍស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ **សម្តេច** បានជំរុញឱ្យយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាបន្ថែមទៀតក្នុងកិច្ចសហការជាមួយក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធនានាដើម្បីពង្រឹងការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋានផង។

ជាចុងក្រោយ **សម្តេចក្រឡាហោម** បានគូសបញ្ជាក់អំពីការតាំងចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំនះនូវរាល់ភាពសាំញ៉ាំ និងស្មុគស្មាញនៃកំណែទម្រង់វិមជ្ឈការ ដែលជាកំណែទម្រង់មានផលប៉ះពាល់ទាំងផ្នែកនយោបាយ និងផ្នែករដ្ឋបាលរបស់ស្ថាប័នទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលទាមទារឱ្យរាជរដ្ឋាភិបាលត្រូវអនុវត្តដោយប្រុងប្រយ័ត្ន មានការសម្របសម្រួល និងប្រកបដោយសនិទានភាព ផ្អែកលើបរិបទប្រវត្តិសាស្ត្រនយោបាយសង្គម សេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា។ ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានអំពាវនាវឱ្យដៃគូអភិវឌ្ឍនានាបន្តការគាំទ្របន្តទៀត ដើម្បីឈានឆ្ពោះទៅសម្រេចគោលបំណងចុងក្រោយនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

*ដោយ ហេង ច័ន្ទសុភារិទ្ធ*

# សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអភិវឌ្ឍស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ




*គណៈអធិបតីចូលរួមអង្គសិក្ខាសាលា*

កាលពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១៦ នាយកដ្ឋានបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអភិវឌ្ឍស្ថាប័ន នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារពមកា ខេត្តកំពង់ចាម ដោយមានអ្នកចូលរួមសរុបចំនួន៨៥នាក់ ស្រី១៨នាក់ ក្នុងនោះរួមមាន ប្រធានមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានីខេត្ត ទីប្រឹក្សាគ្រប់គ្រង និងអនុវត្ត ផ.អ.៣ ទី២ ទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាព និងមន្ត្រីទីចាត់ការគ្រប់គ្រងធនធានមនុស្សទាំង២៥រាជធានីខេត្ត។ សិក្ខាសាលាឆ្លុះបញ្ចាំងនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យ ពិភាក្សាអំពីលទ្ធផល បញ្ហាប្រឈម និងអនុសាសន៍កែលម្អពាក់ព័ន្ធនឹងការអភិវឌ្ឍស្ថាប័ននៅថ្នាក់ក្រោមជាតិក្នុងរយៈពេលកន្លងមក រួមទាំងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត។ អង្គសិក្ខាសាលាមានកិត្តិយសដោយបានការអញ្ជើញចូលរួមជាអធិបតីពីសំណាក់ **ឯកឧត្តម ប្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។ ថ្លែងក្នុងពិធីបើកសិក្ខាសាលា ឯកឧត្តមបានមានប្រសាសន៍ថា ការអភិវឌ្ឍស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការចាំបាច់និងចម្បងបំផុតដែលរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ឱ្យបានល្អប្រសើរ ដើម្បីធានាឱ្យរដ្ឋបាលរបស់ខ្លួននីមួយៗមានប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាព សមស្របទៅតាមតម្រូវការនៅអង្គភាពនីមួយៗ សំដៅលើកកម្ពស់ការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យមានប្រសិទ្ធភាពខ្ពស់ មានលក្ខណៈឆ្លើយតប សមធម៌ និងបរិយាប័ន្ន ដើម្បីរួមចំណែកអនុវត្តឱ្យបានជោគជ័យនូវទិសដៅជាយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។

សិក្ខាសាលាឆ្លុះបញ្ចាំងនេះ ផ្តោតលើរបៀបវារៈ



*ទិដ្ឋភាពអ្នកចូលរួមអង្គសិក្ខាសាលា*

ចំនួនពីរួមមាន ការបង្ហាញអំពីលទ្ធផលដែលក្រុមការងារនៃនាយកដ្ឋានបណ្តុះបណ្តាលបានរកឃើញក្នុងការចុះតាមដានត្រួតពិនិត្យការអនុវត្តការងាររបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ក៏ដូចជាវឌ្ឍនភាពនៃការអភិវឌ្ឍស្ថាប័ននៅថ្នាក់ក្រោមជាតិ បន្ទាប់មកមានកិច្ចពិភាក្សាដោយសិក្ខាកាម ដើម្បីពិនិត្យពិភាក្សាទៅលើបញ្ហាប្រឈម និងអនុសាសន៍សម្រាប់កែលម្អការអនុវត្តការងាររបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត និងការអភិវឌ្ឍស្ថាប័ននៅថ្នាក់ក្រោមជាតិ ។

លទ្ធផលនៃការចុះតាមដានដំណើរការរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត បានរកឃើញថា ការអនុវត្តតួនាទីរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត មានភាពល្អប្រសើរ ដោយស្ទើរតែគ្រប់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត បានបំពេញតួនាទីភារកិច្ចរបស់ខ្លួនសមស្រប មានទីកន្លែងធ្វើការសមរម្យ ព្រមទាំងមានការបំពាក់ប្រព័ន្ធឆ្លើយតបទាន់ហេតុការណ៍ និងមានការរៀបចំប្រព័ន្ធតម្កល់ឯកសារ បើទោះបីជាកិច្ចការទាំងនេះពុំទាន់មានប្រសិទ្ធភាពពេញលេញតាមការរំពឹងទុកយ៉ាងណាក៏ដោយ។ ជាមួយនេះ ក្រុមការងារក៏បានរកឃើញផងដែរនូវចំណុចត្រូវកែលម្អមួយចំនួនដូចជា ការពង្រឹងបន្ថែមលើការតាមដានត្រួតពិនិត្យ ដោយគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ការពង្រឹងសមត្ថភាពរបស់មន្ត្រីឱ្យចំទិសដៅ និងតម្រូវការព្រមទាំងការគាំទ្រទាំងផ្នែកសម្ភារ និងថវិកា។ ជាមួយនេះរដ្ឋបាលរាជធានី ខេត្ត ត្រូវពង្រឹងគុណភាពនៃកិច្ចអន្តរាគមន៍ការអភិវឌ្ឍសមត្ថភាព តាមរយៈការប្រើប្រាស់គោលវិធីផ្សេងៗ ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងការចែករំលែកបទពិសោធន៍ការងារល្អៗ។

ចំពោះដំណើរការនៃការអភិវឌ្ឍស្ថាប័នទាំង៥ជំហានដែលរួមមាន (១)ការតម្រង់ទិស (២)ការប៉ាន់ប្រមាណតម្រូវការ (៣)ការធ្វើផែនការ (៤)ការតាក់តែង និងការផ្តល់អន្តរាគមន៍ និង(៥)ការវាយតម្លៃលទ្ធផលអន្តរាគមន៍ ក្រុមការងារបានរកឃើញថា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុវត្តបានល្អសម្រាប់ជំហានទី១ ទី២ និងទី៣ ដោយសម្រេចបានពីចន្លោះ៨៤-១០០ភាគរយ។ ទន្ទឹមនេះ លទ្ធផលក៏បានបង្ហាញថា រដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ជាអាទិ៍ក្រុមប្រឹក្សាសកម្មជាងមុន បុគ្គលិកមានសមត្ថភាពអនុវត្តការងារមានប្រសិទ្ធភាពជាងមុន ការយកចិត្តទុកដាក់លើការដំឡើងតួនាទីជាពិសេសស្ត្រី និងការគ្រប់គ្រងបុគ្គលិកមានភាពល្អប្រសើជាងមុនជាដើម។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនៃការអភិវឌ្ឍស្ថាប័នក៏បានជួបប្រទះបញ្ហាមួយចំនួន ដូចជាក្នុងជំហានទី៤សម្រេចបានតែ៤៤ភាគរយ សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង៣៩ភាគរយ សម្រាប់រដ្ឋបាលរាជធានី ខេត្ត និង ជំហានទី៥ សម្រេចបានតែ២ភាគរយ សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង៥ភាគរយ សម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ក្នុងន័យនេះ សម្រាប់ជំហានទី៤ និងទី៥ រដ្ឋបាលរាជធានី ខេត្ត ក្រុង

ស្រុក និងខណ្ឌ មិនទាន់អនុវត្តបានល្អនៅឡើយទេ។ មានកត្តាមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការទាំងនេះ ក្នុងនោះរួមមានដូចជា៖

- ទីប្រឹក្សាមួយចំនួនត្រូវបានកាត់បន្ថយ និងមិនបានជ្រើសរើសបំពេញឡើងវិញ
- ទីប្រឹក្សាស្រុកផ្លាស់ប្តូរញឹកញាប់ និងមិនសូវមានបទពិសោធន៍ចំពោះការងារអភិវឌ្ឍន៍ស្ថាប័ន (OD)
- សមត្ថភាពរបស់អ្នកផ្តល់សេវា (គ្រូបង្គោល) នៅមានកម្រិតនៅឡើយ
- ការកំណត់ប្រធានបទក្នុងផែនការប្រចាំឆ្នាំច្រើនពេក និងពុំទាន់ឆ្លើយតបតម្រូវការជាក់ស្តែង
- ថ្នាក់ដឹកនាំមិនសូវចូលរួម និងគាំទ្រដល់ដំណើរការអភិវឌ្ឍស្ថាប័ន (OD)
- ការចាត់ទុកការងារអភិវឌ្ឍន៍ស្ថាប័ន (OD) ជាការងារមិនអាទិភាពជាដើម។



*កិច្ចពិភាក្សាជាក្រុមរបស់សិក្ខាកាម*

បន្ទាប់ពីការធ្វើបទបង្ហាញអំពីលទ្ធផលរកឃើញរបស់ក្រុមការងារ សិក្ខាកាមត្រូវបានបែងចែកជាក្រុមដើម្បីពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នា។

ឆ្លងតាមការពិភាក្សាយ៉ាងផុលផុស អង្គសិក្ខា-សាលាបានលើកឡើងនូវអនុសាសន៍មួយចំនួនក្នុងការជំរុញការអនុវត្តការងារអភិវឌ្ឍន៍ស្ថាប័ន និងការងារមណ្ឌលអភិវឌ្ឍន៍ធនធនមនុស្សរាជធានី ខេត្ត ដូចខាងក្រោម៖

- សម្រាប់ការអភិវឌ្ឍស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់លើការកែសម្រួលឧបករណ៍ប៉ាន់ប្រមាណតម្រូវការឡើងវិញ ដើម្បីឱ្យមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង រួមជាមួយការកៀរគរធនធានក្នុងការអនុវត្តការងារអភិវឌ្ឍន៍ស្ថាប័ន(OD) ដោយផ្តោតលើធនធានមនុស្ស សម្ភារ និងដៃគូយុទ្ធសាស្ត្រ តាមរយៈការពង្រឹងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការតាមដានត្រួតពិនិត្យដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន ព្រមទាំងការចុះបង្វឹកបន្ថែមក្រោយពេលផ្តល់កិច្ចអន្តរាគមន៍ ដើម្បី ជំរុញការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព។
- សម្រាប់ការអនុវត្តការងារមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលើកទឹកចិត្តដល់ការចូលរួមក្នុងការអភិវឌ្ឍសមត្ថភាព តាមរយៈការកំណត់ជាលក្ខខណ្ឌសម្រាប់ដំឡើងតួនាទី ក៏ដូចជាការបង្កើតប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមការបណ្តុះបណ្តាលពេញលេញ។ លើសពីនេះ ថ្នាក់ជាតិគួរតែមានការណែនាំជាផ្លូវការដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងការវិភាជន៍ថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាព និងគាំទ្រដំណើរការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត តាមរយៈការគាំទ្រការបំពាក់សម្ភារ និងមធ្យោបាយចាំបាច់ផ្សេងៗ។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពិចារណាលើ

ចំនួនក្រុមការងារបច្ចេកទេសឱ្យស្របតាមតម្រូវការនៃការអភិវឌ្ឍសមត្ថភាព ក៏ដូចជាការពិនិត្យឡើងវិញលើសមាសភាពរបស់លេខាធិការដ្ឋាន ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងការគាំទ្រដល់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដោយត្រូវជ្រើសរើសមន្ត្រីដែលមានសមត្ថភាព ឆន្ទៈ និងបំពាក់បំប៉នសមត្ថភាពរបស់អ្នកទាំងនោះបន្ថែមៗ

ជារួម សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការអភិវឌ្ឍស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះ បានផ្តល់ឱកាសឱ្យក្រសួងមហាផ្ទៃ ក៏ដូចរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការចែករំលែកព័ត៌មានអំពីលទ្ធផល បញ្ហាប្រឈមក្នុងការអនុវត្តការងារកន្លងមកនៅរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធការអភិវឌ្ឍស្ថាប័ន និងដំណើរការនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ព្រមទាំងលើកអនុសាសន៍ដើម្បីធ្វើការកែលម្អទៅថ្ងៃអនាគតខាងមុខៗ

*ដោយ លឹម ពុទ្ធារី*

# ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា

## --- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ---

(ភាគ ២)

### ៦. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

#### ក. ចរន្តនៃអភិបាលកិច្ចមូលដ្ឋាន

ការធ្វើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា ពុំមែនជាយុទ្ធសាស្ត្រ ឬជាមធ្យោបាយពិសេសដោយឡែក សម្រាប់តែនៅកម្ពុជានោះឡើយ។ ចាប់តាំងពីចុងទសវត្សទី៩០ វិមជ្ឈការបានក្លាយជាប្រធានបទ និងជាមធ្យោបាយដ៏មានប្រជាប្រិយភាពដែលត្រូវបានយកទៅអនុវត្តនៅក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតាមបណ្តាប្រទេសនានាជាច្រើននៅលើពិភពលោកគាប់ចាប់តាំងពីតំបន់អាស៊ី អឺរ៉ុប និងអាមេរិចជាដើម។



ទោះជាយ៉ាងនេះក្តី ប្រទេសនីមួយៗអនុវត្តវិមជ្ឈការដោយមានមូលហេតុផ្សេងៗគ្នា ផ្អែកទៅតាមកត្តានយោបាយ ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីជាដើម។ នៅអឺរ៉ុបខាងកើត និងអតីត សហភាពសូវៀត វិមជ្ឈការគឺជាផ្នែកមួយនៃការផ្លាស់ប្តូរ នយោបាយ និងសេដ្ឋកិច្ច ដែលកើតឡើងបន្ទាប់ពី ការដួល រលំនៃការគ្រប់គ្រងតាមបែបមជ្ឈការយ៉ាងតឹងរ៉ឹងរបស់សហភាពសូវៀត។ នៅអាហ្វ្រិចខាងត្បូង និងស្រីលង្កា វិមជ្ឈការ គឺជាយុទ្ធសាស្ត្រដើម្បីបន្ធូរបន្ថយបញ្ហាខ្វែងគំនិតគ្នា ក៏ដូចជាជម្លោះក្នុងចំណោមជនជាតិ ឬតំបន់។ យុទ្ធសាស្ត្រនេះក៏ត្រូវបានអនុវត្តនៅឥណ្ឌូនេស៊ី ដោយសារឥណ្ឌូនេស៊ីជាប្រទេសពោរពេញទៅដោយប្រជុំកោះ មានទំហំធំ ប្រជាពលរដ្ឋច្រើន និងសម្បូរទៅដោយជនជាតិផ្សេងៗ។

ក្រៅពីមូលហេតុខាងលើ ជាទូទៅ វិមជ្ឈការត្រូវបានគេមើលឃើញថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាភាពក្រីក្រ វិសមភាពយេនឌ័រ បញ្ហាបរិស្ថាន និងការលើកកម្ពស់ការថែទាំសុខភាព អប់រំ និងការទទួលបានបច្ចេកវិទ្យា។ ទន្ទឹមនេះ វិមជ្ឈការមិនត្រឹមតែជះឥទ្ធិពលដល់រដ្ឋាភិបាល និងការផ្តល់សេវាទេ ប៉ុន្តែថែមទាំងជាល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទាក់ទាញអង្គការសហគមន៍ ក្នុងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធក្នុងដំណើរការគ្រប់គ្រងរដ្ឋបាលសាធារណៈទៀតផង ។

#### ខ. វិមជ្ឈការជាអ្វី ?

ក្នុងក្របខ័ណ្ឌទូទៅ វិមជ្ឈការ ត្រូវបានគេឱ្យនិយមន័យថា ជាដំណើរការមួយដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈ ត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្តាល ទៅឱ្យរដ្ឋាភិបាលមូលដ្ឋាន សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។ វិមជ្ឈការមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងគោលគំនិតស្តីពី "Subsidiarity" ដែលគោលគំនិតនេះបានកំណត់ថា "រាល់មុខងារត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ទាបបំផុតណាដែលមានសមត្ថភាព

អាចបំពេញមុខងារនោះបាន"។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) បានឱ្យនិយមន័យនៃ "អភិបាលកិច្ចតាមបែបវិមជ្ឈការ" ថា "ជាការរៀបចំឡើងវិញនូវសមត្ថកិច្ចដើម្បីឱ្យមានប្រព័ន្ធមួយដែលមានការសហការទទួលខុសត្រូវ រវាងស្ថាប័នអភិបាលកិច្ចនៅថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ដោយឈរលើគោលការណ៍នៃ Subsidiarity ដែលកត្តានេះនឹងនាំមកនូវការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ច ដើរទន្ទឹមនឹងការកើនឡើងនូវសិទ្ធិអំណាច និងលទ្ធភាពនៅថ្នាក់ក្រោមជាតិ"។

### គ. អត្ថន័យនៃវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

នៅកម្ពុជា គោលបំណងជាយុទ្ធសាស្ត្រនៅក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានកំណត់នៅក្នុង ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចខាងក្រោម៖

- ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និង
- ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

ទន្ទឹមនេះ ក្នុងបរិបទរបស់ប្រទេសកម្ពុជា ពាក្យ "វិមជ្ឈការ" និង "វិសហមជ្ឈការ" ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

វិមជ្ឈការ គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។ ក្នុងន័យនេះ រាល់កិច្ចការនានាដែលបានផ្ទេរវិមជ្ឈការទៅឱ្យក្រុមប្រឹក្សាៗ មានឆន្ទានុសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។

វិសហមជ្ឈការ គឺជាការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នផ្ទេរប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអនុវត្តកិច្ចការទាំងនោះតាមការណែនាំ ឬចង្អុលបង្ហាញពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ហើយការទទួលខុសត្រូវចុងក្រោយចំពោះការអនុវត្តកិច្ចការទាំងនេះនៅតែជារបស់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មដដែល។

ការរៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាសម្រាប់គាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា គឺរៀបចំឡើងក្នុងស្មារតីនៃ "វិមជ្ឈការ" និង "វិសហមជ្ឈការ" ដូចបានកំណត់ខាងលើនេះ។

## II. ក្របខ័ណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាត្រូវបានផ្តួចផ្តើម និងយកចិត្តទុកដាក់តាំងពីក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣ និងត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗចាប់ពីអាណត្តិទី២នៃនិតិកាលរដ្ឋសភាជាបន្តបន្ទាប់។ រាជរដ្ឋាភិបាលបានអនុវត្តកំណែទម្រង់នេះដោយមានការប្រុងប្រយ័ត្នខ្ពស់ និងធ្វើឡើងជាជំហានៗ តាមរយៈការធ្វើបណ្តើរដកបទពិសោធន៍បណ្តើរ និងពង្រឹងពង្រីកបណ្តើរ។ នៅក្នុងឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្តកំណែទម្រង់នេះ តាមរយៈការរៀបចំឱ្យមានការបោះឆ្នោតជ្រើស-រើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សា

សង្កាត់នៅទូទាំងប្រទេស។ ផ្អែកលើបទពិសោធន៍ការអនុវត្តវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នៅក្នុងឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានបន្តពង្រឹងពង្រីកការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ដទៃទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំការបោះ-ឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌនៅទូទាំងប្រទេស។

នៅក្នុងការអនុវត្តជាជំហានៗនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដូចខាងលើនេះ រាជរដ្ឋា-ភិបាលកម្ពុជាបានតាក់តែងនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាជាច្រើន ដើម្បីធានានូវភាពប្រាកដប្រជា និងភាពជោគជ័យក្នុងការអនុវត្តកំណែ-ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។ ក្នុងចំណោមនេះ គោលនយោបាយ និងច្បាប់សំខាន់ៗរួមមាន៖

- យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ ទី២ និងទី៣
- ក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈ-ការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ទន្ទឹមនឹងការដាក់ចេញក្របខ័ណ្ឌគោលនយោ-បាយ និងក្របខ័ណ្ឌច្បាប់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ ដែលការអនុវត្តកម្មវិធីជាតិនេះ ត្រូវបានចែកចេញជាបីដំណាក់កាលតាមរយៈការរៀបចំឱ្យមានផែនការអនុវត្តន៍លម្អិតតាមដំណាក់កាលនីមួយៗ។ បច្ចុប្បន្ននេះ ផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី១(ផអ៣ទី១) ដែលមានរយៈពេល០៣ឆ្នាំ+០១ឆ្នាំ (២០១១-២០១៤)បានបញ្ចប់ និងកំពុងបន្តអនុវត្តផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី២(ផអ៣ទី២) ដែលមានរយៈពេល០៣ឆ្នាំ(២០១៥-២០១៧)។

ខាងក្រោមនេះ គឺជាខ្សែពេលវេលានៃដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។




*ដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា*

### ១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣

ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ ទី៤ និងទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣។ នៅក្នុងឯកសារយុទ្ធសាស្ត្រទាំងបី អភិបាលកិច្ចល្អត្រូវបានចាត់ទុកជាស្នូល និងជាបុរេល័ក្ខខ័ណ្ឌដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌។ ដើម្បីសម្រេចបាននូវគោលដៅនៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ធ្វើកំណែទម្រង់លើវិស័យចំនួនបួនរួមមាន៖

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

កំណែទម្រង់ទាំងបួននេះ ត្រូវបានពង្រឹងពង្រីក និងយកចិត្តទុកដាក់អនុវត្តកាន់តែស៊ីជម្រៅពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ។ ជាពិសេស ពាក់ព័ន្ធកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាកំណែទម្រង់ដ៏មានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព មានការចូលរួម គណនេយ្យភាព សមធម៌ និងបរិយាប័ន្ន។

### ២. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមាន ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងគោលបំណងកំណត់អំពី៖

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ រៀបចំឡើងដោយឈរលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់តាមរយៈការដាក់ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០១។ ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំ និងត្រូវបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ២០០៨។

ក្នុងការដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមស្មារតីនៃច្បាប់រៀបចំអង្គការខាងលើ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធបានដាក់ចេញនូវព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន

ពាក់ព័ន្ធដទៃទៀតជាច្រើន ដើម្បីធានាឱ្យប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានអាចដំណើរការទៅបានប្រកប ដោយភាពលូន មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

### III. គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

មាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា៖រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការៈ។

ក្នុងន័យនេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានដែលបានមកពីការផ្ទេរពីថ្នាក់ជាតិទៅឱ្យក្រុមប្រឹក្សា ឬបានមកពីប្រភពនៅមូលដ្ឋាន ឬប្រភពផ្សេងៗទៀត ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាព នូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈឆ្លើយតបទៅនឹងសមាសធាតុទាំង៨ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលបានកំណត់នៅក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

គោលការណ៍ទាំង៨ខាងលើ គឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ បែបបទ នីតិវិធី បំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការរៀបចំច្បាប់ និងលិខិតបទដ្ឋាននានា។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង៨ មានដូចខាងក្រោម៖

**ទី១៖ ភាពជាតំណាងសាធារណៈ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស គឺជាការផ្តល់ភាពជាតំណាងសាធារណៈ ដល់ក្រុមប្រឹក្សាជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានា ក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយមិនមានការរើសអើងខាងនយោបាយ ពណ៌សម្បុរ ជំនឿ សាសនា ជនជាតិ និងទ្រព្យធននោះឡើយ។

**ទី២៖ ស្វ័យភាពរបស់មូលដ្ឋាន**

ស្វ័យភាពមូលដ្ឋាន មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងដែនសមត្ថកិច្ចដែលច្បាប់បានកំណត់។

**ទី៣៖ ការពិគ្រោះយោបល់ និងការចូលរួម**

ការពិគ្រោះយោបល់ និងការចូលរួម គឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមានលក្ខណៈផ្សេងៗគ្នាក្នុងមូលដ្ឋានខ្លួន (ឧទាហរណ៍ តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រ...ជាដើម) សំដៅធ្វើសេចក្តីសម្រេចឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៤៖ ការឆ្លើយតប និងគណនេយ្យភាព**

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

**ទី៥៖ ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន**

គឺជាកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើត និងធ្វើឱ្យមានភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនិងលើកកម្ពស់ផាសុកភាពនិងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈផ្សេងៗគ្នាទៅតាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជាយុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច ក្រុមជនក្រីក្រ ជាដើម ហេតុនេះក្រុមប្រឹក្សាត្រូវខិតខំស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយ ពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះ តាមរយៈការលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវខិតខំប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

**ទី៦៖ ការលើកស្ទួយសមធម៌**

ជាគោលការណ៍ ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតប គណនេយ្យភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។

ការលើកស្ទួយសមធម៌សង្គម គឺជាកិច្ចដំណើរការដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រឹងប្រែងធានាឱ្យមានការពិគ្រោះយោបល់ ការចូលរួមកាន់តែស៊ីជម្រៅជាមួយស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ សហគមន៍ក្រីក្រ ជនជាតិភាគតិច... ។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍឱ្យបានសមស្របបំផុតចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះ ការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនខាងលើនេះ ដើម្បីឱ្យក្រុមជនទាំងនេះទទួលបាននូវឱកាសកាន់តែច្រើន អត្ថប្រយោជន៍កាន់តែច្រើន ពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។

## ទី៧៖ តម្លាភាព និងសុចរិតភាព

តម្លាភាព និងសុចរិតភាព គឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ជាស្ថាប័នប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ជាក្រឹត្យក្រម តម្លាភាព និងសុចរិតភាពមិនអាចកើតឡើងដោយឯកឯងបានឡើយ។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីច្បាស់លាស់សម្រាប់ស្ថាប័ននីមួយៗ ហើយថ្នាក់ដឹកនាំនៃស្ថាប័ននោះ ត្រូវមានការប្ដេជ្ញាចិត្តក្នុងការកសាងស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សា គណៈអភិបាលត្រូវមានការប្ដេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឱ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈបើកចំហរមានតម្លាភាព ដោយត្រូវធានាឱ្យបានថា សមាជិកក្រុមប្រឹក្សាគ្រប់ៗរូប អភិបាល អភិបាលរង មន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាពក្នុងការបំពេញការងារ ការផ្ដល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់ខ្លួន ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យការងារផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធសវនកម្មផ្ទៃក្នុង ផ្ទៃក្រៅ និងប្រព័ន្ធ នីតិវិធីនានាជាច្រើនដែលបានដាក់ឱ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការលើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ទី៨៖ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច គឺជាកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈគ្រប់ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គមមួយប្រកបដោយភាពស្អាតស្អំ និងយុត្តិធម៌ ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

ព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវច្បាប់ប្រឆាំងអំពើពុករលួយនាខែមេសា ឆ្នាំ២០១០។ លើមូលដ្ឋាននៃច្បាប់នេះ កម្ពុជាកំពុងចាត់វិធានការតាមគ្រប់រូបភាពដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងសង្គមទាំងមូល។

រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ជារដ្ឋបាលដែលកើតចេញពីការបោះឆ្នោត ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ហេតុនេះ រដ្ឋបាលនីមួយៗត្រូវដាក់ចេញនូវវិធានការប្រកបដោយប្រសិទ្ធភាព និងមានភាពសក្ដិសិទ្ធិ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមគ្រប់រូបភាពក្នុងស្ថាប័នរបស់ខ្លួន។ ទន្ទឹមនឹងការដាក់ចេញនូវវិធានប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងស្ថាប័នរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវសហការចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ វិធានការទាំងនេះ ត្រូវធានាឱ្យមានការចូលរួមពីផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋទាំងមូលផងដែរ។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវចាត់វិធានការ ចំពោះសកម្មភាពរំលោភអំណាចដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ មាត្រា ៤៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានគូសបញ្ជាក់យ៉ាងច្បាស់

អំពីនិយមន័យ និងសកម្មភាពនានាដែលកំណត់ថា ជាការរំលោភអំណាចហើយច្បាប់ក៏បានចង្អុលបង្ហាញនូវវិធានសម្រាប់ដោះស្រាយ ក្នុងករណីមានសកម្មភាពរំលោភអំណាចកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។

សរុបមកវិញ គោលការណ៍ទាំងនេះ មានទំនាក់ទំនងផ្សារភ្ជាប់គ្នា និងជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមក។ ភាពទន់ខ្សោយក្នុងការអនុវត្តសមាសធាតុណាមួយ ឬមួយចំនួន ឬការខកខានមិនបានដាក់បញ្ចូលនូវសមាសធាតុណាមួយ ឬមួយចំនួនក្នុងកិច្ចដំណើរការនៃកំណែទម្រង់នឹងជះឥទ្ធិពលមិនល្អដល់សមាសធាតុផ្សេងៗទៀត ហើយធ្វើឱ្យប៉ះពាល់ដល់ចីរភាពនៃដំណើរការកំណែទម្រង់ទាំងមូល។

រូបភាពខាងក្រោម បង្ហាញអំពីទំនាក់ទំនងនៃសមាសធាតុទាំង៨ នៃកិច្ចដំណើរការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលសមាសធាតុទាំង៨នេះមានភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមក និងមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ។




*ទំនាក់ទំនងនៃសមាសធាតុទាំង៨នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ*

# ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារតាមរយៈការគាំទ្រពីរាជរដ្ឋាភិបាលមូលដ្ឋាន




ស្រុកគោលដៅនៃកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (២០១៦)

ខេត្តសៀមរាបមានផ្ទៃក្រឡា១០២៩៩គីឡូម៉ែត្រការ៉េ ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា និងមានព្រំប្រទល់ខាងជើងជាប់ជាមួយខេត្តឧត្តរមានជ័យ ខាងកើតជាប់ខេត្តព្រះវិហារ និងខេត្តកំពង់ធំ ខាងលិចជាប់ជាមួយខេត្តបន្ទាយមានជ័យ និងភាគខាងត្បូងជាប់អាងស្តុកទឹកដ៏ធំជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍គឺបឹងទន្លេសាប។ ទន្ទឹមនេះ ខេត្តសៀមរាបក៏ជាខេត្តសម្បូរដោយប្រាង្គប្រាសាទ ជាពិសេសប្រាសាទអង្គរវត្ត ដែលមានភាពល្បីល្បាញនៅទូទាំងពិភពលោក។ ក្រៅពីសក្តានុពលផ្នែកទេសចរណ៍ ខេត្តសៀមរាប ក៏ជាតំបន់ដីសើមដែលគ្របដណ្តប់ដោយវាលស្រែ និងដំណាំកសិកម្មផ្សេងទៀត ព្រមទាំងមានគម្របព្រៃធម្មជាតិនៅភាគខាងជើងនៃដែនដីខេត្តផងដែរ។

ទោះបីខេត្តសៀមរាបដែលខេត្តមានសក្តានុពលយ៉ាងនេះក៏ដោយ មុនឆ្នាំ២០០៧ ប្រជាពលរដ្ឋភាគច្រើននៅក្នុងខេត្តនេះ មានកម្រិតជីវភាពទាបជាងខេត្តដទៃទៀតមួយចំនួនធំ។ អ្នកទទួលផលប្រយោជន៍ពីវិស័យទេសចរណ៍ ភាគច្រើនជាអ្នកមានទ្រព្យសម្បត្តិ ក្នុងនោះរួមមានម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន ឬម្ចាស់ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងវិស័យនេះ។ ដោយឡែក សម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ មិនសូវទទួលបានផលប្រយោជន៍ពីវិស័យទេសចរណ៍នេះទេ។ ប្រឈមមុខនឹងបញ្ហានេះ នៅក្នុងឆ្នាំ២០០៧ រដ្ឋបាលខេត្តសៀមរាប ដោយមានការជួយឧបត្ថម្ភគាំទ្រពីអង្គការ GIZ បានបង្កើតឱ្យមានកម្មវិធី "ខ្សែក្រវ៉ាត់បៃតង" (Green Belt) នៅក្នុងស្រុកចំនួន ០៣ នៃខេត្តសៀមរាប គឺស្រុកអង្គរជុំ ស្រុកវ៉ារិន និង

ស្រុកពួក។ បច្ចុប្បន្ន កម្មវិធីនេះ បានប្រែក្លាយទៅជាកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (RED: Regional Economic Development) ដោយមានវិសាលភាពគ្របដណ្តប់គ្រប់ស្រុកជនបទទាំង១១ ក្នុងខេត្តសៀមរាប និងកំពុងបន្តអនុវត្តនៅស្រុកចំនួន០៥ ក្នុងខេត្តបន្ទាយមានជ័យ និងស្រុកចំនួន០៤ ក្នុងខេត្តឧត្តរមានជ័យ។ កម្មវិធីនេះ មានគោលបំណងជួយដល់ប្រជាពលរដ្ឋជនបទក្រីក្រជាពិសេសស្ត្រីមានឱកាសបំពេញការងារ និងប្រកបរបរចិញ្ចឹមជីវិតប្រកបដោយចីរភាពសំដៅលើកកម្ពស់ប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ។ ដើម្បីសម្រេចគោល-បំណងនេះ កម្មវិធីមានគោលដៅជាយុទ្ធសាស្ត្រដូចខាងក្រោម៖

-ពង្រឹងសកម្មភាពរបស់រដ្ឋបាលមូលដ្ឋានឱ្យមានលក្ខណៈឆ្លើយតប និងបរិយាប័ន្ន

-លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់

-បង្កើតថ្មី ឬកែលម្អសេវាកម្មសម្រាប់ប្រជាពលរដ្ឋ និងធុរកិច្ចនៅមូលដ្ឋាន។

តាមរយៈការអនុវត្តគោលដៅជាយុទ្ធសាស្ត្រទាំងនេះ សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋបានលើកកម្ពស់តាមរយៈការគាំទ្រពីអាជ្ញាធរមូលដ្ឋានក្នុងនោះសកម្មភាពសំខាន់ៗ ដែលកម្មវិធីនេះយកចិត្តទុកដាក់គឺការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការចងក្រងសហគមន៍មូលដ្ឋាន។

**ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា**

សម្រាប់ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា រដ្ឋបាលខេត្តសៀមរាប ដោយសហការជាមួយមន្ត្រីគាំទ្រកម្មវិធី បានផ្តល់ការចុះបណ្តុះបណ្តាលពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សានៅ៤ស្រុកគោលដៅលើការងារគ្រប់គ្រងកិច្ចការផ្សេងៗនៅរដ្ឋបាលឃុំជាពិសេសពាក់ព័ន្ធការពង្រឹងប្រសិទ្ធភាពនៃកិច្ចប្រជុំក្រុមប្រឹក្សា នីតិវិធីនៃការចេញដីកា ការរៀបចំទុកដាក់ឯកសារ ការផ្តល់សេវា និងការបំផុសគំនិតក្នុងការស្វែងរកសក្តានុពល ដើម្បីអភិវឌ្ឍមូលដ្ឋានជាដើម។ ក្រៅពីនេះ ក៏មានការចុះទស្សនកិច្ចសិក្សាផងដែរទាំងនៅក្នុងស្រុក និងក្រៅប្រទេស ដើម្បីសិក្សាស្វែងយល់ដោយផ្ទាល់ពីបទពិសោធន៍អនុវត្តន៍ជាក់ស្តែងដោយអង្គភាព ស្ថាប័នពាក់ព័ន្ធ។

បន្ទាប់ពីមានការបណ្តុះបណ្តាល ការចុះណែនាំផ្ទាល់ និងការចូលរួមទស្សនកិច្ចសិក្សា សមត្ថភាពក្រុមប្រឹក្សាឃុំ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយក្រុមប្រឹក្សាឃុំដែលក្រុមការងារបានចុះជួបសម្ភាសន៍បានបង្ហាញអំពីការជឿជាក់លើខ្លួនឯងកាន់តែច្រើន មានការយល់ដឹងពីបញ្ហាប្រឈម និងសក្តានុពលរបស់មូលដ្ឋាន ព្រមទាំងចេះស្វែងរកដំណោះស្រាយតាមរយៈវិធានការផ្សេងៗ មានដូចជាការដាក់ចេញនូវដីកាចាំបាច់មួយចំនួន ដើម្បីដោះ-ស្រាយបញ្ហាប្រឈមនៅមូលដ្ឋានរបស់ខ្លួន ដែលតាមរយៈការដាក់ចេញដីកាទាំងនេះ ប្រជាពលរដ្ឋមានការអបអរដោយដីកាទាំងនេះ បានការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ជាក់ស្តែងនៅឆ្នាំ២០០៩ ក្រុមប្រឹក្សាឃុំប្រាសាទ នៃស្រុកវ៉ារិន បានដាក់ចេញនូវដីកាស្តីពីការទប់ស្កាត់ការលែងសត្វចិញ្ចឹមគ្មានសណ្តាប់ធ្នាប់ ដែលបានធ្វើឱ្យការដាំដុះរបស់ប្រជាកសិករទទួលបានផលគាប់ប្រសើរជាងមុន ដោយសារដំណាំដាំដុះរបស់ប្រជាពលរដ្ឋក្នុងឃុំ មិនត្រូវបានបំផ្លាញដោយសត្វចិញ្ចឹមដូចពេលមុន។ លើសពីនេះទៀត ដីកានេះ បានចូលរួមកាត់បន្ថយទំនាស់នៅមូលដ្ឋាន ព្រមទាំងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលបង្កដោយសត្វចិញ្ចឹមផងដែរ។ ក្រុមប្រឹក្សាឃុំសំរោងយា នៃស្រុកពួក កាលពី

ឆ្នាំ២០១២ បានដាក់ចេញដីកាស្តីពីការគ្រប់គ្រង ការពារ និងថែរក្សាទ្រព្យសម្បត្តិសាធារណៈផ្នែកអភិវឌ្ឍសេដ្ឋកិច្ច ដែលដីកានេះ មានផលប្រយោជន៍ក្នុងការការពារ ថែរក្សា និងទប់ស្កាត់នូវរាល់អំពើអនាធិបតេយ្យ ដែលបង្កការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈផ្នែកសេដ្ឋកិច្ច រួមមានអូរ ប្រឡាយ បឹង ត្រពាំង ព្រៃក ផ្លូវ បង្គោលការពារផ្លូវ លូ ស្ពាន ដីចំណីផ្លូវ ផ្លូវរទេះ សំណង់ធារាសាស្ត្រ ស្លាកសញ្ញាសាធារណៈ និងរោងយាមជាដើម ដើម្បីធានាឱ្យមានការប្រើប្រាស់ និងទាញយកប្រយោជន៍ពីទ្រព្យសម្បត្តិសាធារណៈប្រកបដោយនិរន្តភាព។ ក្រៅពីការលើកកម្ពស់សមត្ថភាពក្នុងការរៀបចំដីកាដើម្បីផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួន ការងារគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ ក៏ត្រូវបានលើកកម្ពស់ផងដែរ ក្នុងនោះយើងសង្កេតឃើញការទុកដាក់ឯកសាររបស់រដ្ឋបាលឃុំមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ ដោយឯកសារទាំងនោះត្រូវបានរៀបចំតាមប្រភេទឯកសារ និងកាលប្បវត្តិយ៉ាងផ្ចិតផ្ចង់ និងល្អប្រសើរ។

**ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ**

ក្រៅពីអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សា កម្មវិធីក៏បានយកចិត្តទុកដាក់លើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសជំនាញដល់ប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ ក្នុងនោះមានដូចជាបច្ចេកទេសដាំស្រូវ ដាំបន្លែផ្លែឈើ ដាំឫស្សី និងចិញ្ចឹមសត្វជាដើម។ ប្រជាពលរដ្ឋនៅតាមឃុំគោលដៅត្រូវបានជ្រើសរើសតាមការស្ម័គ្រចិត្ត ដោយមានការសម្របសម្រួលពីអាជ្ញាធរមូលដ្ឋាន ដើម្បីបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់អ្នកទាំងនោះ។ ជាទូទៅប្រជាពលរដ្ឋ ដែលប្រកបរបរចិញ្ចឹមជីវិតស្របតាមជំនាញដែលកម្មវិធីបើកវគ្គបណ្តុះបណ្តាលតែងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការចូលរួមការបណ្តុះបណ្តាលពីការដាំដំណាំ។ ជាលទ្ធផលរួម ក្រុមការងារសង្កេតឃើញថា ប្រជាកសិករដែលបានទទួលការបណ្តុះបណ្តាល ហើយបន្តប្រកបរបរចិញ្ចឹមជីវិតតាមជំនាញដែលបានទទួលការបណ្តុះបណ្តាលទាំងនោះ ជីវភាពរបស់ពួកគាត់មានការប្រែប្រួលគួរឱ្យកត់សម្គាល់។ នៅពេលជួបជាមួយលោក **សុខ សំ** ដែលជាកសិករចិញ្ចឹមមាន់រស់នៅឃុំប្រាសាទ ស្រុករ៉ាំរិន បានឱ្យដឹងថា ការចិញ្ចឹមមាន់តាមធម្មជាតិរបស់គាត់មាន ការរីកចម្រើនគួរឱ្យកត់សម្គាល់ដោយក្នុងមួយឆ្នាំ គាត់អាចលក់មាន់ចិញ្ចឹមបានបីដង ដោយមួយដងលក់បានពី ៥០គីឡូក្រាម ទៅ៧០គីឡូក្រាម។ ចំណែក លោក **ឆាយ ឆេង** ជាកសិករដាំដើមឫស្សី នៅឃុំប្រាសាទ ស្រុករ៉ាំរិន និងលោកស្រី **ខេង ឡូន** ជាកសិករដាំបន្លែ នៅឃុំដូនកែវ ស្រុកពួក នៃខេត្តសៀមរាប ដែលក្រុមការងារបានចុះជួបផ្ទាល់ ក៏បានបង្ហាញពីភាពរីករាយ និងសប្បាយចិត្តផងដែរ ចំពោះទិន្នផលនៃការដាំដុះរបស់ពួកគាត់។ អ្នកទាំងពីរបាន លើកឡើងពីអត្ថប្រយោជន៍យ៉ាងច្រើន ដែលទទួលបានបន្ទាប់ពីពួកគាត់បានទទួលជំនាញច្បាស់លាស់ក្នុងការដាំដុះពីអ្នកជំនាញការដែលបណ្តុះបណ្តាលពួកគាត់។



*ការផ្សាំកូនឫស្សី*

ទោះបីប្រជាពលរដ្ឋមួយចំនួនដែលទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេសពីកម្មវិធីខ្សែក្រវ៉ាត់បៃតង ឬកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ មិនបានបន្តប្រើប្រាស់ជំនាញបច្ចេកទេសទាំងនេះក៏ដោយ តាមការឱ្យដឹងពីអ្នកពាក់ព័ន្ធ ក៏ដូចប្រជាពលរដ្ឋដែលបានចុះជួបផ្ទាល់ មានប្រជាពលរដ្ឋមួយចំនួននៅតែបន្តប្រើប្រាស់បច្ចេកទេសដែលទទួលបានពីកម្មវិធីទាំងនេះយ៉ាងជោគជ័យ ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ទាំងក្នុងគោលបំណងបម្រើសេចក្តីត្រូវការក្នុងគ្រួសារ និងក្នុងគោលបំណងផ្គត់ផ្គង់ទៅទីផ្សារ។

ជាលទ្ធផលតាមរយៈគម្រោងនេះ ទីផ្សារបន្លែក្នុងខេត្ត បានកើនឡើងពី៧% ក្នុងឆ្នាំ ២០០៧ ទៅ ២៥% នៅក្នុងឆ្នាំថ្មីៗនេះ។



*ចំការដំណាំសណ្តែកគួរ*

ចំណែក ទិន្នផលស្រូវមានការកើនឡើងទាំងគុណភាព និងបរិមាណ ដោយសារកសិករយល់ដឹងពីបច្ចេកទេសដាំដុះ ការជ្រើសរើសពូជ និងការប្រើប្រាស់ជីធម្មជាតិ។ សព្វថ្ងៃនេះ រោងម៉ាស៊ីនកិនស្រូវក្នុងស្រុកកំពុងនាំចេញអង្ករពីខេត្តសៀមរាបដែលជាអតីតខេត្តដែលផលិតស្រូវមិនបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខេត្តខ្លួនឯង ទៅកាន់ទីផ្សារដែលមានស្តង់ដារល្អ ដូចជាសហរដ្ឋអាមេរិក ឬអឺរ៉ុប។ កសិករ និងសិប្បករ ប្រមាណ១៧.៥០០នាក់ អាចបង្កើនចំណូលប្រចាំឆ្នាំជាមធ្យមប្រមាណ ២០០ ដុល្លារអាមេរិក (Economic growth, falling poverty, GIZ's Website ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១៧)។

លើសពីនេះទៀត ក្រៅពីការយកជំនាញបច្ចេក-ទេសដែលទទួលបានយកមកប្រើប្រាស់នៅក្នុងការប្រកបរបររបស់ខ្លួន ក៏មានកសិករមួយចំនួនដែលមានជំនាញបច្ចេកទេសច្បាស់លាស់ត្រូវបានស្ថាប័នឬអង្គការមួយចំនួនអញ្ជើញទៅបណ្តុះបណ្តាលបន្តដល់ប្រជាកសិករនៅក្នុងតំបន់ ក៏ដូចនៅក្រៅតំបន់ផងដែរ រហូតដល់អ្នកទាំងនោះបានក្លាយជាគ្រូបង្គោល ដែលបានទទួលការបណ្តុះបណ្តាលដោយជោគជ័យមានចំនួនសរុប៤៨នាក់ ក្នុងនោះមាន ៤០នាក់(៨៣.៣៤%)បានប្រើប្រាស់ចំណេះដឹងទាំងនេះក្នុងការចែករំលែកទៅកសិករផ្សេងទៀតដែលធ្វើឱ្យពួកគាត់មានលទ្ធភាពក្នុងការពង្រីកចំណេះដឹងរបស់ខ្លួន ក៏ដូចជាទទួលបានចំណូលបន្ថែមពីការបណ្តុះបណ្តាលក្រៅពីផលិតកម្មរបស់ពួកគាត់ផងដែរ។ ជាក់ស្តែង នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប មានកសិករចំនួន០៩រូប ដែលបានក្លាយជាគ្រូបង្គោលលើជំនាញផ្សេងៗ ក្នុងនោះរួមមាន ១) លោក **ម៉ុង សុឃឿន** ជាគ្រូបង្គោលផ្នែកចិញ្ចឹមមាន់ និងជ្រូក ២) លោក **តូច ចន្ថា** ជាគ្រូបង្គោលសម្រាប់ដំណាំឈើហូបផ្លែ ៣) លោក **ឈឿម ឈាំ** ជាគ្រូបង្គោលចិញ្ចឹមមាន់ ៤) លោក **សៀង ជូ** ជាគ្រូបង្គោលចិញ្ចឹមមាន់ ៥) លោកស្រី **ណិប ឡាយ** ជាគ្រូបង្គោលផ្នែកដាំទំពាំងបារាំង និងចិញ្ចឹមគោ ៦) លោក **អាន សំអុល** ជាគ្រូបង្គោលផ្នែកបន្លែចម្រុះ


លោក ម៉ុង សុឃឿន (០១៧ ២៥០ ៩៣៦)


លោក ជាន់ ឡុន (០១៧ ៦៩៧ ១៧៧)


លោក ឈឿម លាំ (០៨៩ ២៨០ ៦០៧)


លោក តូច ចន្ថា (០៨៩ ៧៦៨ ៨៩៧)

៧) លោក **យ៉ាប់ វណ្ណៈ** ជាគ្រូបង្គោលផលិតស្រូវពូជ ៨) លោក **ប៉ាវ សុខ** (ស្លាប់) ជាគ្រូបង្គោលផ្នែកបន្លែចម្រុះ និងដាំឫស្សី និង ៩) លោក **ជាន់ ឡុន** ជាគ្រូបង្គោលផ្នែកដាំត្រសក់។

**ការចងក្រងសហគមន៍មូលដ្ឋាន**

ការចងក្រងជាសហគមន៍ ជាចលករយ៉ាងសំខាន់ក្នុងការប្រមូលផ្តុំសក្តានុពលមូលដ្ឋានដើម្បីធ្វើការប្រកួតប្រជែងក្នុងទីផ្សារ ក៏ដូចការការពារផលប្រយោជន៍របស់សហគមន៍។ ដោយយល់ឃើញពីសារសំខាន់នេះ កម្មវិធីនេះបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបញ្ជ្រាបគោលគំនិតនេះ ក៏ដូចជួយជ្រោមជ្រែងប្រជាពលរដ្ឋឱ្យមានការចាប់អារម្មណ៍ក្នុងការចូលរួមចងក្រងជាសហគមន៍ ដើម្បីគាំទ្រនិងជំរុញកិច្ចការជំនួញរបស់ពួកគាត់ដែលរហូតមកដល់ពេលនេះ មានសហគមន៍ជាច្រើនត្រូវបានបង្កើតឡើងនៅតាមស្រុកគោលដៅក្នុងខេត្តសៀមរាប។ ជាក់ស្តែង ក្រុមប្រឹក្សាឃុំចារឈូក ស្រុកអង្គរធំ បានផ្តួចផ្តើមបង្កើតសហគមន៍អភិរក្សត្រីធម្មជាតិ ដែលតំបន់អភិរក្សនេះ មានទីតាំងស្ថិតនៅភូមិតាទយ(ស្ទឹងគោកម្លាក់) ក្នុងគោលបំណងបង្កើនផលត្រីធម្មជាតិ នៅតាមវាលស្រែ ប្រឡាយ ស្ទឹង និងតាមតំបន់វាលទំនាបលិចទឹក តាមរយៈការប្រែក្លាយតំបន់ទាំងនោះជាទីជ្រករស់នៅ និងពងកូនរបស់មច្ឆជាតិ និងតាមរយៈការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការទទួលស្គាល់អំពីអត្ថប្រយោជន៍នៃការគ្រប់គ្រង និងអភិរក្សត្រីធម្មជាតិនៅក្នុងសហគមន៍។ ដោយឡែក នៅស្រុកបន្ទាយស្រី ដោយមានការសហការគាំទ្រពីរដ្ឋបាលស្រុកបន្ទាយស្រី សង្គមស៊ីវិល វិស័យឯកជន និងដៃគូដទៃទៀត ផែនការអភិវឌ្ឍន៍ទេសចរណ៍មូលដ្ឋានត្រូវបានរៀបចំឡើង ដើម្បីជាជម្រើសក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដើម្បីគាំទ្រដល់ផែនការនេះ កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់បានណែនាំ បណ្តុះបណ្តាល និងគាំទ្រប្រជាពលរដ្ឋឱ្យចងក្រងជាសហគមន៍ ដើម្បីរួមគ្នាប្រែក្លាយ


លោក សៀង ជូ (០៩៧ ៧១៩ ០៣៥៧)


លោកស្រី ណាប ឡាយ (០១២ ៧០៦ ៩៦១)


លោក យ៉ាប់ វណ្ណៈ (០១២ ៤៦១ ០៦៤)


លោក អាន សំអុល (០៩២ ៩៥១ ៣៦៥)

តំបន់ដែលមានសក្តានុពលទេសចរណ៍នេះ ទៅជាប្រភពចំណូលសម្រាប់លើកកម្ពស់ជីវភាពរស់នៅតាមគ្រួសារប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ ជាលទ្ធផល សហគមន៍ជាច្រើនត្រូវបានបង្កើត ក្នុងនោះមានដូចជាសហគមន៍ផ្ទះស្នាក់ សហគមន៍ព្រៃឈើ សហគមន៍ទូក សហគមន៍ស្តុកផ្កាត សហគមន៍បន្លែ សហគមន៍បាយ័នញញឹម និងសហគមន៍អ្នកលក់នំបញ្ចុកជាដើម។ សហគមន៍ទាំងនេះ បានចងក្រងជាបណ្តាញសហគមន៍ទេសចរណ៍ស្រុកបន្ទាយស្រី ដើម្បីជួយគាំទ្រគ្នាទៅវិញទៅមកក្នុងការជំរុញឱ្យមានការរីកចម្រើននៅតាមសហគមន៍នីមួយៗ។ ការចងក្រងជាសហគមន៍នេះ បានផ្តល់ផលប្រយោជន៍យ៉ាងច្រើន ដល់ប្រជាពលរដ្ឋ ក៏ដូចអាជីវករនៅមូលដ្ឋាន ជាពិសេសក្នុងការប្រមូលផ្តុំសក្តានុពលតាមវិស័យ សម្រាប់ភាពរីកចម្រើនប្រកបដោយភាពសុខដុមរមនា វិបុលភាព និងចីរភាព។ ជាក់ស្តែងប្រជាពលរដ្ឋចំនួនប្រមាណ១៥គ្រួសារ នៅក្នុងភូមិត្បែងលិច និងភូមិវត្ត នៃឃុំត្បែង ស្រុកបន្ទាយស្រី ដែលមានផ្ទះសម្បែងផ្សេងៗគ្នា និងឃ្លាតពីគ្នា បានចងក្រងជាសហគមន៍ផ្ទះស្នាក់ ដែលតាមរយៈការចងក្រងជាសហគមន៍នេះ ធ្វើឱ្យសហគមន៍របស់គាត់ប្រែក្លាយដូចជាផ្ទះសំណាក់ ដែលមានច្រើនបន្ទប់ និងអាចទទួលភ្ញៀវមកស្នាក់នៅបានច្រើននាក់ ក្នុងពេលតែមួយ។ តាមរយៈការចងក្រងជាសហគមន៍នេះ ក្រុមគ្រួសារទាំងនេះអាចទទួលបានចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគាត់មួយកម្រិតថែមទៀត។ មិនតែប៉ុណ្ណោះ ការចងក្រងជាសហគមន៍ផ្ទះស្នាក់នេះ ថែមទាំងអាចជួយផ្សព្វផ្សាយអំពីប្រពៃណី វប្បធម៌ដ៏ល្អផូរផង់របស់កម្ពុជាដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិថែមទៀតផង។



*បន្ទប់នៃផ្ទះស្នាក់*

សរុបមក តាមរយៈបទពិសោធន៍នៃការអនុវត្តកម្មវិធីខ្សែក្រវ៉ាត់បៃតង ឬកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់បានបញ្ជាក់ឱ្យឃើញថា អាជ្ញាធរមូលដ្ឋានមានតួនាទីសំខាន់ណាស់ក្នុងការលើកស្ទួយសេដ្ឋកិច្ចគ្រួសារនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ដើម្បីអាចសម្រេចកិច្ចការនេះបាន ទាមទារឱ្យអាជ្ញាធរមូលដ្ឋានមានសមត្ថភាពស្វែងយល់អំពីសក្តានុពលរបស់មូលដ្ឋានខ្លួន ក៏ដូចសមត្ថភាពក្នុងការដោះស្រាយ និងគ្រប់គ្រងចាត់ចែងកិច្ចការនានាក្នុងដែនសមត្ថកិច្ច ដើម្បីផ្តួចផ្តើមរៀបចំផែនការ និងសកម្មភាពចាំបាច់នានា ដែលមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពក៏ដូចសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន៕

*ដោយ លឹម ពុទ្ធារី*

ឯកសារយោង

-អត្ថបទស្តីពី Economic growth, falling poverty, GIZ's Website ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧

# ការអភិវឌ្ឍអ្នកដឹកនាំវ័យក្មេង



*ឯ.ឧ អភិបាលខេត្តកណ្តាល: "ការបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេង ជាកិច្ចការចម្បងដែលរដ្ឋបាលខេត្តត្រូវយកចិត្តទុកដាក់។"*

ការអភិវឌ្ឍស្ថាប័នប្រកបដោយថាមពល និងមានសមត្ថភាពពេញលេញ ជាកត្តាគន្លឹះដែលមិនអាចមើលរំលងបានក្នុងការដឹកនាំគ្រប់គ្រងស្ថាប័ន។ ក្នុងនោះការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីបម្រើការងារនៅតាមស្ថាប័ន គឺជាកម្លាំងស្នូលដ៏សំខាន់ និងចម្បងដែលមិនអាចខ្វះបាន។ ដោយឈរលើទស្សនវិស័យនេះ ក្នុងឆ្នាំ២០១៦រដ្ឋបាលខេត្តកណ្តាល បានផ្តួចផ្តើមរៀបចំឱ្យមានគម្រោងអភិវឌ្ឍន៍សមត្ថភាពអ្នកដឹកនាំវ័យក្មេង។ គម្រោងនេះ មានគោលបំណងបណ្តុះ-បណ្តាលមន្ត្រីវ័យក្មេងដែលមានសក្តានុពលឱ្យក្លាយជាអ្នកដឹកនាំល្អ មានសមត្ថភាព មានការយល់ដឹងជ្រៅជ្រះ និងជាអ្នកបន្តវេនដឹកនាំគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាពនៅថ្ងៃអនាគត។

ដើម្បីស្វែងយល់អំពីការរៀបចំគម្រោងនេះ ក្រុមការងារសូមណែនាំអំពីទិដ្ឋភាពទូទៅនៃគម្រោងនេះ ដូចខាងក្រោម៖

**<u>ប្រធានបទ</u>**

ដើម្បីក្លាយជាអ្នកដឹកនាំក្នុងបរិបទកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ប្រធានបទសំខាន់ៗនឹងផ្តោតលើ៖

១. ការងារអភិបាលកិច្ចល្អ

២. ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ

៣. ការងារអភិវឌ្ឍមូលដ្ឋាន (គំនិតរៀបចំផែនការមេ គម្រោងមូលនិធិឃុំ ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ)

៤. ការងារដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ និង ភូមិឃុំមានសុវត្ថិភាព

៥. ការងារគ្រប់គ្រងហិរញ្ញវត្ថុ

៦. ទ្រឹស្តីនយោបាយ

**<u>រយៈពេល</u>**

រយៈពេលអនុវត្តគម្រោងសរុប ៧ខែ ក្នុងនោះ៖

- វគ្គហ្វឹកហ្វឺនទ្រឹស្តី សម្រាប់ ប្រធានបទទាំង ៦ ប្រើរយៈពេល ៣ សប្តាហ៍
- ការរៀបចំផែនការសិក្សា និង អនុវត្តនៅមូលដ្ឋាន រយៈពេល ១ សប្តាហ៍
- ចុះសិក្សា និង អនុវត្តផ្ទាល់នៅមូលដ្ឋាន យ៉ាងតិច ២ថ្ងៃ ក្នុងមួយសប្តាហ៍ សម្រាប់រយៈពេល ៦ខែ។

**<u>វិធីសាស្ត្រ/ដំណើរការ</u>**

**ក. ការជ្រើសរើសសិក្ខាកាម**

គម្រោងគ្រោងជ្រើសរើសសិក្ខាកាមចំនួន៣០នាក់ ដោយផ្អែកលើលក្ខណសម្បត្តិដូចខាងក្រោម៖

- មានអាយុក្រោម ៤០ឆ្នាំ
- មានបរិញ្ញាបត្រ
- ចេះភាសាអង់គ្លេសបង្គួរ
- មានសីលធម៌ល្អ, ចេះប្រើប្រាស់កុំព្យូទ័រ
- មានលទ្ធភាពប្រើ Smart Phone
- មានលទ្ធភាពចាកចេញពីផ្ទះទៅស្នាក់នៅតាមមូលដ្ឋានជាដើម។

ជាមួយនេះ គម្រោងក៏បានលើកទឹកចិត្តឱ្យមានការចូលរួមជាស្ត្រីផងដែរ ដោយកំណត់យ៉ាងតិចត្រូវមាន ៣០% នៃសិក្ខាកាមជាស្ត្រី។

ទន្ទឹមនេះ ដើម្បីធានាឱ្យមានអ្នកចូលរួមពេញលេញ សិក្ខាកាមទាំងអស់តម្រូវឱ្យចុះកិច្ចសន្យាជាមួយរដ្ឋបាលខេត្ត ដើម្បីធានាថា ពួកគេនឹងចូលរួមដោយពេញលេញ ទាំងវគ្គទ្រឹស្តី និងការអនុវត្តផ្ទាល់នៅមូលដ្ឋាន។

**ខ. វគ្គណែនាំផ្ទាល់ជាមូលដ្ឋាន**

យល់បន្ថែមពីការងារជាក់ស្តែងនៅមូលដ្ឋាន វគ្គណែនាំជាទ្រឹស្តីនឹងត្រូវបានរៀបចំនៅថ្នាក់ខេត្ត ដោយប្រើពេលវេលា ០៣សប្តាហ៍។ ក្រុមបច្ចេកទេសនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ដើរតួសម្របសម្រួល ព្រមទាំងស្វែងរកគ្រូឧទ្ទេសមានបទពិសោធន៍ មកធ្វើបាឋកថាបន្ថែមលើទ្រឹស្តីនៃប្រធានបទទាំង០៦ខាងលើ ដើម្បីចែករំលែកបទពិសោធន៍នៃការអនុវត្តផ្ទាល់ ដែលជាមេរៀនយ៉ាងសំខាន់សម្រាប់សិក្ខាកាម។

**គ. ការរៀបចំអ្នកប្រឹក្សាយោបល់(Mentor)**

សិក្ខាកាមត្រូវបែងចែកជា៣ក្រុម ដើម្បីចុះសិក្សាស្វែងយល់នៅមូលដ្ឋាន ដោយមួយក្រុមៗមានអ្នកប្រឹក្សាយោបល់ម្នាក់ ដើម្បីជួយណែនាំនិងដោះស្រាយរាល់ចម្ងល់ បញ្ហាដែលជួបប្រទះ។

**ឃ. ការរៀបចំផែនការផ្ទាល់ខ្លួនសម្រាប់ការចុះសិក្សា និងបំពេញការងារនៅមូលដ្ឋាន**

ក្រោយពីទទួលវគ្គណែនាំជាទ្រឹស្តីរយៈពេល០៣សប្តាហ៍ សិក្ខាកាមក៏ត្រូវបែងចែកជា៣ក្រុម ចុះទៅសិក្សា និងអនុវត្តផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់



*សិក្ខាកាមថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ*

ដើម្បីមានមូលដ្ឋានចំណេះដឹង ទៅដើរតួជាអ្នកជំនួយការរដ្ឋបាលឃុំ និងមានមូលដ្ឋានសិក្សាស្វែង-

នៅក្នុងស្រុក៣ នៅក្នុងខេត្តកណ្តាល។ គោលបំណងនៃការបែងចែកជាក្រុម គឺដើម្បីផ្តល់ឱកាស

ឱ្យមានការពិភាក្សាគ្នា និង ចេះសាមគ្គីគ្នា ប៉ុន្តែមិនមែនមានន័យថាធ្វើកិច្ចការរួមគ្នាទេ ព្រោះសិក្ខាកាមម្នាក់ៗ ចុះសិក្សា អនុវត្ត តាមឃុំ សង្កាត់រៀងៗ ខ្លួន។ ក្រោយពីបែងចែកក្រុមរួចហើយ អ្នកសម្របសម្រួលជួយ សិក្ខាកាមរៀបចំផែនការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន សម្រាប់ការចុះសិក្សាស្វែងយល់នៅមូលដ្ឋាន ដោយផ្តោតសំខាន់លើការអភិវឌ្ឍ ១) កសិកម្ម ២)សិប្បកម្ម និង ៣)សេវាកម្ម។ ផែនការផ្ទាល់ខ្លួនត្រូវមាន៖

- គោលបំណងអភិវឌ្ឍសមត្ថភាពខ្លួនឯង និងគោលបំណងនៃការសិក្សាស្វែងយល់ជាក់លាក់
- លទ្ធផលរំពឹងទុកពីការចុះសិក្សា និងអនុវត្តផ្ទាល់នៅមូលដ្ឋាន
- សកម្មភាព/យុទ្ធសាស្ត្រដែលត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលរំពឹងទុកខាងលើរបស់ខ្លួន ដោយបញ្ជាក់ពេលវេលាមួយមានកាលកំណត់ច្បាស់លាស់។ សិក្ខាកាមគួរត្រៀមជាសំនួរគន្លឹះមួយចំនួន (checklist) នៅក្នុងការសិក្សាស្វែងយល់នៅមូលដ្ឋាន។

ផែនការអភិវឌ្ឍន៍សមត្ថភាពផ្ទាល់ខ្លួននេះ នឹងបង្ហាញជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្តកណ្តាល ដើម្បីពិនិត្យ កែសម្រួល និងសុំការឯកភាព ហើយត្រូវចុះហត្ថលេខាដោយសាមីខ្លួន និងប្រធានគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស។

ដើម្បីសម្រួលដល់ការចុះទៅសិក្សាស្វែងយល់នៅមូលដ្ឋាននេះ រដ្ឋបាលស្រុកគោលដៅទាំង៣ នឹងជួយសម្របសម្រួលរកជួលផ្ទះមួយដែលអាចស្នាក់នៅរួមគ្នាបាន១០នាក់ សម្រាប់រយៈពេល០៦ខែ ព្រោះសិក្ខាកាមទាំងអស់តម្រូវឱ្យស្នាក់នៅរួមគ្នាយ៉ាងតិច ០២ថ្ងៃក្នុងមួយសប្តាហ៍។ រដ្ឋបាលខេត្តនឹងគាំទ្រថ្លៃជួលផ្ទះ ហើយនឹងឧបត្ថម្ភថវិកា១៥០$/ខែ ក្នុងសិក្ខាកាមម្នាក់ៗ សម្រាប់ថ្លៃអាហារ និង មធ្យោបាយធ្វើដំណើរ។

**ង. ការចុះសិក្សា និងអនុវត្តកិច្ចការនៅមូលដ្ឋាន**

សិក្ខាកាមម្នាក់ៗ ត្រូវចុះទៅធ្វើជាជំនួយការរបស់រដ្ឋបាលឃុំ សង្កាត់។ ក្នុងអំឡុងពេលចុះសិក្សា សិក្ខាកាមត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ ដោយជួយបំពេញការងារផង និង សិក្សាស្វែងយល់ពីប្រធានបទដែលបានកំណត់ផង។ សិក្ខាកាមម្នាក់ៗ ត្រូវរិះរក និងបង្កើតគំនិតផ្តួចផ្តើមសម្រាប់កែលម្អការងារនៅក្នុងឃុំរបស់ខ្លួនដែលកំពុងចុះសិក្សាហើយលើកជម្រើសនោះ ដាក់ជូនក្រុមប្រឹក្សាពិភាក្សា និងពិចារណាសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត បើសិនក្រុមប្រឹក្សាភាគច្រើនយល់ថាជាគំនិតផ្តួចផ្តើមល្អ។ ការផ្តល់គំនិតផ្តួចផ្តើមនេះ ជាលក្ខខណ្ឌដ៏ចាំបាច់មួយសម្រាប់ការវាយតម្លៃនៅចុងបញ្ចប់វគ្គ។

ពេលជួបបញ្ហានៃការអនុវត្តផែនការផ្ទាល់ខ្លួន សិក្ខាកាមត្រូវពិភាក្សាជាមួយអ្នកប្រឹក្សាយោបល់ តែបើមានការប្រែប្រួលខ្លាំងលើផែនការ សិក្ខាកាមត្រូវធ្វើការពិភាក្សាសុំយោបល់ពីគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍សមត្ថភាពជាមុន ក្នុងបំណងដើម្បីធានាថាផែនការផ្លាស់ប្តូរនោះអាចសម្រេចបាន។

**ច. ការរៀបចំរបាយការណ៍**

ក្រោយពីបញ្ចប់វគ្គ០៦ខែ សិក្ខាកាមម្នាក់ៗត្រូវរៀបចំរបាយការណ៍បញ្ចប់វគ្គមួយដែលរបាយការណ៍បញ្ចប់វគ្គនេះ នឹងត្រូវវាយតម្លៃដោយគណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស។ គណៈកម្មការនេះត្រូវរៀបចំលក្ខណៈវិនិច្ឆ័យ និងវិធីសាស្ត្រដែលមានតម្លាភាព និងយោងតាមរបាយការណ៍វាយតម្លៃរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ។ សិក្ខាកាមម្នាក់ៗ នឹងទទួលបានវិញ្ញាបនបត្រនៅចុងបញ្ចប់នៃកម្មវិធីនេះ ទៅតាមលទ្ធផលនៃការវាយតម្លៃ។

កម្រិតនៃវិញ្ញាបនបត្រ នឹងចែកចេញជា៣ថ្នាក់គឺ៖ កម្រិត A កម្រិត B និង កម្រិត C ។ វិញ្ញាបនបត្រនេះនឹងត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការគ្រប់គ្រងមណ្ឌល និង អភិបាលខេត្ត។ សិក្ខាកាមដែលបានបញ្ចប់វគ្គនេះនឹងជាបេក្ខជនមានសក្តានុពលសម្រាប់មុខដំណែងថ្នាក់ដឹកនាំនាពេលអនាគត។

**ឆ. សិក្ខាសាលាឆ្លុះបញ្ចាំងបញ្ចប់វគ្គ**

ក្រោយពីបញ្ចប់វគ្គសិក្សានៅតាមមូលដ្ឋាន សិក្ខាសាលាមួយនឹងរៀបចំឡើងដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ទាំង១២៧ ដើម្បីសិក្សារៀនសូត្រពីអ្វីដែលសិក្ខាកាមបានសិក្សា និងអនុសាសន៍ដែលសិក្ខាកាមលើកឡើង។ សិក្ខាសាលានេះ នឹងផ្តោតសំខាន់ឱ្យសិក្ខាកាមដែលមានរបាយការណ៍ល្អចំនួន ៥នាក់ ធ្វើបទបង្ហាញសង្ខេបពីរបាយការណ៍របស់ខ្លួន និងស្នើសុំក្រុមប្រឹក្សាឃុំដែលសិក្ខាកាមបានចុះសិក្សាផ្ទាល់ចំនួន ០៣នាក់ លើកឡើងពីមេរៀន បទពិសោធន៍ ដែលទទួលបានពីសិក្ខាកាម ក្នុងអំឡុងពេល ចុះសិក្សារបស់សិក្ខាកាម និងវាយតម្លៃពីគម្រោងនេះផងដែរ។

ជាលទ្ធផលនៃការអនុវត្តគម្រោងអភិវឌ្ឍសមត្ថភាពអ្នកដឹកនាំវ័យក្មេងក្នុងជំនាន់ទី១នេះ មានសិក្ខាកាមចូលរួមចំនួន២៥នាក់ ក្នុងនោះស្ត្រី០៧នាក់ ដែលជាមន្ត្រីរាជការវ័យក្មេងមកពីសាលាខេត្តកណ្តាល សាលាស្រុកកណ្តាលស្ទឹង សាលាស្រុកល្វាឯម សាលាស្រុកលើកដែក និងមន្ទីរអប់រំ យុវជន និងកីឡា។ តាមរយៈការសម្ភាសន៍ជាមួយសិក្ខាកាមមួយចំនួន បានឱ្យដឹងថា បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេងនេះ សមត្ថភាពបំពេញការងាររបស់ពួកគាត់មានភាពល្អប្រសើរជាងមុន ជាពិសេសពាក់ព័ន្ធការងារគ្រប់គ្រង ការងាររដ្ឋបាល ការងារអភិវឌ្ឍន៍មូលដ្ឋាន និងការងារផ្តល់សេវា ក៏ដូចការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន ព្រមទាំងជាមួយសិក្ខាកាមរួមជំនាន់។ដោយមានការវាយតម្លៃខ្ពស់ពីថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តកណ្តាល ក៏ដូចពីសិក្ខាកាមលើលទ្ធផលនៃការអនុវត្តគម្រោងអភិវឌ្ឍន៍សមត្ថភាពអ្នកដឹកនាំវ័យក្មេងជំនាន់ទី១នេះ ក្នុងឆ្នាំ២០១៧ រដ្ឋបាលខេត្តកណ្តាលក៏គ្រោងនឹងចាប់ផ្តើមគម្រោងនេះ បន្តទៀតសម្រាប់សិក្ខាកាមជំនាន់ទី២ផងដែរ។

*ដោយ លឹម ពុទ្ធារី*

ឯកសារយោង៖

-គម្រោងអភិវឌ្ឍន៍សមត្ថភាពអ្នកដឹកនាំវ័យក្មេង ខេត្តកណ្តាល ឆ្នាំ២០១៧

# អ្នកដឹកនាំកើតពីកំណើត ឬពីការរៀន?

## តើអ្វីអាចបង្រៀនបាន ហើយអ្វីមិនអាចបង្រៀនបាន?

*អត្ថបទនេះ ចុះផ្សាយដោយ Jack and Suzywelch លើ LinkedIn កាលពីថ្ងៃទី០២ ឧសភា ឆ្នាំ២០១៦។*

សម្រាប់មនុស្សមួយចំនួន សំណួរដែលសួរថា តើអ្នកដឹកនាំកើតពីកំណើត ឬមកពីការរៀនគឺនៅតែជាបញ្ហាមិនដាច់ស្រឡះ។ ទាំងនេះ ហាក់ដូចជា



*លោក Jack Welch ជានាយកប្រតិបត្តិ*

ការជជែកដេញដោលគ្នាថាតើគួរមានអាហារនៅថ្នាក់រៀន ឬគួររៀបចំពិធីជប់លៀងអាហារពេលល្ងាច។

ប៉ុន្តែសម្រាប់អ្នកដែលមានតួនាទីជួរមុខក្នុងការជ្រើសរើស តែងតាំង ក៏ដូចបញ្ឈប់ការងារ អ្វីដែលគួរសួរជាងនេះ នោះគឺ " តើមនុស្សបែបណាដែលមានលក្ខណសម្បត្តិត្រឹមត្រូវក្នុងការដឹកនាំ? "

ប្រសិនបើអាចទទួលបានចម្លើយត្រឹមត្រូវ នោះនឹងអាចធ្វើឱ្យវប្បធម៌ក៏ដូចការបំពេញការងាររបស់ស្ថាប័ននោះរីកចម្រើនទៅកាន់កម្រិតមួយថ្មី។ ប៉ុន្តែប្រសិនបើទទួលបានចម្លើយមិនត្រឹមត្រូវនោះនឹងធ្វើឱ្យស្ថាប័នធ្លាក់ចុះទៅវិញ។

ហេតុនេះ អ្វីទៅជាចម្លើយ? ពិតណាស់ នៅទីនេះយើងនិយាយអំពីជីវិតពិត មិនមែននិយាយអំពីអ្វីដែលល្អរៀបរយ ឬសាមញ្ញនោះទេ។ ការពិតគឺថា លក្ខណសម្បត្តិរបស់អ្នកដឹកនាំមួយចំនួនមានពីកំណើត ហើយនោះគឺជាអ្វីដែលជាការប្រទានល្អដ៏ប្រសើរ។ លក្ខណសម្បត្តិទាំងនោះមានអត្ថន័យខ្លាំងណាស់។ ផ្ទុយទៅវិញ មានលក្ខណសម្បត្តិសំខាន់ពីររបស់អ្នកដឹកនាំ ដែលអាចអភិវឌ្ឍបានតាមរយៈការបណ្ដុះបណ្ដាល និងបទពិសោធន៍។ តាមពិតលក្ខណសម្បត្តិទាំងពីរនេះ គឺត្រូវតែបែបនេះ។ ទោះជាយ៉ាងនេះក្ដី មុននឹងយើងនិយាយអ្វីបន្តទៀត យើងត្រូវដឹងអំពីនិយមន័យ នៃភាពជាអ្នកដឹកនាំសិន។ ភាពជាអ្នកដឹកនាំមានលក្ខណសម្បត្តិចម្បងប្រាំយ៉ាង។ ប៉ុន្តែលក្ខណសម្បត្តិទាំងនេះមិនគិតបញ្ចូល ពី " សុចរិតភាព " ទេ ដោយសារសុចរិតភាពគឺជាតម្រូវការចាំបាច់ ទោះក្នុងតួនាទីដឹកនាំបែបណាក៏ដោយក៏មិនគិតបញ្ចូលពី " ភាពឆ្លាតវៃ " ដែរ ដោយសារភាពឆ្លាតវៃត្រូវចាត់ទុកជាសំបុត្រ មួយសម្រាប់ចូលលេងល្បែងនៅក្នុងទីផ្សារពិភពលោកដ៏ស្មុគស្មាញនាពេលបច្ចុប្បន្ននេះ។ ហើយលក្ខណសម្បត្តិទាំងនេះក៏មិនគិតបញ្ចូលផងដែរអំពី " ភាពចាស់ទុំនៃអារម្មណ៍ " ដែលជាលក្ខណសម្បត្តិចាំបាច់មួយផ្សេងទៀត។ លក្ខណសម្បត្តិទាំងបីនេះគឺជាមូលដ្ឋានដែលគេទទួលស្គាល់ជាទូទៅ។

ក្រៅពីនេះតើមានអ្វីទៀត? តាមបទពិសោធន៍របស់យើង លក្ខណសម្បត្តិចម្បងទីមួយ សម្រាប់អ្នកដឹកនាំគឺថាមពលជាវិជ្ជមាន (Positive energy)

ដែលជាសមត្ថភាពជំរុញឱ្យដើរទៅមុខជានិច្ចជាមួយនឹងភាពរឹងមាំដ៏ប្រាកដប្រជា និងឥរិយាបថ ទាំងនៅក្នុងអំឡុងពេលអំណោយផល និងពេលពិបាក។

លក្ខណសម្បត្តិទីពីរ គឺសមត្ថភាពផ្តល់ថាមពលឱ្យអ្នកដទៃ (Ability to energize others) ដើម្បីឱ្យអ្នកទាំងនោះបញ្ចេញថាមពល ជាវិជ្ជមានរបស់ពួកគេក្នុងការធ្វើដំណើរឡើងលើទីទួលបែបណាក៏ដោយ។

លក្ខណសម្បត្តិទីបី គឺភាពមុតស្រួច (Edge) ដែលជាសមត្ថភាពក្នុងការធ្វើការងារពិបាកៗដើម្បីសម្រេច " Yes " ឬ " No " ដោយមិនប្រហែល។

លក្ខណសម្បត្តិទីបួន គឺទេពកោសល្យក្នុងការអនុវត្ត (Talent to execute) ដែលជាសមត្ថភាពក្នុងការបំពេញការងារបានល្អ ដោយប្រើប្រាស់វិធីសាមញ្ញៗ។

លក្ខណសម្បត្តិទីប្រាំ និងចុងក្រោយគឺ អ្នកដឹកនាំត្រូវមានឆន្ទៈខ្ពស់ (Passion) ។ អ្នកទាំងនោះគិតគូរជ្រៅជ្រះ។ អ្នកទាំងនោះមានការប្តេជ្ញាចិត្ត និងមានការជឿជាក់។

ដូចលោកអ្នកអាចយល់ ថាមពលជាវិជ្ជមាន និងសមត្ថភាពផ្តល់ថាមពលឱ្យអ្នកដទៃគឺមានលក្ខណៈមកពីកំណើតច្រើន។ លក្ខណសម្បត្តិទាំងនេះ ជាធម្មតាគឺជាបុគ្គលិកលក្ខណៈ(Personality)។ ក៏ដូចគ្នា "ឆន្ទៈខ្ពស់" ក៏មានលក្ខណៈមកពីកំណើតដែរ។ មនុស្សមួយចំនួនកើតមក គឺពោរពេញទៅដោយកម្លាំង និងការចង់ចេះ ចង់ដឹង។ ជាធម្មជាតិ អ្នកទាំងនោះតែងតែស្រឡាញ់អ្នកដទៃ ជីវិត និងការងាររបស់ខ្លួន។ ហើយអ្វីៗទាំងនោះ គឺនៅក្នុងខ្លួនរបស់ពួកគេ។ អ្នកដឹកនាំ គឺអ្នកទាំងនោះហើយ។ ភាពមុតស្រួច និងសមត្ថភាពក្នុងការអនុវត្ត គឺខុសពីលក្ខណសម្បត្តិទាំង០៣ខាងលើ។ បុគ្គលិកដែលទើបចូលធ្វើការ កម្រមានអ្នកដែលមានសមត្ថភាពគ្រប់គ្រាន់រួចហើយណាស់ សូម្បីតែអ្នកគ្រប់គ្រងកម្រិតកណ្តាល(Middle managers) ក៏ទទួលអត្ថប្រយោជន៍ពីការបណ្តុះបណ្តាលលើលក្ខណសម្បត្តិទាំងពីរនេះដែរ។ ប៉ុន្តែគ្រូដ៏ប្រសើរបំផុតសម្រាប់លក្ខណសម្បត្តិទាំងពីរនេះគឺ សង្គ្រាមត្រង់សេ (Trench warfare)។ នេះគឺដោយសារភាពមុតស្រួច និងការអនុវត្ត ភាគច្រើន គឺជាមុខងារនៃការជឿជាក់ខ្លួនឯង។ លោកអ្នកអាចនិយាយបានថា " Yes " ឬ " NO " កាន់តែប្រសើរឡើង នៅពេលអ្នកបានធ្វើកិច្ចការទាំងនោះជាច្រើនដង ហើយអាចយល់ថា ការសម្រេចចិត្តទាំងនោះបានល្អបែបណា។

ដូចគ្នានេះដែរ គឺមានតែនៅក្នុងការប្រឈមនៅក្នុងពិភពពិតតែប៉ុណ្ណោះ ដែលអ្នកគ្រប់គ្រងអាចមានអារម្មណ៍ពិតប្រាកដ អំពីអំណាចនៃការធ្វើចលនាដោយលឿន ការទាមទារគណនេយ្យភាព និងការផ្តល់រង្វាន់នៅពេលទទួលលទ្ធផល។ អ្នកទាំងនោះក៏អាចដកពិសោធន៍ផងដែរថាតើការខូចខាតនឹងមានយ៉ាងណានៅពេលដែលមិនអនុវត្ត ដែលនេះគឺជាកំហុសមួយដែលអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពមិនឱ្យមានជាលើកទី២។

សរុបមក តើអ្នកដឹកនាំកើតមកពីកំណើត ឬពីការរៀនសូត្រ? ចម្លើយ (ប្រហែលជាមិនភ្ញាក់ផ្អើលច្រើននោះទេ)គឺទាំងពីរ។ ហេតុនេះ យុទ្ធសាស្ត្រប្រសើរបំផុតសម្រាប់អ្នកគឺ រកមនុស្សណាដែលមានថាមពល មានសមត្ថភាពផ្តល់ថាមពល និងមានឆន្ទៈខ្ពស់។ បន្ទាប់មក ប្រើឱ្យអស់កម្លាំងកាយ

ក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍភាពមុតស្រួច និងការអនុវត្ត។ ដំឡើងឋានៈ ដល់អ្នកដែលមានលក្ខណសម្បត្តិទាំងប្រាំនេះ។ ទោះជាយ៉ាងនេះក្តី សូមចងចាំថា មិនមែនអ្នកគ្រប់គ្នាត្រូវតែជាអ្នកដឹកនាំនោះទេ។ ប៉ុន្តែប្រសិនបើអ្នកជាអ្នកដឹកនាំ នោះការងាររបស់អ្នកគឺត្រូវស្វែងរក និងកសាងមនុស្សដែលមានភាពជាអ្នកដឹកនាំ៕

Jack Welch ជានាយកប្រតិបត្តិនៃ Jack Welch Management Institute និងជាអតីតនាយកប្រតិបត្តិ(CEO) នៃក្រុមហ៊ុន General Electric (GE)៕

Suzy Welch ជាសហអ្នកនិពន្ធសៀវភៅ "The Real-life MBA-Your No-BS Guide to Winning the Game, Building a team, and Growing the Game, Building a Team, and Growing Your Career" ជាមួយលោក Jack Welch៕

*ប្រែសម្រួលដោយ សូ មុនីរក្សា*

# ការអភិវឌ្ឍមូលដ្ឋានប្រកបដោយសមធម៌

## ~ បទពិសោធន៍ដឹកនាំនៅរដ្ឋបាលខេត្តកណ្ដាល ~



*ឯកឧត្តមបណ្ឌិត **ម៉ៅ ភិរុណ** អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល*

*"ខ្ញុំចង់ឃើញប្រជាពលរដ្ឋរស់នៅដោយសុខសាន្ត និងមានជីវភាពរស់នៅធូរធារ"។*

នេះជាឆន្ទៈ និងការប្ដេជ្ញាចិត្តដ៏មុះមុតរបស់**ឯ.ឧ បណ្ឌិត ម៉ៅ ភិរុណ** អភិបាលនៃគណៈអភិបាលខេត្តកណ្ដាលដែលបានថ្លែងប្រាប់ក្រុមការងារ ក្នុងឱកាសដែលក្រុមការងារចុះសិក្សាស្វែងយល់អំពីបទពិសោធន៍អភិវឌ្ឍន៍ខេត្តកណ្ដាលនាពេលថ្មីៗកន្លងមកនេះ។

ខេត្តកណ្ដាល ជាខេត្តមួយក្នុងចំណោមរាជធានីខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា និងមានព្រំប្រទល់ខាងលិចទល់នឹងខេត្តកំពង់ស្ពឺ ខាងកើតទល់នឹងខេត្តព្រៃវែង ខាងជើងទល់នឹងខេត្តកំពង់ឆ្នាំងកំពង់ចាម ខាងត្បូងទល់នឹងខេត្តតាកែវ និងខេត្តអានយ៉ាងនៃប្រទេសវៀតណាម។ ខេត្តកណ្ដាលមានផ្ទៃដីសរុប៣.២១១,៧៥៩គ.ម$^2$ មានក្រុងចំនួន១ ស្រុកចំនួន១០ ឃុំសង្កាត់ចំនួន១២៧ និងភូមិចំនួន១.០១០ និងមានប្រជាពលរដ្ឋសរុបចំនួន១.១៨០.៨៩១នាក់ ស្រី៦១០.៦៦៧នាក់ ក្នុងនោះប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងមាន៧៤០.៦០៧នាក់ និងចំនួនគ្រួសារមាន២៤៩.៨៥៦គ្រួសារ។ ខេត្តកណ្ដាលមានសក្ដានុពលលើការងារបង្កបង្កើនផលស្រូវ ដំណាំអនុផល នេសាទ និងជាមូលដ្ឋាននៃអាជីវកម្ម ឧស្សាហកម្មផងដែរ។[1]

**ឯ.ឧ បណ្ឌិត ម៉ៅ ភិរុណ** ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាតែងតាំងឱ្យកាន់មុខតំណែងជាអភិបាលខេត្តកណ្ដាលនៅក្នុងឆ្នាំ២០១៥។ ដោយឈរលើ

[1] http://www.kandal.cambodia.gov.kh *(ថ្ងៃទី៣០ មិថុនា ២០១៧)*



*ពិធីអបអរក្រុងតាខ្មៅ ទទួលបានពានរង្វាន់* ***រំដួលពីទង ទីក្រុងស្អាត***

ទស្សនវិស័យចង់ឃើញប្រជាពលរដ្ឋនៅក្នុងខេត្តកណ្តាលរស់នៅដោយសុខសាន្ត និងមានជីវភាពរស់នៅធូរធារ ស្របតាមទស្សនវិស័យនៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០១៥-២០១៩) របស់រដ្ឋបាលខេត្តកណ្តាល ដែលបានកំណត់ថា "ប្រជាជនទូទាំងខេត្តមានជីវភាពរស់នៅ និងសុខុមាលភាពល្អប្រសើរប្រកបដោយសីលធម៌ សមធម៌យេនឌ័រក្នុងសង្គមមួយដែលមានសន្តិភាព ស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរស់នៅក្នុងបរិស្ថានស្អាតស្អំ"។ ក្រោមការដឹកនាំរបស់ឯកឧត្តមអភិបាលខេត្តក្នុងរយៈពេលកន្លងមកនេះ បានធ្វើឱ្យខេត្តកណ្តាលមានការអភិវឌ្ឍលើវិស័យជាច្រើនគួរឱ្យកត់សម្គាល់។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍទាំងនេះមិនបានប្រមូលផ្តុំតែនៅតំបន់ទីក្រុង ឬទីប្រជុំជននោះទេ តែបានពង្រាយនៅតាមតំបន់ជនបទនានាជាច្រើនទៀតនៅទូទាំងខេត្តកណ្តាលទាំងមូល។

នៅតាមតំបន់ទីក្រុងយើងសង្កេតឃើញសកម្មភាពរបស់ប្រជាពលរដ្ឋមានការប្រែប្រួលច្រើន។ ប៉ុន្មានឆ្នាំមុននេះ ប្រជាពលរដ្ឋភាគច្រើនតែងមកលំហែកាយ ឬមកទិញទំនិញ សម្ភារប្រើប្រាស់នានា នៅរាជធានីភ្នំពេញដែលស្ថិតនៅជាប់នឹងទីក្រុងតាខ្មៅ។ ប៉ុន្តែ បច្ចុប្បន្នយើងសង្កេតឃើញ សកម្មភាពនៅទីក្រុងតាខ្មៅមានភាពរស់រវើក និងមមាញឹក មិនចាញ់នៅភ្នំពេញប៉ុន្មានឡើយ។ សកម្មភាពហាត់ប្រាណ លំហែកាយការលក់ដូររបស់អាជីវករ ក៏ដូចសកម្មភាពទិញទំនិញរបស់បងប្អូនប្រជាពលរដ្ឋនៅតាមទីផ្សារមានការកើនឡើងគួរឱ្យចាប់អារម្មណ៍ ដែលយើងអាចសង្កេតឃើញភាពមមាញឹកនេះមានចាប់តាំងពីពេលព្រឹកព្រលឹម រហូតដល់ពេលយប់។ ទន្ទឹមនេះ



*សួនច្បារមាត់ទន្លេក្រុងតាខ្មៅ ខេត្តកណ្តាល*



សមិទ្ធផលផ្លូវបេតុងក្នុងស្រុកស្អាង ខេត្តកណ្តាល

ផ្លូវថ្នល់ក្រាលកៅស៊ូ/បេតុង ភ្លើងបំភ្លឺសាធារណៈ និងអគ្គិសនីក៏បានអភិវឌ្ឍរហូតដល់តាមឃុំ ស្រុក ដែលជាតំបន់ជនបទ ទន្ទឹមនឹងប្រព័ន្ធ ធារាសាស្ត្រ ក៏ត្រូវបានកសាងបន្ថែម និងកែលម្អឡើងវិញ ដែលកត្តាទាំងនេះបានចូលរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ការកាត់បន្ថយចំណាយក្នុងការធ្វើដំណើរ និងដឹកជញ្ជូន និងបានធ្វើឱ្យប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទមានឱកាស និងលទ្ធភាពកាន់តែច្រើនឡើង ក្នុងការពង្រឹងពង្រីកធុរកិច្ច ក៏ដូចការប្រកបមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្លួន។

នៅពេលដែលក្រុមការងារចង់ដឹងអំពីការប្រែប្រួលជារួមនៅក្នុងខេត្ត ឯកឧត្តមអភិបាលខេត្តបានលើកឡើងថា ក្នុងមួយរយៈកន្លងមកនេះ មានការប្រែប្រួលច្រើន ពោលគឺ "អ្វីដែលពីមុនអត់មាន ឥឡូវមាន អ្វីដែលពីមុនមានតិច ឥឡូវមានច្រើន"។ ជាមួយនេះ ឯកឧត្តមក៏បានកត់សម្គាល់ថា ប្រជាពលរដ្ឋជាទូទៅនៅក្នុងខេត្តកណ្តាល ក៏មានការចាប់អារម្មណ៍យ៉ាងខ្លាំង និងមានភាពរីករាយចំពោះការប្រែប្រួលទាំងនេះដែរ។

ដើម្បីស្វែងយល់បន្ថែម អំពីយុទ្ធសាស្ត្រនៃការដឹកនាំ គ្រប់គ្រងនៅរដ្ឋបាលខេត្តកណ្តាល ក្រុមការងារក្រសួងមហាផ្ទៃមានកិត្តិយសដោយបានជួបជាមួយឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាលនៃគណៈអភិបាលខេត្តកណ្តាលនាពេលថ្មីៗកន្លងមកនេះ។

ឆ្លើយតបទៅនឹងសំណួររបស់ក្រុមការងារ ពាក់ព័ន្ធកត្តាដែលធ្វើឱ្យរដ្ឋបាលខេត្តកណ្តាលអាចសម្រេចបាន ពិសេសសមិទ្ធផលនៅតាមតំបន់ជនបទក្នុង



ឯកឧត្តមបណ្ឌិត ***ម៉ៅ ភិរុណ*** ចុះពិនិត្យស្ថានីយបូមទឹកនៅស្រុកកណ្តាលស្ទឹង

ខេត្តកណ្ដាល ឯកឧត្តមអភិបាលខេត្តបានឱ្យក្រុមការងារដឹងថា "ទស្សនវិស័យចម្បងក្នុងការដឹកនាំរបស់ខ្ញុំគឺ *ខ្ញុំចង់ឃើញប្រជាពលរដ្ឋរស់នៅដោយសុខសាន្ត និងមានជីវភាពរស់នៅធូរធារ*"។ ដើម្បីសម្រេចបានទស្សនវិស័យនេះ ឯកឧត្តមបានលើកឡើងទៀតថា មានការងារចាំបាច់ជាច្រើនដែលរដ្ឋបាលខេត្តកណ្ដាលត្រូវធ្វើ និងគិតគូរដោយម៉ត់ចត់ ប៉ុន្តែក្នុងនោះអ្វីៗត្រូវធានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយសមធម៌ ដែលចំណុចនេះឯកឧត្តមអភិបាលខេត្តគិតថា គឺជាចំណុចគន្លឹះសំខាន់ក្នុងការធានាឱ្យប្រជាពលរដ្ឋទូទាំងខេត្តកណ្ដាលមានជីវភាពរស់នៅធូរធារ អាចរស់នៅ ដោយសុខសាន្ត ប្រកបដោយសុខុមាលភាពល្អប្រសើរ។


*ឯកឧត្តមបណ្ឌិត **ខៅ ភិរុណ** ចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមមូលដ្ឋាន*

អ្វីដែលឯកឧត្តមអភិបាលខេត្តបានលើកឡើងនេះ បានបញ្ជាក់ឱ្យយើងឃើញជាក់ស្ដែងតាមរយៈការរៀបចំគម្រោងវិនិយោគរបស់រដ្ឋបាលខេត្តកណ្ដាល។ បើយើងពិនិត្យមើលកម្មវិធីវិនិយោគរបស់រដ្ឋបាលខេត្ត យើងឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំ គម្រោងវិនិយោគមានការកើនឡើងជាបន្តបន្ទាប់។ ក្នុងឆ្នាំ២០១៧ តម្លៃគម្រោងវិនិយោគមានប្រមាណ ២៧.៤៦៣លានរៀល ដែលតួលេខនេះមានការកើនឡើងប្រមាណជា២៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៥។ ទន្ទឹមនេះ បើយើងពិនិត្យមើលទៅលើប្រភេទគម្រោងវិនិយោគទាំងនេះ យើងសង្កេតឃើញថា រដ្ឋបាលខេត្តកណ្ដាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់ជនបទ ក្នុងនោះ ក្នុងចំណោមគម្រោងផ្នែកសេដ្ឋកិច្ចទាំង៥៥គម្រោងដែលបានអនុវត្តក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ចំនួនគម្រោងនៅតំបន់ជនបទមានរហូតដល់២៩គម្រោង ពោលគឺមានប្រមាណពាក់កណ្ដាលនៃចំនួនគម្រោងទាំងមូល។ កត្តានេះសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រដ្ឋបាលខេត្ត ក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយសមធម៌ ជាពិសេសនៅតំបន់ជនបទដែលមានការរីកចម្រើនយឺតជាងតំបន់ទីក្រុង ឬទីប្រជុំជនដទៃទៀត។

ក្រៅពីគម្រោងផ្នែកសេដ្ឋកិច្ច រដ្ឋបាលខេត្តក៏បានយកចិត្តទុកដាក់ផងដែរទៅលើផ្នែកសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ គ្រប់គ្រងធម្មជាតិ និងសង្គមកិច្ច សំដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ក្នុងនោះ សមិទ្ធផលសំខាន់ៗដែលរដ្ឋបាលខេត្តសម្រេចបានមានជាអាទិ៍៖

- ការសាងសង់ផ្លូវគមនាគមន៍ និងលូទឹកនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ
- ការសាងសង់អគាររដ្ឋបាលសម្រាប់រដ្ឋបាលនៅថ្នាក់ស្រុក និងឃុំ

–ការពង្រីកនិងកែលម្អបណ្តាញប្រព័ន្ធធារាសាស្ត្រ

–ការតម្លើងបំភ្លឺសាធារណៈតាមផ្លូវ ស្ពាន និងសួនច្បារ

–ពង្រីកបណ្តាញទឹកស្អាត និងអគ្គិសនីនៅតាមទីជនបទ ជាដើម។

*តើយើងត្រូវធ្វើដូចម្តេច ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយសមធម៌?*

ឆ្លើយតបទៅនឹងសំណួរនេះ ឯកឧត្តមបានសង្កត់ធ្ងន់ថា កត្តាសំខាន់ និងដំបូងបំផុតគឺ ឆន្ទៈ និងការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំ។ អ្នកដឹកនាំត្រូវតែមានឆន្ទៈច្បាស់លាស់ និងការប្តេជ្ញាចិត្តមុះមុតនិងមិនរាថយនៅក្នុងការអនុវត្តកិច្ចការនានាប្រកបដោយទស្សនវិស័យរីកចម្រើន និងមានភាពជាអ្នកដឹកនាំល្អប្រសើរ។

ឯកឧត្តមបានបន្ថែមទៀតថា ក្រៅពីមានឆន្ទៈ និងការប្តេជ្ញាចិត្តដោយពិតប្រាកដហើយ យើងត្រូវខិតខំស្វះស្វែងរកគ្រប់យុទ្ធសាស្ត្រ និងមធ្យោបាយដើម្បីសម្រេចឱ្យបាននូវអ្វីដែលយើងចង់បាន ចង់ឃើញនោះ។ សម្រាប់ឯកឧត្តម កត្តាដែលឯក-ឧត្តមគិតថា ឯកឧត្តមអាចសម្រេចបានលទ្ធផលក្នុងការដឹកនាំ គ្រប់គ្រងនៅរដ្ឋបាលខេត្តកណ្តាលដូចសព្វថ្ងៃនេះ គឺអាស្រ័យលើកត្តាសំខាន់ៗចំនួនប្រាំដូចខាងក្រោម៖

***មួយ៖ ពង្រឹងរបៀបរបបការងារ។*** របៀបរបបគ្រប់គ្រងថ្មីនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទើបតែចាប់ផ្តើមអនុវត្តមិនទាន់បានដប់ឆ្នាំនៅឡើយទេ។ ហេតុនេះ មានកិច្ចការជាច្រើនដែលថ្នាក់ជាតិបាន និងកំពុងធ្វើការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅធានាឱ្យរដ្ឋបាលនីមួយៗអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនបានល្អប្រសើរ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀត។ ដោយយល់ឃើញពីកត្តាសត្យានុម័តនេះ ឯកឧត្តមអភិបាលខេត្តបានចាត់ទុកថា ការអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមការណែនាំពីថ្នាក់ជាតិ និងការលើកទឹកចិត្ត ដល់មន្ត្រីរាជការដែលកំពុងបំពេញការងារនៅតាមអង្គភាពនានានៅក្នុងរដ្ឋបាលខេត្ត គឺជាកត្តាសំខាន់ដែលអាចធានានូវប្រសិទ្ធិភាព និងភាពស័ក្តិសិទ្ធក្នុងការបំពេញតួនាទីភារកិច្ចរបស់មន្ត្រីរាជការ។ ក្នុងន័យនេះ ដើម្បីជាគំរូ



*ឯកឧត្តមបណ្ឌិត **ឃឿង ស្រេង*** *កាត់ខ្សែបូរសម្ពោធសមិទ្ធផលថ្មីក្នុងខេត្ត*

ដល់អ្នកដទៃទៀត ឯកឧត្តមផ្ទាល់ខ្លួនតែងតែព្យាយាម អនុវត្តតាមការណែនាំពីថ្នាក់ជាតិជាប្រចាំដោយមិន ធ្វេសប្រហែស ក្នុងនោះមានដូចជា ការព្យាយាម ចូលរួមក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្តក៏ដូច វេទិកាសាធារណៈ ការព្យាយាមអនុវត្តជាទៀងទាត់ នូវរបបប្រជុំជាមួយគណៈអភិបាលក៏ដូចជាមួយ មន្ត្រីរាជការនៅក្នុងរដ្ឋបាលខេត្តទាំងមូល និងការ ខិតខំបន្តផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំក៏ដូចមន្ត្រីរាជការ



ឯកឧត្តមបណ្ឌិត **ម៉ៅ ធនិណ** ចុះត្រួតពិនិត្យតាមមូលដ្ឋាន

ដទៃទៀតអំពីច្បាប់ អនុក្រឹត្យ និងសេចក្តីណែនាំ ឬ កិច្ចការដទៃទៀតដែលឯកឧត្តមផ្ទាល់ទទួលបានពី ថ្នាក់ជាតិ ឬពីប្រភពដទៃទៀតជាដើម។ល។ តាម រយៈការអនុវត្តជាប្រចាំនូវកិច្ចការទាំងនេះ ឯកឧត្តម មានឱកាសជាច្រើនក្នុងការធ្វើការងារ ពិភាក្សា ការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក៏ដូច ស្តាប់មតិយោបល់ និងបញ្ហាប្រឈម ដែលអ្នកទាំង នោះកំពុងជួបប្រទះក្នុងការបំពេញតួនាទី ភារកិច្ច របស់ខ្លួន។ ជាមួយនេះ ឯកឧត្តមក៏បានប្រើប្រាស់ ឱកាសទាំងនេះ ដើម្បីធ្វើការណែនាំ និងផ្តល់អនុ-សាសន៍ដល់អ្នកពាក់ព័ន្ធ សំដៅដោះស្រាយនូវ រាល់បញ្ហានានាដែលឯកឧត្តមផ្ទាល់បានដឹង បានឮ តាមរយៈការលើកឡើងរបស់មន្ត្រីរាជការ ការចុះ ជួបប្រជាពលរដ្ឋនៅមូលដ្ឋាន ឬក្នុងពិធីផ្សេងៗ ជាដើម។ ទន្ទឹមនេះ ឯកឧត្តមក៏បានយកចិត្ត ទុកដាក់ផងដែរក្នុងការលើកទឹកចិត្តដល់មន្ត្រី ក្នុង នោះមានដូចជា ការឧបត្ថម្ភផ្សេងៗ ការលើក ទឹកចិត្ត និងលើកសរសើរដោយផ្ទាល់ ការផ្តល់ ប័ណ្ណសរសើរ ការផ្តល់ មេដាយការងារ ការផ្តល់ អាហារូបករណ៍ ការធានា មិនឱ្យខ្វះខាតសម្ភារការិ-យាល័យសម្រាប់បំពេញ ការងារ និងការលើក កម្ពស់តម្លាភាពក្នុងការ បំពេញការងារជាដើម។ ម្យ៉ាងទៀត ក្នុងនាមឯក-ឧត្តមជាអភិបាលខេត្ត ដែលទទួលខុសត្រូវក្នុង ការដឹកនាំ គ្រប់គ្រងកិច្ចការនានានៅក្នុងដែន សមត្ថកិច្ចនៃខេត្តកណ្តាលតាមគោលការណ៍នៃ រដ្ឋបាលឯកភាព ឯកឧត្តមក៏បានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយមន្ទីរ អង្គភាពនានានៅជុំវិញខេត្តផងដែរ ដើម្បី លើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពនៃ ការបំពេញការងាររបស់មន្ទីរ អង្គភាពទាំងនោះ ជាមួយរដ្ឋបាលខេត្ត។ ជាលទ្ធផល ឯកឧត្តម សង្កេតឃើញថា អាកប្បកិរិយា និងឥរិយាបថបំពេញ ការងាររបស់មន្ត្រីមានការប្រែប្រួលគួរឱ្យកត់សម្គាល់

ទាំងមន្ត្រីបម្រើការងារនៅរដ្ឋបាលខេត្ត និងនៅតាមមន្ទីរ អង្គភាពជំនាញជុំវិញខេត្ត ដែលកត្តានេះបានធ្វើឱ្យប្រជាពលរដ្ឋមានការពេញចិត្ត និងសប្បាយរីករាយ ចំពោះការបម្រើសេវាសាធារណៈនៅក្នុងខេត្ត ព្រមទាំងបានលើកកម្ពស់ការជឿជាក់របស់ប្រជាពលរដ្ឋចំពោះអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនៅក្នុងខេត្តកណ្តាលថែមទៀតផង។

***ពីរ៖ មានផែនការច្បាស់លាស់ និងធ្វើការតាមដាន ត្រួតពិនិត្យជាប្រចាំ។*** ការងារធ្វើផែនការជាការងារសំខាន់ដែលមិនអាចខ្វះបានសម្រាប់អ្នកដឹកនាំ។ ការធ្វើផែនការ បានផ្តល់ផលប្រយោជន៍ច្រើន ក្នុងនោះមានដូចជា ការតម្រែតម្រង់ទិសបានច្បាស់លាស់ កាត់បន្ថយឥទ្ធិពលនៃការប្រែប្រួល កាត់បន្ថយការខ្ជះខ្ជាយ កាត់បន្ថយកម្រិតគ្រោះថ្នាក់ និងអាចកាត់បន្ថយនូវភាពច្របូកច្របល់ដែល។ល។[2] ផ្ទុយទៅវិញការបំពេញការងារដោយគ្មានផែនការ ប្រៀបបីដូចជាការបំពេញការងារដោយគ្មានគោលដៅ គ្មានទិសដៅច្បាស់លាស់ ជាការបំពេញការងារដោយចៃដន្យ ផ្អែកតាមស្ថានភាពកើតឡើងជាក់ស្តែងចំពោះមុខ។ ការបំពេញការងារបែបនេះ ពុំមានប្រសិទ្ធភាពឡើយ ជាពិសេសសម្រាប់ថ្នាក់ដឹកនាំនៅតាមអង្គភាព ស្ថាប័ន។ នៅក្នុងន័យនេះ ឯកឧត្តមអភិបាលខេត្តបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការរៀបចំផែនការទាំងផែនការប្រចាំថ្ងៃរបស់ឯកឧត្តមក៏ដូចរបស់រដ្ឋបាលខេត្ត ព្រមទាំងផែនការរយៈពេលមធ្យម និងវែងរបស់រដ្ឋបាលខេត្តដែលរៀបចំឡើងសំដៅដោះស្រាយបញ្ហាប្រឈម ក៏ដូចសំណើសំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដទៃទៀត។ ទន្ទឹមនេះ ឯកឧត្តមក៏បានធ្វើការតាមដានត្រួតពិនិត្យជាប្រចាំផងដែរ ក្នុងការអនុវត្តផែនការទាំងនេះ ជាពិសេសនៅក្នុងឱកាសនៃកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធ។ ជាមួយនឹងទម្លាប់តាមដាន ត្រួតពិនិត្យជាប្រចាំរបស់ឯកឧត្តមអភិបាលខេត្តនូវរាល់ផែនការដែលដាក់ចេញ បានធ្វើឱ្យកិច្ចការនានាជាច្រើនអាចសម្រេចបានជោគជ័យ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ និងបានធ្វើឱ្យទម្លាប់នេះក្លាយជាវប្បធម៌ក្នុងការបំពេញការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅក្នុងរដ្ឋបាលខេត្តផងដែរ។ ទន្ទឹមនេះ ឯកឧត្តមអភិបាលខេត្តក៏បានវាយតម្លៃខ្ពស់ ចំពោះការចុះតាមដាន ត្រួតពិនិត្យពីអង្គភាពផ្សេងៗផងដែរ ក្នុងនោះមានដូចជា ការធ្វើអធិការកិច្ចពីក្រសួងមហាផ្ទៃជាដើម ដោយសារតាមរយៈនេះ ឯកឧត្តមអាចស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងរដ្ឋបាលខេត្ត ដែលឯកឧត្តមចាត់ទុកថា នេះជាមូលដ្ឋានដ៏សំខាន់សម្រាប់ធ្វើការកែលម្អដើម្បីឈានទៅរកភាពល្អប្រសើរថែមទៀត។

***បី៖ ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ។*** ក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាខេត្តក៏ដូចរដ្ឋបាលខេត្តទាំងមូល ត្រូវខិតខំបំពេញការងារក្នុងការបម្រើសេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និងត្រូវមានគណនេយ្យភាពខ្ពស់

[2] *គោលការណ៍នៃការគ្រប់គ្រង (២០១៥, បណ្ឌិត ពេជ្រ គិរីរង្ស៊ី, សាកលវិទ្យាល័យជាតិគ្រប់គ្រង)*

បំផុតចំពោះប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានខេត្តរបស់ខ្លួន។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍នេះ ឯកឧត្តមអភិបាលខេត្តបានចាត់ទុកប្រជាពលរដ្ឋដូចជា "ម្ចាស់" នៃរដ្ឋបាលខេត្តកណ្តាលទាំងមូល។ ក្នុងន័យនេះ រដ្ឋបាលខេត្តមានកាតព្វកិច្ចត្រូវស្វែងយល់ឱ្យបានច្បាស់លាស់ ជាក់លាក់ និងចំបញ្ហាអំពីតម្រូវការរបស់ "ម្ចាស់" ខ្លួន ដើម្បីអាចផ្គាប់ចិត្ត "ម្ចាស់" ក្នុងការបម្រើសេវានានា។

ការស្វែងយល់អំពីតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ នឹងមិនអាចសម្រេចទៅបានឡើយ ប្រសិនបើគ្មានការចូលរួមដោយផ្ទាល់ ប្រកបដោយអត្ថន័យពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាននៅមូលដ្ឋាន។ ហេតុនេះ ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលខេត្ត នៅក្នុងដំណើរការ និងឬព្រឹត្តិការណ៍នានារបស់រដ្ឋបាលខេត្តមានសារសំខាន់ មិនអាចមើលរំលងបាន ក្នុងការធានាឱ្យរដ្ឋបាលខេត្តអាចបំពេញ តួនាទី ភារកិច្ចរបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងសមធម៌ ស្របតាមស្មារតីនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ពាក់ព័ន្ធចំណុចនេះ ឯកឧត្តមអភិបាលខេត្តបានលើកឡើងថា ការចូលរួមរបស់ប្រជាពលរដ្ឋអាចមានពីរសណ្ឋាន។ មួយបែប គឺប្រជាពលរដ្ឋផ្ទាល់ខ្លួនជាអ្នកអញ្ជើញមកចូលរួមក្នុងព្រឹត្តិការណ៍នានារបស់រដ្ឋបាលខេត្ត ដោយសារប្រជាពលរដ្ឋទាំងនោះចង់ដឹង ចង់ឮ ឬមានសំណើ សំណូមពរអ្វីមួយដល់រដ្ឋបាលខេត្ត។ ចំណែកមួយបែបទៀត គឺយើងជាអ្នកដឹកនាំនៅរដ្ឋបាលខេត្តចុះទៅជួបផ្ទាល់ដល់ទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីស្តាប់ និងដោះស្រាយសំណើ សំណូមពរ ក៏ដូចបញ្ហាប្រឈមនានាដែលប្រជាពលរដ្ឋកំពុងជួបប្រទះ។ តាមការឱ្យដឹងពីមន្ត្រីនៅសាលាខេត្តកណ្តាល ឯកឧត្តមអភិបាលខេត្តបានចំណាយភាគច្រើននៃពេលវេលាការងាររបស់ឯកឧត្តម រួមទាំងថ្ងៃចុងសប្តាហ៍ផង ដើម្បីចុះជួបជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ក្នុងគោលបំណងស្តាប់មតិយោបល់ ក៏ដូចជាស្តាប់ និងដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ។ ឯកឧត្តមអភិបាលខេត្តចុះជួបប្រជាពលរដ្ឋនៅក្នុងឱកាសជាច្រើន មានដូចជា វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់រដ្ឋបាលខេត្ត ក្រុង ស្រុក វេទិកាព្រឹទ្ធសភាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ វេទិកាភូមិឃុំមានសុវត្ថិភាព ជាដើម។ ក្រៅ



*សកម្មភាពចូលរួមវេទិកាសាធារណៈរបស់ប្រជាពលរដ្ឋក្នុងខេត្តកណ្តាល*

ពីនេះ ឯកឧត្តមក៏បានផ្តួចផ្តើមរៀបចំឱ្យមាន "វេទិកាគណៈអភិបាលជាមួយប្រជាពលរដ្ឋ" ផងដែរ ដែលវេទិកានេះធ្វើឡើងជាញឹកញាប់នៅតាមមូលដ្ឋានក្រុងស្រុកនានានៅទូទាំងខេត្តកណ្តាល។ ម្យ៉ាងទៀត ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមកាន់តែច្រើន ឯកឧត្តមអភិបាលខេត្តតែងតែធ្វើការឆ្លើយតបជាប្រចាំដោយមិនខកខាន ចំពោះបញ្ហានានាដែលលើកឡើងដោយប្រជាពលរដ្ឋ បើទោះជាកិច្ចការនោះធ្វើបាន ឬមិនបានយ៉ាងណាក៏ដោយ សំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋស្ងប់ចិត្ត ទទួលយកការពិត។

***បួន៖ កៀរគរធនធានពីប្រភពនានា។*** ជាការពិតរដ្ឋបាលខេត្តត្រូវមានចំណូលសមស្រប ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចដើម្បីអភិវឌ្ឍមូលដ្ឋានឱ្យមានការរីកចម្រើន សំដៅលើកកម្ពស់គុណភាពនៃជីវភាពរស់នៅរបស់ប្រជា-ពលរដ្ឋ។ ឯកឧត្តមអភិបាលខេត្តបានឱ្យក្រុមការងារដឹងថា រដ្ឋបាលខេត្តមានប្រភពចំណូលសំខាន់បីគឺ ថវិកាវិភាជន៍ពីថ្នាក់ជាតិដែលយើងហៅថាថវិកាខេត្ត ចំណូលបានមកពីការប្រមូលពន្ធ និងមិនមែនសារពើ-ពន្ធដទៃទៀត ព្រមទាំងចំណូលបានមកពីការចែករំលែកពីថ្នាក់ជាតិ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ដើម្បីបង្កើនចំណូលរបស់រដ្ឋបាលខេត្ត ខេត្តបានខិតខំកៀរគរធនធានពីគ្រប់ប្រភព ជាពិសេសតាមរយៈការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលពន្ធពីប្រភពពន្ធគ្រប់ប្រភេទនៅក្នុងខេត្ត ជាលទ្ធផលក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ចំណូលបានមកពីការចែករំលែកពីថ្នាក់ជាតិរបស់រដ្ឋបាលខេត្តកណ្តាលមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលធ្វើឱ្យរដ្ឋបាលខេត្តមានលទ្ធភាពកាន់តែច្រើនឡើងក្នុងការរៀបចំគម្រោងនានាដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចអភិវឌ្ឍមូលដ្ឋានជាពិសេសការអភិវឌ្ឍនៅតំបន់ជនបទដើម្បីលើកកម្ពស់សមធម៌ក្នុងសង្គម។

ក្រៅពីប្រភពចំណូលខាងលើនេះ ឯកឧត្តមបានបន្ថែមទៀតថា រដ្ឋបាលខេត្តក៏បានខិតខំកៀរគរធនធានពីប្រភពផ្សេងៗទៀត មានដូចជា សប្បុរសជនក្នុងនិងក្រៅស្រុក វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាជាដើម។

***ប្រាំ៖ ជំរុញកិច្ចសហការពីក្នុងចំណោមអ្នកពាក់ព័ន្ធ។*** ទោះបីជាការកៀរគរធនធានពីប្រភពផ្សេងៗមានលក្ខណៈល្អប្រសើរយ៉ាងណាក្តី ឯកឧត្តមបានបញ្ជាក់ថា ការឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋានដោយរដ្ឋបាលខេត្តកណ្តាលតែឯងនៅតែមានកម្រិតនៅតែពុំទាន់សមល្មមនៅឡើយ ដោយសារតម្រូវការរបស់ប្រជាពលរដ្ឋមានច្រើនប្រភេទ និងមានទំហំធំ ជាពិសេសតម្រូវការដែលមានផលប៉ះពាល់ដល់ជីវភាពរស់នៅផ្ទាល់របស់ប្រជាពលរដ្ឋ។ ហេតុនេះ ឯកឧត្តមបន្ថែមថា នៅក្នុងការឆ្លើយតបទៅនឹងតម្រូវការនានានៅមូលដ្ឋាន ឯកឧត្តមតែងតែខិតខំកៀរគរកិច្ចសហការពីគ្រប់មន្ទីរ អង្គភាពនានានៅក្នុងខេត្តក្នុងក្របខ័ណ្ឌនៃរដ្ឋបាលឯកភាពរបស់ខេត្ត ដើម្បីរួមគ្នាឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនៅមូលដ្ឋាន ក៏ដូចរួមគ្នាដោះស្រាយបញ្ហាប្រឈមនានានៅមូល-ដ្ឋាន ឱ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ជាក់ស្តែង តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ

រដ្ឋបាលខេត្តបានទទួលនូវកិច្ចសហការលើច្រើនវិស័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីមន្ទីរ អង្គភាពនានាជុំវិញខេត្ត ក្នុង លក្ខណៈ"រួមចិត្ត រួមគំនិតគ្នាធ្វើ" មិនត្រឹមតែក្នុងការដោះស្រាយលើករណីជាក់លាក់ដែលកើតឡើងនៅមូលដ្ឋានប៉ុណ្ណោះទេ ថែមទាំងក្នុងការផ្តល់ការគាំទ្រដល់គម្រោងនៅក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត ដែលកន្លងនេះបានធ្វើឱ្យការរៀបចំផែនការអភិវឌ្ឍន៍នៅក្នុងខេត្តទាំងមូលអាចធានាបាននូវសុខដុមនីយកម្មល្អប្រសើរ។

សរុបមក ការអភិវឌ្ឍប្រកបដោយសមធម៌ ដែលឯកឧត្តមអភិបាលខេត្តកណ្តាលបានយកចិត្តទុកដាក់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍខេត្តកណ្តាល គឺជាជម្រើសដ៏សមស្របនិងមានប្រសិទ្ធភាពក្នុងការចូលរួមចំណែកធានាឱ្យការបែងចែកកំណើនសេដ្ឋកិច្ចជាតិបានទៅដល់ដៃប្រជាពលរដ្ឋគ្រប់ៗរូបនៅគ្រប់មូលដ្ឋានជាពិសេសសម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ជនជាតិដើមភាគតិច និងជនងាយរងគ្រោះជាដើម។ ដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយសមធម៌នេះ ធាតុចូលដ៏សំខាន់មួយដែលមិនអាចកាត់ផ្តាច់បាន គឺការចូលរួមប្រកបដោយអត្ថន័យពីប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ដោយមិនមានការរើសអើង សំដៅក្តាប់បាននិងឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវខិតខំរិះរកមធ្យោបាយនិងយន្តការនានាដែលមានប្រសិទ្ធភាព និងមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋធ្វើការទំនាក់ទំនង ក៏ដូចលើកឡើងពីបញ្ហាប្រឈម សំណើ សំណូមពរនានារបស់ខ្លួន ហើយថ្នាក់ដឹកនាំនៃរដ្ឋបាលទាំងនេះត្រូវខិតខំព្យាយាមធ្វើការឆ្លើយតបឱ្យអស់លទ្ធភាពតាមរយៈមធ្យោបាយផ្សេងៗ ដើម្បីព្យាយាមដោះស្រាយបញ្ហាប្រឈមសំណើ និងសំណូមពរដែលប្រជាពលរដ្ឋបានលើកឡើងទាំងនោះ ដោយមិនត្រូវមិនឆ្លើយតប មិនរវីរវល់ឬមិនមានវិធានការអ្វីនោះឡើយ។

*ដោយ សូ មុនីរក្សា*

# មូលនិធិឃុំ សង្កាត់ និងការអភិវឌ្ឍមូលដ្ឋាន




តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី២នៃនីតិកាលរដ្ឋសភាមូលនិធិឃុំ សង្កាត់ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ពោលគឺស្របពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រដោយប្រជាពលរដ្ឋនៅមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានឆន្ទានុសិទ្ធិក្នុងការប្រើប្រាស់មូលនិធិនេះ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

**មូលនិធិឃុំ សង្កាត់បានមកពីណានិងបែងចែកយ៉ាងដូចម្ដេច** ?

នៅរៀងរាល់៣-៥ឆ្នាំម្ដង រាជរដ្ឋាភិបាលបានកំណត់អត្រានៃទំហំមូលនិធិនេះសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេស។ ផ្អែកតាមអត្រាដែលបានកំណត់នេះ គណនីមូលនិធិឃុំ សង្កាត់មួយត្រូវបានកំណត់នៅក្នុងថវិកាជាតិប្រចាំឆ្នាំ ហើយក្រសួងមហាផ្ទៃជាអ្នកទទួលខុសត្រូវបញ្ជាការផ្ទេរពីគណនីនោះ ទៅគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់នៅរតនាគាររាជធានី ខេត្ត ឬនៅធនាគារពាណិជ្ជណាមួយដែលមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរៀបចំជាតារាងវិភាជន៍មូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំ។ ការបែងចែកមូលនិធិឃុំ សង្កាត់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវធ្វើឡើងដោយផ្អែកតាមចំនួនប្រជាពលរដ្ឋ ចំនួនសមាជិកក្រុមប្រឹក្សា សន្ទស្សន៍នៃភាពក្រីក្រ និងចំនួនភូមិនៅក្នុងឃុំ សង្កាត់នីមួយៗ។

ផ្អែកតាមគោលការណ៍ខាងលើ អត្រានៃទំហំមូលនិធិឃុំ សង្កាត់មានការកើនឡើងជាលំដាប់ពី ១,៥% ក្នុងឆ្នាំ២០០២ រហូតដល់ ២,៨% នៃចំណូលចរន្តជាតិ ក្នុងឆ្នាំ២០១៧។ បើគិតពីទំហំនៃមូលនិធិ ឃុំ សង្កាត់នីមួយៗ គឺមានការកើនឡើងចំនួនជាង១២ដង ពោលគឺពី ៣០.៦៨៧លានរៀល (ប្រមាណ៧លាន៥០ម៉ឺនដុល្លារអាមេរិក) ក្នុងឆ្នាំ ២០០២ រហូតដល់ ៣៧៥.៤០៤លានរៀល

(ប្រមាណ៩៣លានដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ បើគិតជាមធ្យម បច្ចុប្បន្នរដ្ឋបាលឃុំ សង្កាត់នីមួយៗទទួលបានប្រមាណ ២២៨លានរៀល (ប្រមាណ៥ម៉ឺន៧ពាន់ដុល្លារអាមេរិក)។

ក្រៅពីចំណូលទទួលបានពីមូលនិធិឃុំ សង្កាត់ ប្រភពចំណូលដទៃទៀតរបស់រដ្ឋបាលឃុំ សង្កាត់ រួមមាន៖




- ចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធនៅក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន
- ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ ដែលជាចំណូលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ ជំនួសមុខឱ្យក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋ និង
- ចំណូលផ្សេងៗទៀតដែលមានដូចជា ការចូលរួមចំណែករបស់ប្រជាពលរដ្ឋ សប្បុរសជន កម្មវិធីនានា អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាដើម។

**ការប្រើប្រាស់មូលនិធិឃុំ សង្កាត់**

ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ត្រូវផ្អែកទៅតាមផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងត្រូវអនុវត្តតាមរយៈការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ត្រូវចែកចេញជាពីរផ្នែកគឺផ្នែកប្រតិបត្តិការរដ្ឋបាល និងផ្នែកអភិវឌ្ឍន៍មូលដ្ឋាន។

ផ្នែកប្រតិបត្តិការរដ្ឋបាលមិនត្រូវច្រើនជាង១ភាគ៣នៃធនធានមូលនិធិសរុបរបស់រដ្ឋបាល ឃុំ សង្កាត់ឡើយ។ ផ្នែកនេះត្រូវចំណាយទៅលើប្រាក់បំណាច់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ បៀវត្សមន្ត្រីឃុំ សង្កាត់ និងចំណាយផ្សេងៗសម្រាប់មន្ត្រី បុគ្គលិកឃុំ សង្កាត់ ឧបករណ៍ការិយាល័យ មធ្យោបាយសម្ភារសម្រាប់រដ្ឋបាល ការជួសជុល និងថែទាំមធ្យោបាយសម្ភារៈរដ្ឋបាល ថ្លៃប្រើប្រាស់ទឹក និងអគ្គិសនី ជាដើម។ ផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ត្រូវប្រើប្រាស់សម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន និងការផ្តល់សេវាសេដ្ឋកិច្ចសង្គមនៅឃុំ សង្កាត់ជាដើម។ គម្រោងអភិវឌ្ឍន៍ដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់ហៅថា គម្រោងមូលនិធិឃុំ សង្កាត់។




ចាប់តាំងពីឆ្នាំ២០០៣ មកទល់ឆ្នាំ២០១៥ គម្រោងមូលនិធិឃុំ សង្កាត់មានចំនួនសរុប ២៣.៦៥៥គម្រោង ដែលមានតម្លៃវិនិយោគសរុបប្រមាណ ៩៣១.១៣៧.៥៨១.០០០រៀល (ប្រមាណ ២៣៣លានដុល្លារអាមេរិក) ដែលក្នុងនោះភាគច្រើនផ្ដោតលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលជាគម្រោងអាទិភាពសម្រាប់មូលដ្ឋានឃុំ សង្កាត់ នៅកម្ពុជាបច្ចុប្បន្ន។

ជាទូទៅ គម្រោងមូលនិធិឃុំ សង្កាត់ត្រូវបានវាយតម្លៃខ្ពស់ ដោយសារការអនុវត្តគម្រោងទាំងនេះមាននីតិវិធីច្បាស់លាស់ មានតម្លាភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនៃការអនុវត្តគម្រោងទាំងនោះ។ សៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលហៅថាសៀវភៅភីម (PIM: Project Implementation Manual) និងសៀវភៅណែនាំស្ដីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោង



អភិវឌ្ឍន៍ កិច្ចការរដ្ឋបាល និងកិច្ចការហិរញ្ញវត្ថុ ដែលដាក់ឱ្យប្រើប្រាស់ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅឆ្នាំ២០០៩ បានកំណត់អំពីនីតិវិធីយ៉ាងលម្អិតសម្រាប់កិច្ចការចាំបាច់នានា ក្នុងការអនុវត្តគម្រោង ដោយមានការណែនាំចាប់តាំងពីការចាប់ផ្ដើមសិក្សារៀបចំគម្រោង រហូតដល់ការដេញថ្លៃអនុវត្តគម្រោង ព្រមទាំងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោង។

ក្រៅពីនេះ ក៏មានការរៀបចំឱ្យមានយន្តការតាមដានត្រួតពិនិត្យពីប្រជាពលរដ្ឋដែលជាអ្នកទទួលផលផ្ទាល់ផងដែរ តាមរយៈការបំពាក់ប្រអប់សំបុត្រគណនេយ្យភាពនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទូទាំងប្រទេស សំដៅប្រមូលព័ត៌មានពីប្រជាពលរដ្ឋ ក៏ដូចអ្នកពាក់ព័ន្ធផ្សេងទៀតអំពីភាពមិនប្រក្រតីនានាដែលអាចកើតមាននៅក្នុងការប្រើ



ថវិកានៃមូលនិធិឃុំ សង្កាត់។

ជាក់ស្តែង តាមរយៈប្រអប់សំបុត្រគណនេយ្យភាពទាំងនេះ បណ្តឹងទទួលបានពីប្រជាពលរដ្ឋមានចំនួន ២២០ ករណី ក្នុងឆ្នាំ២០១៥ និងចំនួន ២២៤ ករណី ក្នុងឆ្នាំ២០១៦ ពីឃុំ សង្កាត់ទូទាំងប្រទេស។ នេះបើយោងតាមរបាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៥ និងឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

**មូលនិធិឃុំ សង្កាត់ បានរួមចំណែកលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ**

គោលបំណងជាយុទ្ធសាស្ត្រមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលមានចែងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស៊ីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៥) គឺជំរុញកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាន សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ តាមរយៈមូលនិធិឃុំ សង្កាត់ យើងសង្កេតឃើញថា សមិទ្ធផលនានាដែលសម្រេចបានដោយគម្រោងមូលនិធិឃុំ សង្កាត់បានរួមចំណែក



គួរឱ្យកត់សម្គាល់ក្នុងការសម្រេចបាននូវគោលបំណងជាយុទ្ធសាស្ត្រនេះ។



បើយើងប្រៀបធៀបកាលពីជាង១០ឆ្នាំមុន ជាមួយបច្ចុប្បន្ននេះ យើងសង្កេតឃើញស្ថានភាពជាទូទៅនៅមូលដ្ឋាន ឃុំ សង្កាត់ មានការប្រែប្រួលច្រើន ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងនោះ ប្រសិនបើយើងពិនិត្យមើលការរស់នៅរបស់គ្រួសារប្រជាពលរដ្ឋនៅមូលដ្ឋានបច្ចុប្បន្ន មិនថាតែប្រជាពលរដ្ឋនៅតាម

តំបន់ទីក្រុង ឬទីប្រជុំជននោះទេ សូម្បីតែគ្រួសារប្រជាពលរដ្ឋនៅជនបទក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ ជាក់ស្ដែង យើងសង្កេតឃើញប្រជាពលរដ្ឋទាំងនោះភាគច្រើនរស់នៅក្នុងលំនៅដ្ឋានស្អាតជាងមុន សមរម្យជាងមុន និងមានម៉ូតូពីរ ឬបីគ្រឿងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ហើយគ្រួសារខ្លះមានរហូតដល់រថយន្តទៀតផង។ ជាមួយនេះ បើយើងពិនិត្យមើលអំពីមធ្យោបាយធ្វើកសិកម្ម ភាគច្រើនបងប្អូនប្រជាកសិករយើងសុទ្ធតែប្រើប្រាស់គ្រឿងចក្រ មិនប្រើកម្លាំងមនុស្ស កម្លាំងសត្វដូចមុនទៀតឡើយ។ បច្ចុប្បន្ន ផ្លូវថ្នល់ ស្ពាន ប្រឡាយទឹក និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ជាច្រើនទៀតត្រូវបានសាងសង់ ក៏ដូចកែលម្អឱ្យកាន់តែល្អប្រសើរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋ



សាលារៀនរបស់ UNICEF ជួយ បានខូចសាឡង់ទ្រ លិចទឹកមិនអាចរៀនបាន



គម្រោងសាងសង់ផ្លូវបេតុងមានជើង១ខ្សែ ប្រវែង១៦០មទទឹង២.២ម និងកម្រាស់៦០មម នៅឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ខេត្តកោះកុង



គម្រោងសាងសង់ច្រាំងស្ទឹង ប្រវែង៤៥ម ជម្រាលទទឹង១៣ម និងកម្រាស់០.១២៥ម នៅឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ

មូលដ្ឋាន។ សមិទ្ធផលទាំងនេះបានរួមចំណែកបង្កភាពងាយស្រួល លើកកម្ពស់ផលិតភាព និងកាត់បន្ថយចំណាយរបស់ប្រជាពលរដ្ឋទាំងក្នុងការរស់នៅប្រចាំថ្ងៃ ក៏ដូចក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ម្យ៉ាងទៀត ផ្អែកតាមសៀវភៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឆ្នាំ២០១៤-២០១៨) អត្រានៃភាពក្រីក្រនៅប្រទេសកម្ពុជាត្រូវបានកាត់បន្ថយគួរជាទីកត់សម្គាល់ ជាក់-ស្តែងក្នុងឆ្នាំ២០០៧ នៅតំបន់មិនមែនទីប្រជុំជន ដោយមិនរាប់បញ្ចូលទីក្រុងភ្នំពេញ និងតំបន់ទីប្រជុំជន ភាពក្រីក្ររបស់ប្រជាពលរដ្ឋស្ថិតក្នុងអត្រា ៥៣% ហើយត្រូវបានកាត់បន្ថយជាបន្តបន្ទាប់រហូតដល់ ២០%ក្នុងឆ្នាំ២០១១ និងបន្តធ្លាក់ចុះដល់១៥%ក្នុងឆ្នាំ២០១៧នេះ។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចនៅតែបន្តរក្សាបាននូវកំណើនរបស់ខ្លួនក្នុងរង្វង់ ៧%ក្នុងមួយឆ្នាំ ដោយបានប្រែក្លាយកម្រិតផលិតផលក្នុងស្រុកសរុបរបស់ប្រជាពលរដ្ឋពី១០០០ដុល្លារអាមេរិក/១នាក់ ក្នុងឆ្នាំ២០១៣ រហូតដល់ ១៤៥០ដុល្លារអាមេរិក/១នាក់ ក្នុងឆ្នាំ២០១៧។

**រួមគ្នាអភិវឌ្ឍឃុំ សង្កាត់យើង**!

ការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់ប្រកបដោយគណនេយ្យភាព តម្លាភាព សមធម៌ ចីរភាព និងនិរន្តរភាព ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែង និងចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់នីមួយៗ។ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗកើតឡើងចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ហេតុនេះក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំបំពេញការងារដើម្បីបម្រើផលប្រយោជន៍រួម និងឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន តាមរយៈការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយតម្លាភាព គណ-នេយ្យភាព សមធម៌ និងចីរភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវខិតខំប្រើប្រាស់មូលនិធិឃុំ សង្កាត់ ឱ្យចំទិសដៅ និងមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ទន្ទឹមនឹងការខិតខំកៀរគរធនធានពីប្រភពចំណូលផ្សេងៗទៀតដូចបានរៀបរាប់ខាងលើ ដើម្បីក្រុមប្រឹក្សាឃុំ សង្កាត់មានលទ្ធភាពកាន់តែច្រើនក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែរីកចម្រើន។

ដើម្បីសម្រេចបានកិច្ចការនេះ ការចូលរួមប្រកបដោយអត្ថន័យរបស់ប្រជាពលរដ្ឋ គឺពិតជាមានសារសំខាន់ដែលមិនអាចខ្វះបាន ដើម្បីធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ហេតុនេះ ប្រជាពលរដ្ឋក្នុងនាមជាម្ចាស់ឆ្នោត គួរយកចិត្តទុកដាក់ចូលរួមផ្តល់យោបល់ និងលើកឡើងអំពីតម្រូវការ ក៏ដូចបញ្ហាប្រឈមរបស់ខ្លួន ដើម្បីក្រុមប្រឹក្សាអាចពិនិត្យដោះស្រាយ និងឆ្លើយតប ជាពិសេស នៅក្នុងដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ក្រុមប្រឹក្សាឃុំ សង្កាត់ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងវេទិកានានាដទៃទៀត។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវខិតខំបង្កលក្ខណៈងាយស្រួលតាមគ្រប់រូបភាព ដើម្បីលើកទឹកចិត្តឱ្យប្រជា-ពលរដ្ឋចូលរួមនៅក្នុងដំណើរការនៃអភិបាលកិច្ច ក៏ដូចការអភិវឌ្ឍមូលដ្ឋាន។

*ដោយ សូ មុនីរក្សា*
*មុំ វីរៈ*
*ឯមគាន់ សុផានិត*

# ស្វែងយល់អំពីអាស៊ាន

## *កម្ពុជា អាស៊ាន និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន*



នៅក្នុងព្រឹត្តិបត្រលេខមុន អត្ថបទស្តីពី “ស្វែងយល់អំពីអាស៊ាន” បាននាំមកជូនប្រិយមិត្តអ្នកអាននូវចំណេះដឹងសំខាន់ៗពាក់ព័ន្ធសាវតារនៃការកកើតអាស៊ាន ទិដ្ឋភាពទូទៅនៃអាស៊ាន ក៏ដូចព័ត៌មានទូទៅអំពីបណ្តាប្រទេសអាស៊ាន។សម្រាប់ព្រឹត្តិបត្រលេខនេះវិញ “ស្វែងយល់ពីអាស៊ាន” នឹងផ្តោតសំខាន់លើវត្តមានរបស់កម្ពុជាអាស៊ាន ក៏ដូចកម្ពុជា និងការធ្វើសមាហរណកម្មក្នុងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន។

**កម្ពុជា និងអាស៊ាន**

ជាការពិតដែលមិនអាចប្រកែកបាន កត្តាដ៏លំបាកបំផុតដែលជាឧបសគ្គនៃកិច្ចអភិវឌ្ឍន៍របស់កម្ពុជា គឺដំណើរផ្លូវមួយដែលចាប់ផ្តើមបន្ទាប់ពីការផ្តួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះ ស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយ ទាំងក្នុងនិងក្រៅប្រទេសធ្លាក់ចុះដល់ចំណុចក្រោមសូន្យ។ ឈានចេញពីស្ថានភាពដ៏លំបាកនេះ កម្ពុជានៅតែមិនទាន់អាចសម្រេចបាននូវកិច្ចអភិវឌ្ឍន៍ល្អប្រសើរមួយ ទាំងក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ពីព្រោះថាសង្គ្រាមស៊ីវិលនៅតែបន្តរហែកហួរដោយក្រុមចលនានយោបាយផ្សេងៗ។ បញ្ហានេះនៅតែធ្វើឱ្យកម្ពុជាឃ្លាតឆ្ងាយពីក្រសែភ្នែករបស់អ្នកទេសចរ អ្នកវិនិយោគ ដែលធ្វើឱ្យកម្ពុជានៅតែមិនទាន់ស្មើមុខស្មើមាត់ពេញលេញលើឆាកអន្តរជាតិ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ គឺជាចំណុចចាប់ផ្តើម ដែលនាំឱ្យមានការរៀបចំបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំ និងចាត់ចែងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) ទោះបីជាយ៉ាងនេះកម្ពុជានៅតែពុំទាន់បានទទួលនូវសន្តិភាព ស្ថេរភាព និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម បានពេញ-លេញនៅឡើយ។ សន្តិភាព ស្ថេរភាព និងកិច្ចអភិវឌ្ឍន៍លេចជារូបរាងឡើងនៅក្នុងឆ្នាំ១៩៩៨ នៅពេលដែលមានការផ្តួចផ្តើម និងដាក់ចេញនូវនយោបាយ “ឈ្នះ-ឈ្នះ” ដែលតាមរយៈនយោបាយនេះបាននាំមកឱ្យកម្ពុជានូវការបង្រួបបង្រួមនូវរាល់កងកម្លាំង និងក្រុមចលនានយោបាយខុសច្បាប់ទាំងឡាយឱ្យស្ថិតក្រោមដំបូលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តែមួយ។

ក្នុងស្ថានភាពដ៏អំណោយផលនេះ តាមរយៈការតាំងចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាល ជាពិសេសរាជរដ្ឋាភិបាល ដែលកើតចេញពីការបោះឆ្នោតជាតិលើកទី២បាននាំមកនូវសន្តិភាព ស្ថិរភាព និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម កាន់តែមានភាពរឹងមាំ ខណៈពេលដែលនយោបាយក្រៅប្រទេសកាន់

តែមានលក្ខណៈវិជ្ជមានគួរជាទីកត់សម្គាល់។ ចាប់ពីពេលនោះមក កម្ពុជាបានកសាងទំនាក់ទំនងការទូត និងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយបណ្ដាប្រទេសជិតខាង ទាំងក្នុងតំបន់ និងពិភពលោក។ តាមរយៈលក្ខណសម្បត្តិរបស់កម្ពុជា ក៏ដូចភាពល្អប្រសើរនៃទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការនេះ កម្ពុជាបានក្លាយជាសមាជិកកូនពៅ




របស់សមាគមអាស៊ាននៅឆ្នាំ១៩៩៩ ហើយជាបន្តបន្ទាប់ជាសមាជិករបស់អង្គការអន្តរជាតិដទៃទៀត។ ចំណុចគួរកត់សម្គាល់ វត្តមានរបស់កម្ពុជានៅក្នុងអាស៊ាន បង្ហាញយ៉ាងច្បាស់នូវភាពស្មើមុខស្មើមាត់របស់កម្ពុជាក្នុងឆាកអន្តរជាតិ ហើយបានបង្ហាញនូវការប្ដេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជា ក្នុងការចូលរួមជាមួយបណ្ដាប្រទេសដទៃទៀត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងការរក្សាសន្តិភាព ស្ថេរភាព ក៏ដូចកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ស្របតាមទិសដៅគោលការណ៍ និងគោលបំណងរបស់អាស៊ាន។ ជាការពិត កម្ពុជាជាប្រទេសមានការអភិវឌ្ឍន៍តិចតួច




បើប្រៀបធៀបទៅនឹងបណ្ដា ប្រទេសនៅក្នុងអាស៊ាន ប៉ុន្តែវត្តមាន ឆន្ទៈ ការតាំងចិត្ត និងការចូលរួមរបស់កម្ពុជាបានបង្ហាញនូវកិច្ចខិតខំក្នុងការជម្នះរាល់ឧបសគ្គ ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅដែលបានកំណត់ក្នុងសេចក្ដីប្រកាសទីក្រុងបាងកក ដែលចែងអំពីការរួមគ្នាជំរុញវឌ្ឍនភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងតំបន់ ការលើកកម្ពស់សន្តិភាព និងស្ថេរភាពក្នុងតំបន់ ក៏ដូចការលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកលើបញ្ហាដែលជាផលប្រយោជន៍រួម។ល។

ក្នុងដំណើររយៈពេលជាង១៧ឆ្នាំរបស់កម្ពុជាក្នុងសមាគមអាស៊ានកម្ពុជាទាញបានប្រយោជន៍ច្រើនផ្នែកសន្តិសុខ និងវិស័យការទូត ជាពិសេសតាមរយៈការធ្វើម្ចាស់ផ្ទះអាស៊ានចំនួនពីរដង គឺនៅឆ្នាំ២០០២និង២០១២។ កម្ពុជាបានប្រែក្លាយមុខមាត់ជាប្រទេសដែលគេមិនសូវស្គាល់ ឬជាប្រទេសដែលគេស្គាល់ក្នុងផ្លូវអវិជ្ជមាន ទៅជាប្រទេសដែលគេស្គាល់ក្នុងផ្លូវវិជ្ជមាន ដែលបានផ្ដល់នូវផ្លូវមួយដ៏សំខាន់សម្រាប់កម្ពុជាក្នុងការឈានទៅធ្វើកិច្ចសហប្រតិបត្តិការនិងបានចាប់យកដៃគូពិភាក្សា

សំខាន់ៗក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ក៏ដូចតំបន់ដទៃទៀតក្នុងពិភពលោក។ តាមរយៈអាស៊ាន ប្រទេសកម្ពុជាបានទាក់ទាញអ្នកវិនិយោគយ៉ាងច្រើនឱ្យបែរមកបណ្តាក់ទុននៅក្នុងប្រទេសកម្ពុជា ទាំងអ្នកវិនិយោគនៅក្នុងប្រទេសអាស៊ានផង និងប្រទេសដែលជាដៃគូចរចានោះផង ព្រមទាំងអ្នកវិនិយោគអន្តរជាតិផ្សេងៗទៀត តាមរយៈសហគមន៍សេដ្ឋកិច្ចអាស៊ានដែលបានជំរុញឱ្យមានទីផ្សារតែមួយ និងកន្លែងផលិតតែមួយ។

ជាមួយគ្នានេះ កម្ពុជាក៏ទទួលបានផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាសមាជិកអាស៊ានផ្សេងទៀតលើវិស័យសន្តិសុខប្រពៃណី ដូចជាបរិស្ថាន ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនជាដើម ហើយអ្វីដែលពិសេស កម្ពុជាអាចទទួលផលប្រយោជន៍សេដ្ឋកិច្ចនិងមានលទ្ធភាពពង្រីកទីផ្សាររបស់ខ្លួនថែមទៀតតាមរយៈសមាហរណកម្មសេដ្ឋកិច្ចអាស៊ានដែលបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១៥កន្លងទៅ។

**កម្ពុជា និងសហគមន៍សេដ្ឋកិច្ចអាស៊ាន**

សហគមន៍សេដ្ឋកិច្ចអាស៊ាន បានចាប់ផ្តើមអនុវត្តជាផ្លូវការនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ដែលជាជំហានថ្មីមួយ នៃការចាប់ផ្តើមបរិយាកាសសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ដែលមានលក្ខណៈទូលំទូលាយ បើកចំហរ និងប្រមូលផ្តុំ ដែលនឹងផ្តល់ដល់ប្រជាជននៅក្នុងបណ្តាប្រទេសអាស៊ាននូវជម្រើសសម្បូរបែបនៃទំនិញ និងសេវាកម្ម ក្នុងតម្លៃប្រកួតប្រជែង។ សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ជាគោលដៅសម្រេចទីផ្សារតែមួយ ដែលនឹងដំណើរការដោយមានលំហូរពាណិជ្ជកម្ម សេវាកម្ម និងកម្លាំងពលកម្មដោយសេរី ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន។

ទោះជាយ៉ាងនេះក្តី ការចាប់យកកាលានុវត្តភាព និង ឬការទទួលយកបរិយាកាសថ្មីទាំងនោះ គឺអាស្រ័យទៅលើយុទ្ធសាស្ត្រ សមត្ថភាព និងភាពប៉ិនប្រសប់របស់ប្រជាជន ធុរជន និងប្រជាជាតិនីមួយៗ ជាពិសេសសម្រាប់កម្ពុជា ក្នុងនាមជាប្រទេសមានការរីកចម្រើននៅមានកម្រិតនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនៅក្នុងតំបន់។



**សហគមន៍សេដ្ឋកិច្ចអាស៊ាន៖ កាលានុវត្តភាព និង បញ្ហាប្រឈមរបស់កម្ពុជា**

ស្របទៅនឹងដំណើរការរបស់អាស៊ាន កម្ពុជា ដែលបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ានតាំងពីឆ្នាំ១៩៩៩ ត្រូវសម្របខ្លួនទៅក្នុងចរន្តនៃសមាហរណកម្មទីផ្សារតំបន់សេរីរបស់អាស៊ាននេះដែរ។ ក្នុង

ដំណើរការនេះ កម្ពុជារំពឹងថា នឹងទទួលបានផលប្រយោជន៍ផង ហើយក៏នឹងជួបបញ្ហាប្រឈមផង។

ជាកាលានុវត្តភាព សហគមន៍សេដ្ឋកិច្ចអាស៊ាននឹងនាំមកនូវឱកាសទីផ្សារដ៏ធំ ដើម្បីនាំចេញនូវផលិតផលក្នុងស្រុកទៅលក់ក្នុងទីផ្សារអាស៊ានជាមួយតម្លៃខ្ពស់ និងរាល់ទំនិញនាំចូល នឹងមានតម្លៃថោក ដោយសារ




និងអ្នកវិនិយោគទុនកម្ពុជា នឹងមានលទ្ធភាពពង្រីកមិនមានការបង់ពន្ធ។ លើសពីនេះ ពលករ អ្នកជំនាញ ឱកាសការងារ និងប្រាក់ចំណូលច្រើនជាងមុននៅតាមបណ្តាប្រទេសសមាជិកអាស៊ាន ចរាចរដោយពុំមានរបាំងព្រំដែន។ ជារួម សេចក្តីរំពឹងទុកមួយរបស់អាស៊ាន រួមទាំងកម្ពុជាក្នុងនោះផង គឺចរន្តឬលំហូរដ៏គំហុកនូវទំនិញ សេវាកម្ម និងការវិនិយោគបរទេស មូលធនហិរញ្ញវត្ថុរវាងប្រទេសសមាជិក នឹងត្រូវធ្វើឡើងដោយសេរីដោយមិនមានការបង់ពន្ធគយ និងជាពិសេស ចរាចរពលករ អ្នកជំនាញ អ្នកវិនិយោគទុនពីប្រទេសសមាជិកនីមួយៗក្នុងតំបន់ នឹងមានកំណើនកាន់តែខ្លាំង។

មកទល់ពេលនេះ ដំណើររបស់កម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានមានរយៈពេលជាង១ឆ្នាំ ហើយៗគេរំពឹងថាកម្ពុជានឹងមានសេដ្ឋកិច្ចលូតលាស់កាន់តែខ្លាំងក្លាដោយវិនិយោគិនធំៗ អ្នកមូលធនដ៏មានសក្តានុពលមួយចំនួននឹងបោះទុនវិនិយោគនៅក្នុងប្រទេសកម្ពុជា ព្រោះកម្ពុជាជាប្រទេសដែលសម្បូរវត្ថុធាតុដើមច្រើន ពិសេសវិស័យកសិកម្ម ដែលកត្តានេះនឹងអាចផ្តល់ការងារបន្ថែមដល់ប្រជាជនកម្ពុជា។

ទោះបីជាកម្ពុជារំពឹងថា អាចទាញបានឱកាសថ្មីពីការបើកចំហរសេដ្ឋកិច្ចអាស៊ានក៏ដោយក្តី ក៏ក្តីកង្វល់មួយចំនួនត្រូវបានលើកឡើងព្រមពេលជាមួយគ្នា។ ធនធានមនុស្ស និងកម្រិតអប់រំនៅកម្ពុជាដើរក្រោយស្ទើរគ្រប់ប្រទេសនៅក្នុងតំបន់អាស៊ាន មានន័យថា ធនធានមនុស្សកម្ពុជាមិនអាចប្រកួតប្រជែងជាមួយធនធានមនុស្សនៃប្រទេសអាស៊ានបានឡើយ។

លើសពីនេះ បើក្រលេកមើលពីកម្រិតនៃការនាំចេញ បរិមាណផលិតផលសម្រាប់នាំចេញនៅមានកម្រិតទាបជាងការនាំចូលច្រើន។ ហើយផលិតកម្មក្នុងស្រុកក៏នៅមានកម្រិត ហេតុនេះ នៅពេលមានវត្តមានរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាសធំៗមកបោះទីតាំងនៅកម្ពុជា ពេលនោះ ក្រុមហ៊ុនខ្មែរមួយចំនួនដែលរកស៊ីជាលក្ខណៈគ្រួសារ ឬក្រុមហ៊ុន សហគ្រាស ដែលមានផលិតភាពមានកម្រិតនឹងជួបបញ្ហាប្រឈម។

លើសពីនេះទៅទៀត ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធគមនាគមន៍ ក៏ដូចការកសាងប្រព័ន្ធឡូជីស្ទិក ហាក់

នៅមានកម្រិតនៅឡើយ បើប្រៀបធៀបជាមួយនឹងប្រទេសសមាជិកអាស៊ានដទៃ ដែលនេះអាចជាឧបសគ្គមួយផងដែរ នៅក្នុងការគិតពិចារណារបស់អ្នកធុរជន និងអ្នកវិនិយោគ ក្នុងការមកបណ្តាក់ទុននៅកម្ពុជា។

បញ្ហាប្រឈមរបស់កម្ពុជានៅក្នុងដំណើរការសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ដូចបានរៀបរាប់ខាងលើ គឺសុទ្ធសឹងតែជាបេសកកម្មរបស់កម្ពុជាក្នុងការកែលម្អ ដែលត្រូវប្រើប្រាស់ពេលវេលាយូរអង្វែង និងធនធានច្រើនសន្ធឹកសន្ធាប់ នឹងស្ថិតក្នុងក្របខណ្ឌនៃការគិតគូរគ្រប់ជ្រុងជ្រោយ និងជាយុទ្ធសាស្ត្រ។ ប៉ុន្តែ អ្វីដែលកម្ពុជាអាចធ្វើបាននាពេលបច្ចុប្បន្ននេះ ដើម្បីទាញប្រយោជន៍នានាពីសហគមន៍សេដ្ឋកិច្ចអាស៊ានឱ្យបានជាអតិបរមា ការបើកចំហបេះដូងដើម្បីរៀនសូត្រពីចំណុចខ្លាំងនៃប្រទេសអាស៊ានដទៃ។ ទន្ទឹមនេះ ការវិនិយោគលើវិស័យអប់រំបន្ថែមទៀត គឺជាកត្តាចាំបាច់មួយ ដែលធនធានមនុស្សកើតចេញពីការពង្រឹងវិស័យអប់រំនេះ នឹងរួមចំណែកកែលម្អ និងលុបបំបាត់បញ្ហាប្រឈមខាងលើយ៉ាងមានប្រសិទ្ធភាព។



*ដោយ ឯមតាន់ សុផានិត*

**ឯកសារយោង៖**

១. ប្រាជ្ញ វិជ័យ, នុំ ដារុយ, សេ់ សុខលៀង, សេ់ សុខឡាង *អាស៊ានជាទីស្រលាញ់របស់ខ្ញុំ* ឆ្នាំ២០១៥

២. កេត សុជាតិ, តែ ពន្លឺ *នីតិអាស៊ាននិងប្រព័ន្ធនយោបាយ* ភ្នំពេញ ឆ្នាំ២០១០

៣. គេហទំព័រសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍, http://asean.org/

៤. គេហទំព័រក្រុមប្រឹក្សាធុរកិច្ចអាស៊ាន-អាមេរិក, https://www.usasean.org

៥. បណ្ឌិត ស៊ុក ស៊ីផាន់ណា_*សមាហរណកម្មអាស៊ាន* ឆ្នាំ២០១៥, http://www.saintblanquat.com/

៦. *កម្ពុជា និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥*, http://www.blog.aseankorea.org

## ស្វែងយល់អំពីវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

### (បទពាក្យប្រាំពីរ)

១. រៀមលើកប៉ាកកាចារផ្ទួនចាប់ រៀបរាប់ជាស័ព្ទពាក្យប្រាំពីរ
ផ្សាយជូនប្រិយមិត្តគ្រប់ទិសទី បានយល់អំពីវិមជ្ឈការ។

២. និយមន័យបានចែងជាក់ច្បាស់ ផ្តល់ភាពជាម្ចាស់ក្រុមប្រឹក្សា
អនុវត្តមុខងារសិទ្ធិនីត្យា តបតម្រូវការរាស្ត្រប្រជា។

៣. ក្នុងបរិការណ៍កែទម្រង់ មិនត្រឹមផ្តោតផ្ទង់វិមជ្ឈការ
យល់ដឹងឱ្យច្បាស់រាល់មាត្រា វិសហមជ្ឈការតាមមាត៌ា។

៤. វិសហមជ្ឈការល្អត្រកាល រដ្ឋាភិបាលផ្ទេរមុខងារ
ធនធាន នីតិសម្បទា ថ្នាក់ក្រោមធានាអនុវត្ត។

៥. អំណាចមុខងារត្រូវទទួល ឥតបីប្រែប្រួលជាក់ប្រាកដ
តែភាពជាម្ចាស់ដែលកំណត់ នៅថ្នាក់ជាតិជាប់ដូចពីមុន។

៦. អត្ថប្រយោជន៍ដ៏ឧត្តម សេវាតូចធំនៅជុំព័ទ្ធ
ឃុំសង្កាត់យើងធ្វើការស្ទាត់ ស្របតាមបែបបទកែទម្រង់។

៧. ម្យ៉ាងក្រុមប្រឹក្សាដែលជាប់ឆ្នោត គិតគូរផ្តួចផ្តើមយ៉ាងផ្ចិតផ្ចង់
ជាក់ចេញដីកាត្រូវតាមប្លង់ បម្រើចំណង់រាស្ត្រមូលដ្ឋាន។

៨. ដើម្បីសម្រេចការងារនេះ រដ្ឋគិតត្រិះរិះដាក់ចេញបាន
កំណែទម្រង់ប្រាំបីជាន សម្រាប់ជាស្ពានវឌ្ឍនការ។

៩. ទីមួយរៀបចំការបោះឆ្នោត ប្រជាគិតផ្តោតពិចារណា
គូសឆ្នោតជ្រើសរើសក្រុមប្រឹក្សា ជួយដោះបញ្ហាក្នុងដែនដី។

១០. ទីពីរប្រព័ន្ធសាងផែនការ មានរាស្ត្រប្រជាជាសក្ខី
ស្តាប់ពាក្យពួកគាត់ហើយឃ្នាតខ្ចី ប្រើប្រាស់គណនេយ្យដោយតម្លា។

១១. ទីបីប្រគល់ផ្នែកហិរញ្ញ រដ្ឋបាលគិតដេញតាមកិច្ចការ
ប្រើប្រាស់មូលនិធិដោយនីត្យា ស្របតាមមាត្រាច្បាប់នានា។

១២. ទីបួនគ្រប់គ្រងធនធានមនុស្ស ទៅតាមសមុហ៍ជាក់ប្រជា
កសាងសមត្ថភាពការងារ សំដៅធានាវឌ្ឍនភាព។

១៣. ទីប្រាំការផ្ទេរនូវមុខងារ ធនធាននានាតាមរបៀប
វិភាគមុខងារតាមលទ្ធភាព និងការស្វែងស្វាបភាពជាក់ស្តែង។

១៤. ប្រាំមួយពាក់ព័ន្ធនឹងសេវា ផ្តល់តាមគោលការណ៍ដែលបានចែង
កំណត់វេលាកុំយូរវែង ក្រែងរាស្ត្រចំបែងបោះទម្លាក់។

១៥. ប្រាំពីរពង្រឹងគណនេយ្យភាព ឱកាសស្មើប្រៀបជូនរាស្ត្រអ្នក
ចូលរួមសកម្មឥតស្ទើរស្ទាក់ ផ្តល់ភាពជឿជាក់លើរាជការ។

១៦. ប្រាំបីបង្កើតសមាគម ទីប្រមូលផ្តុំក្រុមប្រឹក្សា
ប្រជុំគិតគូរស្នើគោលការណ៍ ជូនដល់រដ្ឋារៀបជាច្បាប់។

១៧. ប្រាំបីខាងលើដែលបានចារ គឺជាយន្តការដែលមានស្រាប់
ប៉ុន្តែបើខ្វះអ្នកត្រងត្រាប់ នោះពិរោះស្តាប់ឥតបានការ។

១៨. ចំណារទឹកខ្មៅវគ្គចុងក្រោយ ទទូចសុំឱ្យរួមចលនា
គ្រប់អ្នកពាក់ព័ន្ធតាមមុខការ ទើបវិមជ្ឈការបានជោគជ័យ។

*រៀបរៀងដោយ ណុំ វណ្ណា*
*កែសម្រួលដោយ ឯមតាន់ សុផានិត*

## តំបន់ទេសចរណ៍សំខាន់ៗក្នុងខេត្តមណ្ឌលគិរី



អត្តសញ្ញាណខេត្តមណ្ឌលគិរី

**ខេត្តមណ្ឌលគិរី** ស្ថិតនៅភូមិភាគឦសាននៃប្រទេស មានចម្ងាយប្រហែល ៥៤៣គ.ម ពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតនិងខាងត្បូងជាប់ព្រំដែនប្រទេសវៀតណាម ខាងជើងជាប់ខេត្តរតនគិរី និងខាងលិចជាប់ខេត្តក្រចេះ។ ខេត្តមណ្ឌលគិរី ជាខេត្តដែលមានប្រជាជនតិចបំផុតនៅប្រទេសកម្ពុជា គឺមានចំនួន៦០ ៨១១នាក់(ជំរឿន ២០០៨) មានវិសាលភាពផ្ទៃដីចំនួន ១៤ ២៨៨គម² មានក្រុង០១ ស្រុក០៤ ឃុំ/សង្កាត់២១ និងភូមិ៩៨ ហើយខេត្តនេះត្រូវបានគេស្គាល់ដោយសារមានភ្នំតូចៗ ដែលមានព្រៃក្រាស់អមដោយទេសភាពខៀវស្រងាត់ និងទឹកជ្រោះដ៏ស្រស់ស្អាត។ ទោះជាខេត្តមណ្ឌលគិរី ជាខេត្តដាច់ស្រយាលក៏ដោយ តែអាចទាក់ទាញភ្ញៀវទេសចរយ៉ាងច្រើនកុះករ ឱ្យធ្វើដំណើរមកកម្សាន្តរីករាយក្នុងពិភពនៃភាពស្ងប់ស្ងាត់ និងភាពស្រស់ស្អាត។ ភ្ញៀវទេសចរអាចធ្វើដំណើរតាមរទេះគោ(ឬជិះដំរី) កាត់តាមព្រៃខៀវស្រងាត់ដើម្បីគយគន់ទេសភាពស្រស់បំព្រង និងស្រូបយកខ្យល់អាកាសបរិសុទ្ធ។




ផែនទីសម្គាល់ខេត្តមណ្ឌលគិរី

### ទឹកជ្រោះប៊ូស្រា

ទឹកជ្រោះប៊ូស្រា ស្ថិតក្នុងស្រុកពេជ្រចិន្តា មានចម្ងាយ៤៣គ.ម ប៉ែកឦសានពីក្រុងសែនមនោរម្យ។ ភ្ញៀវអាចទៅដល់ទីនោះ តាមផ្លូវដីក្រហម នឹងឃើញទឹកជ្រោះនេះដ៏គួរឱ្យចាប់អារម្មណ៍ ដែលជារមណីយដ្ឋានដ៏មានប្រជាប្រិយបំផុតរបស់ខេត្ត ហើយទឹកជ្រោះនេះ បានបែងចែកចេញជាបីដំណាក់គឺ៖ ដំណាក់ទីមួយជាទឹកជ្រោះកម្ពស់ពី៨ ទៅ១២ម ក្នុងរដូវវស្សា និងពី១០ទៅ ១៥ម ក្នុងរដូវប្រាំង និងមានបណ្តោយ១៥ម។ ដំណាក់ទីពីរជាទឹកជ្រោះហូរធ្លាក់ក្នុងកម្ពស់ពី១៥ ទៅ២០ម មានបណ្តោយ២០ម ក្នុងរដូវវស្សា និងទឹកជ្រោះធ្លាក់ កម្ពស់ពី១៨ ទៅ២៥ម បណ្តោយ២០ម ក្នុងរដូវប្រាំង ហើយទឹកជ្រោះដំណាក់ទីពីរមានចម្ងាយ១៥០ម ពីដំណាក់ទីមួយប៉ុណ្ណោះ។ ដំណាក់ទីបី

ជាទឹកជ្រោះមានល្បឿនហូរធ្លាក់លឿនជាងដំណាក់ទីពីរ និងស្ថិតក្នុងព្រៃក្រាស់ មានការពិបាកក្នុងការធ្វើដំណើរ និងមានប្រភេទសត្វប្រកបដោយគ្រោះថ្នាក់ធ្វើឱ្យភ្ញៀវមិនអាចទៅដល់ទីតាំងនេះបានទេ។



*ទឹកជ្រោះប៊ូស្រា*

### ទឹកជ្រោះព្រៃធំ

ទឹកជ្រោះព្រៃធំ ស្ថិតនៅក្នុងភូមិពូល និងភូមិពូធុប ឃុំដាក់ដាំស្រុកអូររាំង ចម្ងាយប្រហែល ២០គ.ម ពីទីរួមខេត្តមណ្ឌលគិរី។ ក្នុងរដូវប្រាំង ទឹកជ្រោះនេះមានកម្ពស់១៥ម និងអង្កត់ផ្ចិត២ម ក្នុងរដូវវស្សាទឹកជ្រោះមានកម្ពស់១១ម និងអង្កត់ផ្ចិត៨ម ព័ទ្ធជុំវិញដោយចម្ការស្រទ្បៅ និងដើមព្រៃធំៗ បែកមែកសាខា ហើយជាកន្លែងទេសចរណ៍ ជំនួសឱ្យទឹកជ្រោះប៊ូស្រាក្នុងរដូវវស្សា។



*ទឹកជ្រោះព្រៃធំ*

### ចម្ការស្រល់

ចម្ការស្រល់ មានទីតាំងនៅក្នុងក្រុងសែនមនោរម្យ ចម្ងាយប្រមាណ៦គ.មពីទីរួមខេត្ត ដោយធ្វើដំណើរតាមផ្លូវជាតិលេខ១៤។ ចម្ការស្រល់ នៅទីទួលខ្ពស់ មានដើមស្រល់លូតលាស់ជាជួរៗ និងមានកម្ពស់ស្មើគ្នា នៅលើដីមានគ្របដណ្ដប់ដោយស្លឹកស្រល់មើលទៅដូចជាកម្រាលព្រំមាសដែលអំណោយផលដល់អ្នកទេសចរសម្រាកនៅទីនោះដោយមិនចាំបាច់ប្រើកម្រាល ហើយដើមស្រល់ទាំងនេះត្រូវបានគេដាំតាំងពីមុនសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ។



*ចម្ការស្រល់*

### ទឹកជ្រោះរមនា

ទឹកជ្រោះរមនា១ គឺស្ថិតនៅក្នុងភូមិពូទ្រូ ឃុំសែនមនោរម្យ ស្រុកអូររាំង ចម្ងាយ១៧គ.មពីទីរួមខេត្ត។ តាមរយៈផ្លូវលំ យើងអាចទៅដល់ទឹកជ្រោះដែលហូរធ្លាក់មានកម្ពស់៥ម និងអង្កត់ផ្ចិត១០មក្នុងរដូវភ្លៀង ហើយក្នុងរដូវប្រាំង ទឹកជ្រោះមានកម្ពស់៦ម និងអង្កត់ផ្ចិត៨ម។ ទឹកជ្រោះរមនា២ គឺមានទីតាំងនៅក្នុងភូមិពូរាំង ឃុំសែនមនោរម្យ ស្រុកអូររាំង ចម្ងាយ១២គ.មពីទីរួមខេត្ត។ ក្នុងរដូវវស្សា ទឹកជ្រោះមានកម្ពស់៣ម និងអង្កត់ផ្ចិត១០ម ក្នុងរដូវប្រាំង ទឹកជ្រោះហូរធ្លាក់មានកម្ពស់៤ម និងបន្ទាត់ផ្ចិត៦ម។ រមណីយដ្ឋានទាំងពីរនេះ មានទីតាំងល្អ ដែលស្ថិតនៅជិតចម្ការដូចជា កៅស៊ូ កាហ្វេ ស្វាយចន្ទី ស្វាយ និងប៊ីរជាដើម។ ផ្នែកខាងក្រោមមានអាងទឹកដ៏ធំ អ្នកទេសចរអាចហែលលេងយ៉ាងសប្បាយរីករាយ ភ្ញៀវកូនក្មេង អមដោយដើមឈើធំៗផ្ដល់ម្លប់ត្រឈឹងត្រឈៃ

ទឹកជ្រោះដ៏ស្រស់ស្អាតខ្យល់អាកាសបរិសុទ្ធគួរជាទីចាប់អារម្មណ៍របស់ភ្ញៀវទេសចរ។



ទឹកជ្រោះរមនា

## ដែនជម្រកសត្វព្រៃភ្នំណាំលៀរ

ដែនជម្រកសត្វព្រៃណាំលៀរ មានចម្ងាយ៨០គ.ម ពីក្រុងសែនមនោរម្យ ហើយការធ្វើដំណើរកម្សាន្តទៅកាន់ទីនោះប្រកបដោយផាសុកភាពបំផុត ព្រោះតាមផ្លូវអមដោយព្រៃព្រឹក្សាលតាល្លើ និងមានខ្យល់អាកាសបរិសុទ្ធ។ ដែនជម្រកសត្វព្រៃនេះ ពោរពេញដោយប្រាំងថ្មស្អាតៗ ទឹកជ្រោះតូចៗ និងអូរ ដែលមានទេសភាពខៀវស្រងាត់តែម្តង។ ជាពិសេស ដែនជម្រកសត្វព្រៃភ្នំណាំលៀរ គឺជាជម្រកសត្វព្រៃ និងសត្វស្លាបជាច្រើនប្រភេទ និងជាតំបន់អភិរក្សសត្វព្រៃដ៏សំខាន់នៅក្នុងខេត្តមណ្ឌលគិរី។ បរិស្ថានដ៏ស្រស់ស្អាត ព្រៃព្រឹក្សា និងសត្វព្រៃទាំងនេះ ធ្វើឱ្យដែនជម្រកសត្វព្រៃភ្នំណាំលៀរ មានប្រជាប្រិយភាពយ៉ាងខ្លាំង អាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើន ដែលជាផ្នែកមួយបានរួមចំណែកក្នុងការលើកស្ទួយអេកូទេសចរណ៍ក្នុងខេត្ត ឱ្យកាន់តែមានវិសាលភាពដ៏អស្ចារ្យថែមទៀតផង។



ដែនជម្រកសត្វព្រៃណាំលៀរ

## ទឹកជ្រោះសែនមនោរម្យ

ទឹកជ្រោះសែនមនោរម្យ មានទីតាំងនៅក្នុងក្រុងសែនមនោរម្យ មានចម្ងាយ៥គ.ម ពីទីរួមខេត្ត។ តាមសងខាងផ្លូវលំក្រួសក្រហមឆ្ពោះទៅទីនោះមានចម្ការដំណាំឧស្សាហកម្មជាច្រើនប្រភេទ ដូចជា កៅស៊ូ កាហ្វេ និងស្វាយចន្ទី។ល។ ទឹកជ្រោះសែនមនោរម្យមានបីដំណាក់៖ ដំណាក់ទីមួយជាទឹកជ្រោះធ្លាក់មានល្បឿនយឺតកម្ពស់១ម និងបន្ទាត់ផ្ចិត២ ទៅ៤ម ដំណាក់ទីពីរក្នុងកំឡុងពេលរដូវវស្សា ទឹកជ្រោះហូរធ្លាក់មានល្បឿនខ្លាំង កម្ពស់៦ ទៅ៧ម និងអង្កត់ផ្ចិត ៨ម ហើយក្នុងរដូវប្រាំង ទឹកជ្រោះមានកម្ពស់ ៧ ទៅ ៩ម អង្កត់ផ្ចិត៤ ទៅ៥ម និងដំណាក់ទីបីមានទីតាំងនៅចម្ងាយ១គ.ម ពីដំណាក់ទីពីរ មានកម្ពស់១.៥ម តែប៉ុណ្ណោះ។ ជាធម្មតាប្រជាជនក្នុងតំបន់បានមកកម្សាន្តសម្រាកលំហែកាយ និងជួបជុំគ្នាក្នុងអំឡុងថ្ងៃឈប់សម្រាក និងពិធីបុណ្យជាតិ ដោយសារតែទឹកជ្រោះសែនមនោរម្យនៅជិតទីរួមខេត្ត។



ទឹកជ្រោះសែនមនោរម្យ

## ទឹកជ្រោះអូរតឹងលឹង

ទឹកជ្រោះអូរតឹងលឹង ស្ថិតនៅក្នុងឃុំមេម៉ង់ ស្រុកកែវសីមា ចម្ងាយ៣០គ.មពីទីរួមខេត្ត។ ទឹកជ្រោះដ៏ស្រស់ស្អាត ព្រៃភ្នំ កូនភ្នំ ខ្យល់អាកាសបរិសុទ្ធ ទេសភាពដ៏ស្រស់ត្រកាលរបស់ទឹកជ្រោះអូរតឹងលឹង

អាចទាក់ទាញភ្ញៀវទេសចរទៅកម្សាន្ត ជាពិសេសសម្រាប់អ្នកស្រឡាញ់ធម្មជាតិ និងការផ្សងព្រេងអាចធ្វើដំណើរតាមថ្មើរជើង និងអាចបោះជំរុំនៅជិតទឹកជ្រោះនោះបាន។



*ទឹកជ្រោះអូររ៉ាំងលើង*

## ទឹកជ្រោះលោកប៉ូកប្រះ

ទឹកជ្រោះលោកប៉ូកប្រះ មានទីតាំងនៅសង្កាត់រមនា ក្រុងសែនមនោរម្យ ចម្ងាយប្រហែល១២ទៅ១៣គ.ម ពីទីរួមខេត្ត។ រដូវវស្សាទឹកជ្រោះមានកម្ពស់ប្រហែល៨ម និងអង្កត់ផ្ចិតប្រហែល៣៩ម ឯរដូវប្រាំងវិញ ទឹកធ្លាក់មានកម្ពស់១០ម និងអង្កត់ផ្ចិតប្រហែល២០ម តែប៉ុណ្ណោះ។ នៅផ្នែកខាងក្រោម មានអាងស្តុកទឹកយ៉ាងធំថ្លាល្អេង និងមានដើមឈើធំៗផ្តល់ម្លប់ដ៏ត្រឈឹងត្រឈៃ ដល់អ្នកទេសចរសម្រាកកាយ ស្រូបយកខ្យល់អាកាសបរិសុទ្ធ និងហែលលេងកម្សាន្ត ជាពិសេស មានផ្ទះរបស់ជនជាតិដើមភាគតិច ដែលមានភាពសម្បូរបែបផ្នែកវប្បធម៌រស់នៅ។



*ទឹកជ្រោះលោកប៉ូកប្រះ*

## រមណីយដ្ឋានភ្នំដោះក្រមុំ

ភ្នំដោះក្រមុំ មានទីតាំងស្ថិតនៅក្នុងភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ មានចម្ងាយ ៣គ.ម ពីទីរួមខេត្ត។ រមណីយដ្ឋានភ្នំដោះក្រមុំ មានទេសភាពធម្មជាតិដ៏អស្ចារ្យ ជាពិសេសអ្វីដែលទាក់ទាញជាងគេបំផុតនោះ គឺភ្នំគ្របដណ្តប់ដោយវាលស្មៅពីជើងដល់កំពូលភ្នំ ហើយមិនសូវមានដើមឈើធំៗទេ លើកលែងតែនៅជិតជ្រលងភ្នំ និងជ្រោះប៉ុណ្ណោះ។ នៅលើកំពូលភ្នំ យើងអាចមើលឃើញទេសភាពដ៏ស្រស់ត្រកាល នៃទីរួមខេត្តមណ្ឌលគិរីទាំងមូល និងព្រៃភ្នំធម្មជាតិដ៏ស្រស់ស្អាតផងដែរ។



*រមណីយដ្ឋានភ្នំដោះក្រមុំ*

## សមុទ្រឈើ

សមុទ្រឈើ មានទីតាំងស្ថិតនៅខាងជើងឆៀងខាងលិចនៃក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជិតវត្តភ្នំដោះក្រមុំ ជាកន្លែងដ៏ល្អមួយដែលមានទេសភាពដ៏ស្រស់ស្អាតក្នុងខេត្តមណ្ឌលគិរី។ ប្រសិនបើយើងឈរមើលពីលើកំពូលភ្នំ យើងនឹងឃើញដើមឈើមានលក្ខណៈដូចជាទឹករលកអញ្ចឹង ដោយវាមិនគ្របដណ្តប់ដោយទឹកទេ ប៉ុន្តែពោរពេញដោយដើមឈើ ប្រកបដោយពណ៌ខៀវស្រងាត់។



*សមុទ្រឈើ*

### ដែនជម្រកសត្វព្រៃភ្នំព្រិច

ជាតំបន់ទេសចរណ៍ដ៏ពេញនិយមមួយក្នុងខេត្តមណ្ឌលគិរី លាតសន្ធឹងលើផ្ទៃដី ២ ២២៥គ.ម² ស្ថិតនៅក្នុងព្រៃទេសភាពភាគខាងកើត មានព្រៃត្រូពិកដ៏ធំ និងទន្លេដ៏ស្រស់ស្អាត ដែលអាចទាក់ទាញអ្នកទេសចរស្រឡាញ់ធម្មជាតិ និងបរិស្ថានមកកម្សាន្ត។ ដែនជម្រកសត្វព្រៃភ្នំព្រិច គឺជាកន្លែងរស់នៅរបស់សត្វជិតផុតពូជជាច្រើន ជាសត្វដែលត្រូវបានគេការពារយ៉ាងល្អ រួមមាន ខ្លា ដំរីអាស៊ី ក្របីទឹកព្រៃ ឆ្មាព្រៃ ក្ងាន់ ថនិកសត្វ បក្សីដូចជាសត្វក្រៀលត្រយងយក្ស សត្វល្មូនជាច្រើនប្រភេទរស់នៅ។



ដែនជម្រកសត្វព្រៃភ្នំព្រិច

### រមណីយដ្ឋានវប្បធម៌ភ្នំក្រោល

យើងត្រូវធ្វើដំណើរចំណាយពេល ៣ម៉ោង ដោយឡាន និងប្រហែល៤ម៉ោង ដោយម៉ូតូ ក្នុងរដូវប្រាំងពីក្រុងសែនមនោរម្យតាមផ្លូវលេខ៧៦ តែក្នុងរដូវវស្សាត្រូវចំណាយពេលយូរជាងនេះ ទើបដល់រមណីយដ្ឋានវប្បធម៌ភ្នំក្រោល។ រមណីដ្ឋានមានទីតាំងស្ថិតនៅក្នុងភូមិអូរយេះ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្ត-មណ្ឌលគិរី ដែលមានចម្ងាយ៣គ.ម ពីទីរួមស្រុកកោះញែក និង១១១គ.ម ពីក្រុងសែនមនោរម្យ។ ជាពិសេសកន្លែងដ៏គួរឱ្យចាប់អារម្មណ៍ និងទាក់ទាញជាងគេ នៅរមណីយដ្ឋាន គឺកន្លែងសក្ការៈបូជាមួយដែលស្ថិតនៅលើកំពូលភ្នំ ដោយអ្នកភូមិ និងអ្នកទេសចរភាគច្រើនមកទីនេះធ្វើការបន់ស្រន់ សុំសេចក្ដីសុខ និងភាពរីកចម្រើន។



រមណីយដ្ឋានវប្បធម៌ភ្នំក្រោល

*ដោយ ញឹន ស្រ៊ិន់*

ឯកសារយោង៖


-www.tourismcambodia.org

-Tourism Sites of Cambodia

# សារប្រយោជន៍របស់ផ្លែម្រះ សម្រាប់សុខភាព

ជាទូទៅ មនុស្សមួយចំនួនមិនចូលចិត្តបរិភោគផ្លែម្រះទេដោយសារផ្លែម្រះមានជាតិល្វីង ប៉ុន្តែសម្រាប់ប្រជាជនខ្មែរ បានយកផ្លែម្រះ មកច្នៃធ្វើជាម្ហូបបានជាច្រើនប្រភេទដែលប្រើប្រាស់ទាំងផ្លែ និងស្លឹកផងដែរ។ ផ្លែម្រះមានប្រយោជន៍ជាច្រើនដូចជា៖



១. **ជួយប្រឆាំងជំងឺទឹកនោមផ្អែម៖** ផ្លែម្រះបានកាត់បន្ថយជាតិស្ករក្នុងឈាមដែលធ្វើឱ្យកើតមានជំងឺទឹកនោមផ្អែម ព្រោះជាតិល្វីងនៃម្រះអាចជួយដុតបរិមាណជាតិស្ករក្នុងរាងកាយ ប្រសិនបើអ្នកឧស្សាហ៍ទទួលទានផ្លែម្រះ ឬកិនផ្លែម្រះធ្វើជាភេសជ្ជៈសម្រាប់ពិសារនោះ អ្នកនឹងមិនប្រឈមមុខនឹងជំងឺទឹកនោមផ្អែមឡើយ ។

២. **ការពារកុំឱ្យមានគ្រួសក្នុងក្រលៀន៖** គ្រួសក្នុងក្រលៀនជាជំងឺដ៏ឈឺចាប់ប៉ុន្តែការពិសារផ្លែម្រះអាចកាត់បន្ថយការលើសជាតិអាស៊ីតនៅក្នុងរាងកាយដែលបណ្តាលឱ្យកើតមានជំងឺគ្រួសក្នុងក្រលៀន តែអ្នកនឹងមិនងាយកើតជំងឺនេះបើអ្នកបានពិសារផ្លែម្រះច្រើន។

៣. **បន្ថយជាតិខ្លាញ់ក្នុងឈាម៖** ផ្លែម្រះអាចជួយកាត់បន្ថយកម្រិតជាតិខ្លាញ់ក្នុងឈាម ជាតិខ្លាញ់ក្នុងរាងកាយដែលអាចធ្វើឱ្យអ្នកប្រឈមមុខនឹងជំងឺជាច្រើនដូចជា ជំងឺគាំងបេះដូង ជំងឺមហារីកបេះដូង និងការដាច់សរសៃឈាម ការពិសារផ្លែម្រះអាចកាត់បន្ថយជាតិខ្លាញ់ខ្ពស់ក្នុងរាងកាយ។

៤. **ការពារនិងប្រឆាំងជំងឺមហារីក៖** គុណប្រយោជន៍នៃផ្លែម្រះគឺវាអាចប្រឆាំងនឹងជំងឺមហារីកបានដោយសារម្រះវាប្រឆាំងនឹងការផលិតជាតិស្ករច្រើនហួសក្នុងរាងកាយ ដូច្នេះវាអាចផ្តល់ប្រយោជន៍ដល់ការប្រឆាំងនូវការលូតលាស់នៃកោសិកាមហារីកជាច្រើនក្នុងរាងកាយ ដូចជាការលូតលាស់នៃមហារីកថ្លើម មហារីកដោះ និងពោះវៀនធំ។ បើតាមការស្រាវជ្រាវរបស់វេជ្ជបណ្ឌិត Frank Shallenberger នៅ University of Colorado បានរកឃើញថា នៅក្នុងផ្លែម្រះមានសារធាតុវ៉ាវ៥% ដែលអាចជួយកម្ចាត់កោសិកាមហារីក និងថែរក្សាលំពែងរបស់មនុស្សបានយ៉ាងល្អ នៅក្នុងទឹកម្រះល្វីងៗអាចសម្លាប់កោសិកាមហារីកប្រហែល៩០%។

**៥. ផ្តល់គុណសម្បត្តិដល់ការថែរក្សាស្បែក៖**

ការពិសារ ផ្លែម្រះ ដោយធ្វើជាម្ហូប ឬកិនជាទឹក ដោយពិសារជាប្រចាំវាអាចផ្តល់ប្រយោជន៍ដល់ស្បែក របស់អ្នកតាមរយៈការបង្កា មិនឱ្យកើតមុន ជំងឺសើស្បែក និងជំងឺស្បែកស្ងួតជាដើម។ អ្នកវិទ្យាសាស្ត្រខ្លះក៏បានយកផ្លែម្រះធ្វើជាឡេថែរក្សាស្បែកផងដែរនិងធ្វើជាអាហារបរិភោគដូចជាស៊ុបម្រះ ឬ ស្ងោរម្រះ សម្រាប់ពិសារជាប្រចាំក៏អាចធ្វើឱ្យស្បែកស្រស់ថ្លាដែរ។



**៦. ជួយការពារជំងឺថ្លើម៖** ផ្លែម្រះ ក៏អាចជួយដល់សុខភាពថ្លើម ហើយមានសារៈសំខាន់ក្នុងរាងកាយ ព្រោះ វាអាចជំនួយដល់ការរំលាយអាហារ ការបន្សាបជាតិពុលមុនពេលអាហារចូលក្នុងប្រមាត់ជាដើម។ លើសពីនោះ ផ្លែម្រះ អាចជួយការពារមិនឱ្យកើតជំងឺថ្លើម ដែលបណ្ដាលមកពីការពិសារស្រាច្រើនពេក ដូចជាជំងឺរលាកថ្លើម និងការទល់លាមក។

**៨. ប្រភពនៃវីតាមីនK៖** វីតាមីន K អាចជួយឱ្យអ្នកមានសុខភាពឆ្អឹងល្អ និងជួយប្រឆាំងនូវការរលាកឆ្អឹង ជួយកាត់បន្ថយការឈឺចុកចាប់ពីជំងឺរលាកសន្លាក់ផ្សេងៗ។ ផ្លែម្រះ ត្រូវបានគេពិសោធន៍ឃើញថា សម្បូរដោយជាតិវីតាមីន K ដែលអាចជួយឱ្យអ្នកមានសុខភាពល្អ និងប្រឆាំងនឹងជំងឺឆ្អឹងនានា។

**៩. ជួយឱ្យប្រព័ន្ធស៊ាំក្នុងរាងកាយមាំមួន៖** ប្រព័ន្ធស៊ាំការពាររាងកាយល្អ នឹងធ្វើឱ្យអ្នកអាចប្រយុទ្ធប្រឆាំងនឹងជំងឺ ឬវីរុសផ្សេងៗទៀត។ ចំពោះផ្លែម្រះ ដែលមានជាតិល្វីងហាក់ដូចជាថ្នាំសម្រាប់ព្យាបាល ម្យ៉ាងដែលវាជួយប្រឆាំងនឹងបាក់តេរី ឬវីរុសដែរ និងធ្វើឱ្យរាងកាយអ្នករឹងមាំ មិនងាយកើតជំងឺនានា ដូចជា ផ្ដាសាយ និងគ្រុនក្ដៅជាដើម។ ការព្យាយាមពិសារផ្លែម្រះ ទោះបីជាវាល្វីងបន្តិចមែនតែវាក៏អាចជួយដល់សុខភាពរបស់អ្នក។

**១០.វិធីយកម្រះសម្រាប់បរិភោគ**

**ឆាម្រះ បង្គា និងស្លឹកញ**




**គ្រឿងផ្សំ**

១.បង្គាត្រាំទឹកគីមបួយ (មួយក្បាលទម្ងន់៣០-៤០ក្រាម) ៦ក្បាល

២.ប្រេងដូង៤ស្លាបព្រា

៣.ផ្លែម្រះ៤០០ក្រាម

៤.ស្លឹកញហាន់១កូនចាន

៥.ទឹកស៊ីអ៊ីវ ១ស្លាបព្រាបាយ

៦.អំបិល១ស្លាបព្រា

៧.ស្ករស១ស្លាបព្រា

៨.ខ្ទឹមសចិញ្ច្រាំ១ស្លាបព្រាកាហ្វេ

*** វិធីធ្វើ**

១.លាងសម្អាតបង្គា បកសម្បកចេញ ពុះខ្នងទាញសរសៃខ្មៅពីខ្នងបង្គាចេញ លើកទុកមួយអន្លើ។

២.ដាក់ខ្ទះបើកភ្លើងតិចៗ ដាក់ប្រេងឆាចូលរួចដាក់ខ្ទឹមសចិញ្ច្រាំបំពងទាល់តែឡើងលឿងហើយឆ្អុយរួចដួសខ្ទឹមសដាក់ក្នុងកូនចាន។ បន្ទាប់មកដាក់បង្គាឆាល្មមឆ្អិនហើយដួសដាក់ចានទុកទៀត បន្ទាប់មកដាក់ម្រះឆានៅពេលសង្កេតឃើញថាវាឆ្អិនហើយ យើងដាក់បង្គា និងស្លឹកញចូល ហើយបន្ថែមទឹកស៊ីអ៊ីវ អំបិល និងស្ករស ឆាត្រឡប់ទៅមកឱ្យសព្វរួចបិទភ្លើង។

៣.ដួសដាក់ចាន រោយខ្ទឹមសបំពង រួចលើកមក បរិភោគទាន់នៅក្តៅៗ។

**ទឹកម្រះថែរក្សាសុខភាព**

**<u>គ្រឿងផ្សំ</u>**

១.ផ្លែម្រះ១ផ្លែ

២.ម្សៅល្មៀតមួយចុងស្លាបព្រា

៤.ទឹកឆ្អិន១កែវ

៥.អំបិលកន្លះស្លាបព្រាកាហ្វេ

*** វិធីធ្វើ**

យកម្រះលាងទឹកឱ្យស្អាតហើយកាត់វាជាពីរយក គ្រាប់ចេញ បន្ទាប់មកហាន់វាជាចំណិតស្តើងៗ បន្ទាប់មកយកម្រះដែលហាន់រួចយកទៅច្របាច់ ជាមួយអំបិល ល្មៀត និងក្រូចឆ្មា ហើយច្របាច់យក ទឹកចេញ រួចយកម្រះនោះ ទៅក្រឡុកជាមួយទឹករួច ចាក់ទុកដាក់កែវរួចជាការស្រេច។



*ដោយ សាឿន មកត៌*

<u>ឯកសារយោង</u>:


- https://www.khmerload.com/news/27575
- http://news.sabay.com.kh/article/238106
- http://www.pmhotnews.com/2015/08/09/12246.html/

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៨ អនុក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## បណ្ណព្រំដែនកម្ពុជា-ថៃ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការគ្រប់គ្រង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីគោលការណ៍ និងយន្តការនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ សម្រាប់ប្រើប្រាស់ក្នុងការចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **ប័ណ្ណព្រំដែនកម្ពុជា-ថៃ** សំដៅដល់ឯកសារធ្វើដំណើរមានដែនកំណត់ដែលចេញឲ្យប្រើដោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាសម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ប្រើប្រាស់ក្នុងការចេញចូលឆ្លងកាត់ព្រំដែនរយៈពេលខ្លី ស្របទៅតាមគោលការណ៍កំណត់។
- **ច្រកទ្វារព្រំដែន** សំដៅដល់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារតំបន់ព្រំដែន។
- **ច្រកទ្វារព្រំដែនអន្តរជាតិ** មានន័យថា ច្រកទ្វារសម្រាប់ការឆ្លងកាត់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀង និងពលរដ្ឋនៃប្រទេសដទៃទៀត។
- **ច្រកទ្វារតំបន់ព្រំដែន** មានន័យថា ច្រកទ្វារសម្រាប់ចេញ-ចូលតំបន់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀងដែលស្នាក់នៅអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន។

## ជំពូកទី២

## គោលការណ៍នៃការគ្រប់គ្រង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**មាត្រា ៥.-**

ត្រូវបានបង្កើតប័ណ្ណព្រំដែនកម្ពុជា-ថៃសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ដូចមានគំរូភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៦.-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការផលិត ការចាត់ចែង និងការត្រួតពិនិត្យការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ដោយធានាឲ្យបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសប្រតិភូកម្មអំណាចជូនដល់អភិបាលខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ក្នុងការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃសម្រាប់ជូនប្រជាពលរដ្ឋខ្មែរ ដើម្បីប្រើប្រាស់។

**មាត្រា ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃ ត្រូវបានផ្តល់ជូនចំពោះតែប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅតាមបណ្តាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រថៃ។

ត្រូវបានហាមឃាត់ដាច់ខាតចំពោះការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលពុំមានលំនៅឋានអចិន្ត្រៃយ៍នៅតាមបណ្តាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រថៃ។

**មាត្រា ៨.-**

អ្នកកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវគោរពឲ្យបានត្រឹមត្រូវតាមច្បាប់ និងកិច្ចព្រមព្រៀងនានាជាធរមាន។

## ជំពូកទី៣

## យន្តការ បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**មាត្រា ៩.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយព្រះរាជាណាចក្រថៃ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំ ចាត់ចែង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ត្រូវរៀបចំយន្តការនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនប្រជាពលរដ្ឋខ្មែរនៅក្នុងទីតាំងសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត ស្របទៅតាមគោលការណ៍ដូចបានកំណត់នៅក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១០.-**

បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១១.-**

កម្រៃ និងរយៈពេលនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## សុពលភាពប័ណ្ណព្រំដែនកម្ពុជា-ថៃ និងរយៈពេលស្នាក់នៅ

**មាត្រា ១២.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃមានសុពលភាពរយៈពេល ០២ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០២ឆ្នាំ។

**មាត្រា ១៣.-**

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃមានសុពលភាព ត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរចេញចូលឆ្លងកាត់ព្រំដែនតាមច្រកទ្វារព្រំដែនផ្លូវការរវាងខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា និងខេត្តជាប់ព្រំដែនដែលនៅទល់មុខគ្នានៃព្រះរាជាណាចក្រថៃ លើកលែងតែមានការកំណត់ដោយឡែក ដោយមានការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃអាចធ្វើដំណើរ ឬស្នាក់នៅក្នុងទឹកដីរបស់ភាគីថៃក្នុងថេរវេលាដែលបានកំណត់ក្នុងអនុក្រឹត្យនេះ និងត្រូវបានអនុញ្ញាតឲ្យចេញតាមច្រកទ្វារព្រំដែនដែលបានចូល។

**មាត្រា ១៤.-**

ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃក្នុងគោលបំណងដូចជា ទៅសួរសុខទុក្ខញាតិសន្តាន ទេសចរណ៍ ភារកិច្ចផ្លូវការ ជំនួញ កីឡា ធ្វើការងារប្រចាំថ្ងៃឬការងារតាមរដូវកាល ចូលរួមសិក្ខាសាលាកិច្ចប្រជុំ សន្និសីទ និងគោលបំណងផ្សេងទៀតតាមការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

**មាត្រា ១៥.-**

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃអាចស្នាក់នៅខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រថៃក្នុងរយៈពេលមិនលើសពី ០៧ថ្ងៃក្នុងពេលចូលម្តង។ ចំពោះការស្នាក់នៅរយៈពេលយូរ ប៉ុន្តែមិនលើសពី ១៥ថ្ងៃត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីថៃ។ រយៈពេលស្នាក់នៅនេះអាចមានការកែប្រែ ស្របទៅតាមការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃដែលបានបំពេញលក្ខខណ្ឌ និងនីតិវិធីផ្សេងក្នុងពាក់ព័ន្ធនឹងការងារប្រចាំថ្ងៃ និងការងារតាមរដូវកាល ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅចំនួន ៣០ថ្ងៃនៅខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រថៃ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៦.-**

អ្នកក្លែងក្លាយ អ្នកលួចផលិតក្លែងបន្លំ អ្នកកោសលុប អ្នករាយការណ៍ ឬផ្តល់ព័ត៌មានមិនពិត និងអ្នកប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃក្លែងក្លាយ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និងផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃដែលចេញឲ្យប្រើប្រាស់មុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបានអនុញ្ញាតឲ្យបន្តប្រើប្រាស់រហូតដល់អស់សុពលភាព។

អាជ្ញាធរមានសមត្ថកិច្ចពុំត្រូវបានអនុញ្ញាតឲ្យបន្តសុពលភាពលើប័ណ្ណព្រំដែនកម្ពុជា-ថៃ ដែលចេញឲ្យប្រើប្រាស់មុនពេលចេញអនុក្រឹត្យនេះឡើយ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្ដីពីការប្រើប្រាស់ប័ណ្ណព្រំដែននៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៥ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ច័ណ្ឌព្រំដែនកម្ពុជា-ឡាវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការឆ្លងកាត់ព្រំដែន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



៨១

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការគ្រប់គ្រង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ឡាវ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីគោលការណ៍ និងយន្តការនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សម្រាប់ប្រើប្រាស់ក្នុងការចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែន។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **ប័ណ្ណព្រំដែនកម្ពុជា-ឡាវ** សំដៅដល់ឯកសារធ្វើដំណើរមានដែនកំណត់ដែលចេញឲ្យប្រើដោយអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាសម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រើប្រាស់ក្នុងការចេញចូលឆ្លងកាត់ព្រំដែនរយៈពេលខ្លី ស្របទៅតាមគោលការណ៍កំណត់។
- **ច្រកទ្វារព្រំដែន** សំដៅដល់ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី និងច្រកទ្វារតំបន់ព្រំដែន។
- **ច្រកទ្វារព្រំដែនអន្តរជាតិ** មានន័យថា ច្រកទ្វារសម្រាប់ការឆ្លងកាត់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀង និងពលរដ្ឋនៃប្រទេសដទៃទៀត។
- **ច្រកទ្វារព្រំដែនទ្វេភាគី** មានន័យថា ច្រកទ្វារសម្រាប់ការឆ្លងកាត់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀង។
- **ច្រកទ្វារតំបន់ព្រំដែន** មានន័យថា ច្រកទ្វារសម្រាប់ចេញ-ចូលតំបន់ព្រំដែនរបស់ពលរដ្ឋនៃភាគីកិច្ចព្រមព្រៀងដែលស្នាក់នៅអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន។

## ជំពូកទី២

## គោលការណ៍នៃការគ្រប់គ្រង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**មាត្រា ៥.-**

ត្រូវបានបង្កើតប័ណ្ណព្រំដែនកម្ពុជា-ឡាវសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍

ក្នុងខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដូចមានតំរូវភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៦.-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការផលិត ការចាត់ចែង និងការត្រួតពិនិត្យការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនដល់ប្រជាពលរដ្ឋខ្មែរ ដោយធានាឲ្យបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសប្រតិភូកម្មអំណាចជូនដល់អភិបាលខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវសម្រាប់ជូនប្រជាពលរដ្ឋខ្មែរដើម្បីប្រើប្រាស់។

**មាត្រា ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ត្រូវបានផ្ដល់ជូនចំពោះតែប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅតាមបណ្ដាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំដែនជាប់ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ត្រូវបានហាមឃាត់ដាច់ខាតចំពោះការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលពុំមានលំនៅឋានអចិន្ត្រៃយ៍នៅតាមបណ្ដាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រំដែនជាប់ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**មាត្រា ៨.-**

អ្នកកាន់ប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវគោរពឲ្យបានត្រឹមត្រូវតាមច្បាប់ និងកិច្ចព្រមព្រៀងនានាជាធរមាន។

## ជំពូកទី៣

## យន្តការ បែបបទ និងនីតិវិធីនៃការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**មាត្រា ៩.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំ ចាត់ចែង និងផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ត្រូវរៀបចំយន្តការនៃការផ្ដល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនប្រជាពលរដ្ឋខ្មែរនៅក្នុងទីតាំងសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត ស្របទៅតាមគោលការណ៍ដូចបានកំណត់នៅក្នុងជំពូកទី២នៃអនុក្រឹត្យនេះ។

**មាត្រា ១០.-**

បែបបទ និងនីតិវិធីនៃការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១១.-**

កម្រៃ និងរយៈពេលនៃការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## សុពលភាពប័ណ្ណព្រំដែនកម្ពុជា-ឡាវ និងរយៈពេលស្នាក់នៅ

**មាត្រា ១២.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវមានសុពលភាពរយៈពេល ០១ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០១ឆ្នាំ។

**មាត្រា ១៣.-**

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ឡាវមានសុពលភាព ត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរចេញចូលឆ្លងកាត់ព្រំដែនតាមច្រកទ្វារព្រំដែនផ្លូវការរវាងខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា និងខេត្តជាប់ព្រំដែនដែលនៅទល់មុខគ្នានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ លើកលែងតែមានការកំណត់ដោយឡែកដោយមានការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ឡាវអាចធ្វើដំណើរ ឬស្នាក់នៅក្នុងទឹកដីរបស់ភាគីឡាវក្នុងថេរវេលាដែលបានកំណត់ក្នុងអនុក្រឹត្យនេះ និងត្រូវបានអនុញ្ញាតឲ្យចេញតាមច្រកទ្វារព្រំដែនដែលបានចូល។

**មាត្រា ១៤.-**

ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវក្នុងគោលបំណងដូចជា ទៅសួរសុខទុក្ខញាតិសន្ដាន ទេសចរណ៍ ភារកិច្ចផ្លូវការ ជំនួញ កីឡា ចូលរួមសិក្ខាសាលា កិច្ចប្រជុំ សន្និសីទ និងគោលបំណងផ្សេងទៀតតាមការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**មាត្រា ១៥.-**

ប្រជាពលរដ្ឋខ្មែរដែលកាន់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ អាចស្នាក់នៅខេត្តជាប់ព្រំដែននៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវក្នុងរយៈពេលមិនលើសពី ០៧ថ្ងៃក្នុងពេលចូលម្ដង។ ចំពោះការស្នាក់នៅរយៈពេលយូរ ប៉ុន្តែមិនលើសពី ១៥ថ្ងៃ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីឡាវ។ រយៈពេលស្នាក់នៅនេះអាចមានការកែប្រែ ស្របទៅតាមការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៦.-**

អ្នកក្លែងក្លាយ អ្នកលួចផលិតក្លែងបន្លំ អ្នកកោសលុប អ្នករាយការណ៍ ឬផ្ដល់ព័ត៌មានមិនពិត និងអ្នកប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវក្លែងក្លាយ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និងផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៤៧៧ ប្រក

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីប័ណ្ណព្រំដែនកម្ពុជា-ថៃ
- បានឃើញកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៨៣៨២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ១៨៣៨៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- តាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល

## សម្រេច

## ជំពូកទី១

## សមត្ថកិច្ចគ្រប់គ្រង និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**ប្រការ ១.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយព្រះរាជាណាចក្រថៃ ត្រូវបានប្រតិភូកម្មអំណាចឲ្យចុះហត្ថលេខាលើប័ណ្ណព្រំដែនកម្ពុជា-ថៃ ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អភិបាលខេត្តត្រូវដឹកនាំ ចាត់ចែង និងផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរ ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ជាធរមាន។

**ប្រការ ២.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានផលិត គ្រប់គ្រង ចាត់ចែង និងបែងចែកទៅតាមខេត្តដោយក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ជាសេនាធិការ។

អគ្គនាយកដ្ឋានរដ្ឋបាលជាសេនាធិការឲ្យក្រសួងមហាផ្ទៃនៅក្នុងការរៀបចំទម្រង់បែបបទ និងផ្តល់ការណែនាំបណ្តុះបណ្តាលមន្ត្រីនៅរដ្ឋបាលខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃ។

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុជាសេនាធិការឲ្យក្រសួងមហាផ្ទៃនៅក្នុងការផលិត និងរក្សាទុកប័ណ្ណព្រំដែនកម្ពុជា-ថៃឲ្យបានត្រឹមត្រូវ ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល។

## ជំពូកទី២

## អំពីប័ណ្ណព្រំដែនកម្ពុជា-ថៃ

**ប្រការ ៣.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃមានពណ៌ខៀវ និងមានចំនួន ៣២ទំព័រ ដែលមានលក្ខណៈសំគាល់របស់សាមីខ្លួនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"

- ភេទ
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលេខប័ណ្ណបញ្ជាក់ទីលំនៅ ឬលេខសំបុត្រកំណើត ឬលេខសំបុត្របញ្ជាក់កំណើត ឬលេខសៀវភៅគ្រួសារ
- ថ្ងៃខែឆ្នាំកំណើត
- ទីកន្លែងកំណើត
- កម្ពស់
- មុខរបរ
- អាសយដ្ឋាន
- ភិនភាគសំគាល់ពិសេស
- រូបថត
- ហត្ថលេខា ឬស្នាមផ្តិតមេដៃស្តាំ។

ក្នុងប័ណ្ណព្រំដែនកម្ពុជា-ថៃអាចបញ្ចូលឈ្មោះកូនស្របច្បាប់របស់អ្នកកាន់ប័ណ្ណព្រំដែនបានចំនួន ០២នាក់ ដែលមានអាយុក្រោម ១២ឆ្នាំ ដោយត្រូវកំណត់លក្ខណៈសំគាល់របស់កូនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- រូបថត
- លក្ខណៈសំគាល់។

លក្ខណៈសំគាល់ខាងលើនេះ ត្រូវចុះក្នុងប័ណ្ណព្រំដែនជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ប្រការ ៤.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃមានសុពលភាពរយៈពេល ០២ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០២ឆ្នាំ។ ផុតរយៈពេលបន្តសុពលភាពនេះ មិនអាចប្រើប្រាស់បានតទៅទៀតទេ។

**ប្រការ ៥.-**

នៅពេលផុតសុពលភាពប័ណ្ណព្រំដែនកម្ពុជា-ថៃ សាមីខ្លួនអាចស្នើសុំបន្តសុពលភាពប័ណ្ណព្រំដែនបាន ដោយត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនចាស់របស់សាមីខ្លួន។

## ជំពូកទី៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ

**ប្រការ ៦.-**

ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ អាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃនៅសាលាខេត្តដែលខ្លួនកំពុងរស់នៅ និងមានលំនៅឋានអចិន្ត្រៃយ៍ពិតប្រាកដ។ ប្រជាពលរដ្ឋខ្មែរម្នាក់អាចកាន់ប័ណ្ណព្រំដែនកម្ពុជា-ថៃតែមួយគត់។

ការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃជូនប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើឡើងតាមយន្តការច្រកចេញចូលតែមួយនៅសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត តាមស្មារតីនៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានផ្តល់ជូនប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងខេត្តដែលសាមីខ្លួនស្នើសុំប័ណ្ណព្រំដែន។ ចំពោះកុមារដែលមានអាយុក្រោម ១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុក ឬម្តាយ ឬអាណាព្យាបាល។

កុមារអាយុក្រោម ១២ឆ្នាំ អាចដាក់បញ្ចូលជាមួយប័ណ្ណព្រំដែនរបស់ឪពុក ឬម្តាយ ឬអាណាព្យាបាលបានដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

កូនដែលមានឈ្មោះក្នុងប័ណ្ណព្រំដែននេះ មិនអនុញ្ញាតឲ្យធ្វើដំណើរដោយឡែកពីអ្នកកាន់ប័ណ្ណព្រំដែនឡើយ។

**ប្រការ ៨.-**

សំណុំឯកសារភ្ជាប់ដើម្បីស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃមានដូចខាងក្រោម ៖

១-ពាក្យស្នើសុំប័ណ្ណព្រំដែនចំនួន ០១ច្បាប់ ដោយមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំរបស់សាមីខ្លួននៅលើពាក្យស្នើសុំ

២-រូបថតសាមីខ្លួនបច្ចុប្បន្ន ទំហំ ៤ x ៦ "ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតា" ចំនួន ០២សន្លឹក

៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតដែលជាច្បាប់ដើម ឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

៤-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

**ប្រការ ៩.-**

អ្នកស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃ ចាំបាច់ត្រូវ ៖

- បង្ហាញមុខដោយផ្ទាល់ជាមួយមន្ត្រីមានសមត្ថកិច្ចនៅសាលាខេត្តដែលសាមីខ្លួនដាក់ពាក្យស្នើសុំប័ណ្ណព្រំដែន ឬទីតាំងផ្សេងទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត
- បំពេញពាក្យស្នើសុំប័ណ្ណព្រំដែនមួយច្បាប់ ដែលមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់សាមីខ្លួន
- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬឯកសារថតចម្លងតាមច្បាប់ដើមដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ
- ផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែននៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែន
- បង់ថ្លៃអាករប័ណ្ណព្រំដែនតាមការកំណត់នៃប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលយកបង្កាន់ដៃបង់ប្រាក់សម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច នៅពេលទទួលយកប័ណ្ណព្រំដែន។

**ប្រការ ១០.-**

មន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចាំបាច់ត្រូវ ៖

- ទទួលពាក្យស្នើសុំប័ណ្ណព្រំដែនដែលបានបំពេញត្រឹមត្រូវ និងភ្ជាប់ឯកសារបានគ្រប់គ្រាន់តាមការកំណត់
- ណែនាំឱ្យប្រជាពលរដ្ឋផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែន ឬបិទរូបថត
- យកគិនភាគ និងស្លាកស្នាមសំគាល់ពិសេស
- វាស់កម្ពស់
- សរសេរបង្កាន់ដៃបង់ប្រាក់ ទទួលប្រាក់កម្រៃសេវាផ្តល់ប័ណ្ណព្រំដែន និងផ្តល់បង្កាន់ដៃបង់ប្រាក់ជូនប្រជាពលរដ្ឋ
- ផ្តល់ប័ណ្ណព្រំដែនជូនដល់ប្រជាពលរដ្ឋទៅតាមពេលវេលាកំណត់។

**ប្រការ ១១.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានបាត់ដោយមូលហេតុផ្សេងៗ សាមីខ្លួនត្រូវដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលកើតហេតុការណ៍បាត់ មិនឲ្យលើសពី ៤៨ម៉ោងបន្ទាប់ពីដឹងថាបាត់។

បន្ទាប់ពីបាត់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ថៃថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវពាក្យបណ្តឹងអំពីការបាត់ប័ណ្ណព្រំដែន ឬកំណត់ហេតុរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលមានបញ្ជាក់អំពីការបាត់ប័ណ្ណព្រំដែនរបស់សាមីខ្លួន។

**ប្រការ ១២.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ថៃត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនកម្ពុជា-ថៃដែលត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយនោះ។

**ប្រការ ១៣.-**

ការកំណត់កម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីមានតម្រូវការកែប្រែកម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៤.-**

ការគ្រប់គ្រងចំណូល ចំណាយ ការតក់ត្រា និងការផ្តល់ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ និងមន្ត្រីផ្សេងទៀត ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ១៥.-**

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិបដិសេធមិនផ្តល់ប័ណ្ណព្រំដែន ដកហូតប័ណ្ណព្រំដែនទុក និងបដិសេធប័ណ្ណព្រំដែនដែលបានផ្តល់ឲ្យរួចហើយ ក្នុងករណីណាមួយដូចខាងក្រោម៖

- ពិរុទ្ធជន ទណ្ឌិត ឬជនកំពុងមានដីកាបង្គាប់ឲ្យចាប់ខ្លួន
- ជនដែលមានការសម្រេចពីតុលាការហាមឃាត់ការចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- ជនដែលមានសំណើពីស្ថាប័នមានសមត្ថកិច្ចសុំមិនឲ្យផ្តល់ប័ណ្ណព្រំដែន
- ជនដែលបានទទួលប័ណ្ណព្រំដែនដែលបានផ្តល់ឲ្យខុសពីការប្រកាស ដោយសារការផ្តល់ព័ត៌មានខុសពីការពិត ឬដោយការក្លែងបន្លំ
- ជនដែលកោសលុប ឬកែខ្លឹមសារ ឬដូររូបថតនៃប័ណ្ណព្រំដែន
- ជនវិកលចរិក
- អ្នកដែលពុំមានឯកសារគ្រប់គ្រាន់តាមការកំណត់។

ប័ណ្ណព្រំដែនដែលត្រូវបានដកហូតទុក ស្ថាប័នមានសមត្ថកិច្ចត្រូវប្រគល់មកជូនរដ្ឋបាលខេត្ត។

## ជំពូកទី៤

## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ១៦.-**

ក្រសួងមហាផ្ទៃប្រគល់ភារកិច្ចឲ្យអគ្គនាយកដ្ឋានរដ្ឋបាល ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ថៃរបស់ខេត្តជាប់ព្រំដែនថៃ។

រដ្ឋបាលខេត្តត្រូវបង្កើតយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការប្រើប្រាស់ប័ណ្ណព្រំដែនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែអំពីលទ្ធផលការងារផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ជូនមកអគ្គនាយកដ្ឋានរដ្ឋបាលឲ្យបានទៀងទាត់ ដើម្បីបូកសរុបរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.-**

ត្រូវបាននិរាករណ៍ប្រកាស និងសារាចរណែនាំ ដូចខាងក្រោម៖

- ប្រកាសលេខ ១២៤២ ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធីនៃការផ្តល់ប័ណ្ណឆ្លងដែននៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ
- សារាចរណែនាំលេខ ០០២ សរ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្តល់ប័ណ្ណឆ្លងដែនជូនប្រជាពលរដ្ឋខ្មែរ និងការគ្រប់គ្រងការឆ្លងកាត់ព្រំដែន។

**ប្រការ ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ[illegible]ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ដូចប្រការ ១៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៤៧៥ ប្រក

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីប័ណ្ណព្រំដែនកម្ពុជា-ឡាវ
- បានឃើញកិច្ចព្រមព្រៀង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្ដីពីការឆ្លងកាត់ព្រំដែន
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៨៣៨២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ១៨៣៨៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការផ្ដល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមសំណើរបស់អគ្គនាយកដ្ឋានរដ្ឋបាល

## សម្រេច

## ជំពូកទី១

## សមត្ថកិច្ចគ្រប់គ្រង និងផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**ប្រការ ១.-**

អភិបាលខេត្តជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវបានប្រតិភូកម្មអំណាចឲ្យចុះហត្ថលេខាលើប័ណ្ណព្រំដែនកម្ពុជា-ឡាវ ក្នុងនាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្ដល់ជូនប្រជាពលរដ្ឋខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អភិបាលខេត្តត្រូវដឹកនាំ ចាត់ចែង និងផ្ដល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរ ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលបានកំណត់ជាធរមាន។

**ប្រការ ២.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានផលិត គ្រប់គ្រង ចាត់ចែង និងបែងចែកទៅតាមខេត្តដោយក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ជាសេនាធិការ។

អគ្គនាយកដ្ឋានរដ្ឋបាលជាសេនាធិការឲ្យក្រសួងមហាផ្ទៃនៅក្នុងការរៀបចំទម្រង់បែបបទ និងការផ្ដល់ការណែនាំបណ្ដុះបណ្ដាលមន្ត្រីនៅរដ្ឋបាលខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងការផ្ដល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ។

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុជាសេនាធិការឲ្យក្រសួងមហាផ្ទៃនៅក្នុងការផលិត និងរក្សាទុកប័ណ្ណព្រំដែនកម្ពុជា-ឡាវឲ្យបានត្រឹមត្រូវ ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល។

## ជំពូកទី២

## អំពីប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**ប្រការ ៣.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវមានពណ៌ខៀវ និងមានចំនួន ៣២ទំព័រ ដែលមានលក្ខណៈសំគាល់របស់សាមីខ្លួនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"

- ភេទ
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលេខប័ណ្ណបញ្ជាក់ទីលំនៅ ឬលេខសំបុត្រកំណើត ឬលេខសំបុត្របញ្ជាក់កំណើត ឬលេខសៀវភៅគ្រួសារ
- ថ្ងៃខែឆ្នាំកំណើត
- ទីកន្លែងកំណើត
- កម្ពស់
- មុខរបរ
- អាសយដ្ឋាន
- ភិនភាគសំគាល់ពិសេស
- រូបថត
- ហត្ថលេខា ឬស្នាមផ្តិតមេដៃស្តាំ។

ក្នុងប័ណ្ណព្រំដែនកម្ពុជា-ឡាវអាចបញ្ចូលឈ្មោះកូនស្របច្បាប់របស់អ្នកកាន់ប័ណ្ណព្រំដែនបានចំនួន ០២ នាក់ដែលមានអាយុក្រោម ១២ឆ្នាំ ដោយត្រូវកំណត់លក្ខណៈសំគាល់របស់កូនដូចខាងក្រោម៖

- ឈ្មោះ "នាមត្រកូល និងនាមខ្លួន"
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- រូបថត
- លក្ខណៈសំគាល់។

លក្ខណៈសំគាល់ខាងលើនេះ ត្រូវចុះក្នុងប័ណ្ណព្រំដែនកម្ពុជា-ឡាវជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ប្រការ ៤.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវមានសុពលភាពរយៈពេល ០១ឆ្នាំ និងអាចបន្តសុពលភាពបានយ៉ាងយូរ ០១ ឆ្នាំ។ ផុតរយៈពេលបន្តសុពលភាពនេះ មិនអាចប្រើប្រាស់បានតទៅទៀតទេ។

**ប្រការ ៥.-**

នៅពេលផុតសុពលភាពប័ណ្ណព្រំដែន សាមីខ្លួនអាចស្នើសុំបន្តសុពលភាពប័ណ្ណព្រំដែនបាន ដោយត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនចាស់របស់សាមីខ្លួន។

## ជំពូកទី៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ

**ប្រការ ៦.-**

ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ឡាវនៅសាលាខេត្តដែលខ្លួនកំពុងរស់នៅ និងមានលំនៅឋានអចិន្ត្រៃយ៍ពិតប្រាកដ។ ប្រជាពលរដ្ឋខ្មែរម្នាក់អាចកាន់ប័ណ្ណព្រំដែនកម្ពុជា-ឡាវតែមួយគត់។

ការផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើឡើងតាមយន្តការច្រកចេញចូលតែមួយនៅសាលាខេត្ត ឬទីតាំងផ្សេងៗទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត តាមស្មារតីនៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៧.-**

ប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានផ្តល់ជូនប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងខេត្តដែលសាមីខ្លួនស្នើសុំប័ណ្ណព្រំដែន។ ចំពោះកុមារដែលមានអាយុក្រោម ១៥ឆ្នាំ ត្រូវមានសំណើសុំ ឬការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុក ឬម្តាយ ឬអាណាព្យាបាល។

កុមារអាយុក្រោម ១២ឆ្នាំ អាចដាក់បញ្ចូលជាមួយប័ណ្ណព្រំដែនរបស់ឪពុក ឬម្តាយ ឬអាណាព្យាបាលបានដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

កូនដែលមានឈ្មោះក្នុងប័ណ្ណព្រំដែននេះ មិនអនុញ្ញាតឲ្យធ្វើដំណើរដោយឡែកពីអ្នកកាន់ប័ណ្ណព្រំដែនឡើយ។

**ប្រការ ៨.-**

សំណុំឯកសារភ្ជាប់ដើម្បីស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ឡាវ មានដូចខាងក្រោម ៖

១-ពាក្យស្នើសុំប័ណ្ណព្រំដែនចំនួន ០១ច្បាប់ ដោយមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំរបស់សាមីខ្លួននៅលើពាក្យស្នើសុំ

២-រូបថតសាមីខ្លួនបច្ចុប្បន្ន ទំហំ ៤ x ៦ -ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតា- ចំនួន ០២សន្លឹក

៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតដែលជាច្បាប់ដើម ឬថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

៤-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

**ប្រការ ៩.-**

អ្នកស្នើសុំប័ណ្ណព្រំដែនកម្ពុជា-ឡាវ ចាំបាច់ត្រូវ ៖

- បង្ហាញមុខដោយផ្ទាល់ជាមួយមន្ត្រីមានសមត្ថកិច្ចនៅសាលាខេត្តដែលសាមីខ្លួនដាក់ពាក្យស្នើសុំប័ណ្ណព្រំដែន ឬទីតាំងផ្សេងទៀតដែលកំណត់ដោយរដ្ឋបាលខេត្ត
- បំពេញពាក្យស្នើសុំប័ណ្ណព្រំដែនមួយច្បាប់ ដែលមានបិទរូបថត ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់សាមីខ្លួន
- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬឯកសារថតចម្លងតាមច្បាប់ដើមដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ
- ផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែននៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែន
- បង់ថ្លៃអាករប័ណ្ណព្រំដែនតាមការកំណត់នៃប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលយកបង្កាន់ដៃបង់ប្រាក់សម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច នៅពេលទទួលយកប័ណ្ណព្រំដែន។

**ប្រការ ១០.-**

មន្ត្រីមានសមត្ថកិច្ចផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ចាំបាច់ត្រូវ ៖

- ទទួលពាក្យស្នើសុំប័ណ្ណព្រំដែនដែលបានបំពេញត្រឹមត្រូវ និងភ្ជាប់ឯកសារបានគ្រប់គ្រាន់តាមការកំណត់
- ណែនាំឲ្យប្រជាពលរដ្ឋផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាលើប័ណ្ណព្រំដែន ឬបិទរូបថត
- យកភិនភាគ និងស្លាកស្នាមសំគាល់ពិសេស
- វាស់កម្ពស់
- សរសេរបង្កាន់ដៃបង់ប្រាក់ ទទួលប្រាក់កម្រៃសេវាផ្តល់ប័ណ្ណព្រំដែន និងផ្តល់បង្កាន់ដៃបង់ប្រាក់ជូនប្រជាពលរដ្ឋ
- ផ្តល់ប័ណ្ណព្រំដែនជូនដល់ប្រជាពលរដ្ឋទៅតាមពេលវេលាកំណត់។

**ប្រការ ១១.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានបាត់ដោយមូលហេតុផ្សេងៗ សាមីខ្លួនត្រូវដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលកើតហេតុការណ៍បាត់ មិនឲ្យលើសពី ៤៨ម៉ោងបន្ទាប់ពីដឹងថាបាត់។

បន្ទាប់ពីបាត់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវពាក្យបណ្តឹងអំពីការបាត់ប័ណ្ណព្រំដែន ឬកំណត់ហេតុរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងឃុំ សង្កាត់ដែលមានបញ្ជាក់អំពីការបាត់ប័ណ្ណព្រំដែនរបស់សាមីខ្លួន។

**ប្រការ ១២.-**

ក្នុងករណីប័ណ្ណព្រំដែនកម្ពុជា-ឡាវត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយ សាមីខ្លួនអាចដាក់ពាក្យស្នើសុំប័ណ្ណព្រំដែនថ្មីបាន ដោយបំពេញសំណុំឯកសារ និងបែបបទដូចមានចែងក្នុងប្រការ៨ និងប្រការ៩ នៃប្រកាសនេះ និងភ្ជាប់មកជាមួយនូវប័ណ្ណព្រំដែនដែលត្រូវបានរហែក ឬលុបអក្សរ ឬខូចទ្រង់ទ្រាយនោះ។

**ប្រការ ១៣.-**

ការកំណត់កម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវជូនដល់ប្រជាពលរដ្ឋខ្មែរ ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីមានតម្រូវការកែប្រែកម្រៃ និងរយៈពេលនៃការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៤.-**

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការផ្តល់ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រី ដែលបំពេញភារកិច្ចផ្ទាល់ក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ឡាវ និងមន្ត្រីផ្សេងទៀត ត្រូវអនុលោមទៅតាមប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ស្ដីពីការផ្ដល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ១៥.-**

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិបដិសេធមិនផ្តល់ប័ណ្ណព្រំដែន ដកហូតប័ណ្ណព្រំដែនទុក និងបដិសេធប័ណ្ណព្រំដែនដែលបានផ្ដល់ឲ្យរួចហើយ ក្នុងករណីណាមួយដូចខាងក្រោម៖

- ពិរុទ្ធជន ទណ្ឌិត ឬជនកំពុងមានដីកាបង្គាប់ឲ្យចាប់ខ្លួន
- ជនដែលមានការសម្រេចពីតុលាការហាមឃាត់ការចាកចេញពីព្រះរាជាណាចក្រកម្ពុជា
- ជនដែលមានសំណើពីស្ថាប័នមានសមត្ថកិច្ចសុំមិនឲ្យផ្ដល់ប័ណ្ណព្រំដែន
- ជនដែលបានទទួលប័ណ្ណព្រំដែនដែលបានផ្តល់ឲ្យខុសពីការប្រកាស ដោយសារការផ្តល់ព័ត៌មានខុសពីការពិត ឬដោយការក្លែងបន្លំ
- ជនដែលកោសលុប ឬកែខ្លឹមសារ ឬដូររូបថតនៃប័ណ្ណព្រំដែន
- ជនវិកលចរិក
- អ្នកដែលពុំមានឯកសារគ្រប់គ្រាន់តាមការកំណត់។

ប័ណ្ណព្រំដែនដែលត្រូវបានដកហូតទុក ស្ថាប័នមានសមត្ថកិច្ចត្រូវប្រគល់មកជូនរដ្ឋបាលខេត្ត។

## ជំពូកទី៤

## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ១៦.-**

ក្រសួងមហាផ្ទៃប្រគល់ភារកិច្ចឲ្យអគ្គនាយកដ្ឋានរដ្ឋបាល ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ប័ណ្ណព្រំដែនកម្ពុជា-ឡាវរបស់ខេត្តជាប់ព្រំដែនឡាវ។

រដ្ឋបាលខេត្តត្រូវបង្កើតយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការប្រើប្រាស់ប័ណ្ណព្រំដែនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែអំពីលទ្ធផលការងារផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ឡាវ ជូនមកអគ្គនាយកដ្ឋានរដ្ឋបាលឲ្យបានទៀងទាត់ ដើម្បីបូកសរុបរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៨.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការ

ដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ ១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ